អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 10-Aug-2012, 14:43
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសជ

**ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០៣ នាទី**

**សវនាការលើកទី៩៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាវស្ទី

លោក សេង ប៊ុនឃាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល *(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី
*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោកស្រី ជេត វណ្ណលី

លោក វ៉េន ពៅ

លោកស្រី ម៉ារី ហ្គីរ៉ូដ
*(Ms. Marie GUIRAUD)*

លោក ហ្វែឌីណង់ ចាមិន ហ្សេប៉ា
*(Mr. Ferdinand DJAMMEN NZEPA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ច័ន្ទ តារាវស្ឋី | ខ្មែរ |
| លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ឡោ ជុនធី | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ | បារាំង |
| លោក អ៊ុង ចុងហៀង (TCW-490) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក អ៊ុង ចុំងហឿង** (TCW-490)

សួរដោយលោក ឡៅ ជុនធី ផ្ដើមពី៖ ........................................ទំព័រ ៣

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ ផ្ដើមពី៖ ........................................ទំព័រ ២៤

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី៖ ........................................ទំព័រ ៣៦

សួរដោយលោក អេនឌ្រូ អ៊ីនូហ្ស៊ី ផ្ដើមពី៖ ........................................ទំព័រ ៥០

សួរដោយលោក សុន អរុណ ផ្ដើមពី៖ ........................................ទំព័រ ៦៧

សួរដោយលោក ម៉ៃខល កាណាវាស ផ្ដើមពី៖ ........................................ទំព័រ ៧៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការជាបន្តនៅព្រឹកនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សី អុង ហុងហឿង ដែលនឹងសួរដេញដោលដោយក្រុមមេធាវីការពារក្តី ដែលនឹងចាប់ផ្តើមដោយមេធាវីការពារក្តីលោក នួន ជា មុនក្រុមមេធាវីពីរក្រុមទៀត។ ហើយមុននឹងផ្តល់វេទិកា។ សូមក្រឡាបញ្ជីឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន និងអវត្តមាន។

បាទ សូមកែសម្រួលបន្តិច អាចច្រឡំ នៅព្រឹកនេះនៅបន្តឡើងការតាំងសំណួរដេញដោលចំពោះសាក្សីនេះ ដោយក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ហើយមេធាវីការពារក្តីលោក នួន ជា គឺបន្ទាប់ពីក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គល ដែលអង្គជំនុំជម្រះកោះអញ្ជើញ ឲ្យចូលរួមនៅក្នុងដំណើរការសវនាការនេះ!

[០៩:០៥:៤០]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្តីនេះ មានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងដំណើរការសវនាការដោយផ្ទាល់ ពីបន្ទប់សវនាការសម្រាប់រយៈពេលពេញ ១ថ្ងៃ នៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី។ អង្គជំនុំ-ជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍

សម្រាប់រយៈពេលដំណើរការសវនាការពេញ១ថ្ងៃនេះ។ លោកវេជ្ជបណ្ឌិត ឈាង ឃោ គ្រូពេទ្យទទួលពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅមន្ទីរឃុំឃាំង នៃ អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកមិញនេះ ហើយបានកត់សម្គាល់ឃើញថា លោក អៀង សារី មានអាការៈហត់ខ្លាំងពេលដើរ វិលមុខ ចង់ក្អួត ឈឺចង្កេះខ្លាំង ហើយមិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ដល់អង្គជំនុំជម្រះគប្បីអនុញ្ញាតឲ្យគាត់ នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយនៅខាងក្រោមសាលសវនាការនេះ។

[០៩:០៧:១២]

អង្គជំនុំជម្រះយល់ឃើញថា នាពេលនេះលោក អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ដោយមានបញ្ហាសុខភាពដូចគ្រូពេទ្យបានកត់សម្គាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយអាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ ជាមួយនឹងក្រុមមេធាវីការពាររបស់គាត់បានដែរ។

ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចយល់ព្រម តាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលសុំលះបង់សិទ្ធិចូលរួម នៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលធ្វើសវនាការក្នុងថ្ងៃនេះ។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសតាំងសំណួរដេញដោល ចំពោះសាក្សី អ៊ុង ឆុងហៀង។

សូមអញ្ជើញ!

[០៩:០៨:២៥]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជនទាំងអស់។ សម្រាប់អន្តរាគមន៍ ក៏ដូចជាការលើកសំណួរចំពោះលោកសាក្សី អ៊ុង ឆុងហៀងនេះ មេធាវី

នាំមុខសូមផ្ទេរសិទ្ធិជូនលោក ឡោ ជុនធី ជាមេធាវីជាតិនៅក្នុងអង្គការជំនួយផ្នែកច្បាប់ នៃកម្ពុជា និងលោកស្រីមេធាវី ម៉ារី ហ្គីរ៉ូដ ជាមេធាវីអន្តរជាតិនៅក្នុងក្រុមសម្ព័ន្ធអន្តរជាតិ នៃសិទ្ធិមនុស្សបារាំង។

សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណ។ ជាដំបូងខ្ញុំបាទ ឡោ ជុនធី ជាមេធាវីនៅក្នុងអង្គការជំនួយផ្នែកច្បាប់ នៅកម្ពុជា បច្ចុប្បន្នក៏ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី។

សូមគោរពលោកប្រធាន សូមគោរពអង្គជំនុំជម្រះទាំងមូល ហើយសូមគោរពសហភាគា សហព្រះរាជអាជ្ញា ហើយសូមគោរពដល់បងប្អូនជនរួមជាតិ តាមដាននៅទីនេះ ក៏តាមដានតាមប្រព័ន្ធអេឡិចត្រូនិចផ្សេងៗ។ សូមអរគុណ។

[០៩:០៩:៤២]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** លោក អុង ថុងហឿង ថ្ងៃនេះ ខ្ញុំសូមជម្រាបសួរលោកជាដំបូង ហើយសូមថ្លែងអំណរគុណដែលលោកបានអញ្ជើញមកពីចម្ងាយ ផ្តល់នូវសក្ខីកម្មដ៏មានតម្លៃនៅក្នុង អ.វ.ត.ក នេះ។ ជាដំបូងខ្ញុំបាទសូមជម្រាបសួរថា ពាក់ព័ន្ធនឹងអ្វីដែលនិស្សិតយើងបានទៅស្រុកបារាំងនោះ ហើយដែលបានថាបានចូលទៅក្នុង ហៅថា បក្សៗ កុម្មុយនីស្តបារាំង ហើយក្រោយមកទៀតបានបង្កើតនូវអ្វីដែលជាបក្សខ្លួនឯង។ ខ្ញុំចង់ជម្រាបសួរថានៅក្នុងនុំង គឺគេបានលើកឡើងហៅថា វង់មាក្ស-ឡេនីន។ ចំណុចទី១ ខ្ញុំចង់សួរថា តើនិស្សិតដែលទៅស្រុកបារាំងនោះ សុទ្ធតែបានចូលចលនានេះជាសម្ងាត់ ឬមួយយ៉ាងម៉េច?

**លោក អុង ថុងហឿង៖**

**ឆ៖** បាទ ខ្ញុំសូមអរគុណ ហើយខ្ញុំសូមជម្រាបលោកប្រធាន និងលោកតំណាងតុលាការទាំងអស់ ហើយនិងបងប្អូនជនជាតិរួមជាតិកម្ពុជាទាំងមូល។ មុននឹងឆ្លើយសំណួរដ៏មានសារៈសំខាន់នេះ ខ្ញុំសូមបកថយក្រោយឡើងវិញ បើលោកអនុញ្ញាតនិយាយពីប្រវត្តិនៃនិស្សិតកម្ពុជា និស្សិតខ្មែរនៅប្រទេសបារាំង។ គឺដូចលោក អស់លោកជ្រាបហើយ ប្រទេសកម្ពុជាធ្លាប់ជាអាណានិគមនិយមប្រទេស

បារាំង ហើយជាមួយគ្នានេះ ការសិក្សាធិការរបស់ប្រទេសជាតិយើងកាលពីជំនាន់បារាំង មិនសូវមានការលូតលាស់ទេ ហើយអ្នកចេះរៀនសូត្រខ្មែរមួយចំនួនដែលរៀនវិជ្ជា គឺត្រូវភាគច្រើនទៅរៀននៅប្រទេសវៀតណាម ជាពិសេសនៅហាណូយ។

[០៩:១២:១២]

តែដល់ក្រោយសង្គ្រាមលោកលើកទី២ បងប្អូនយើងមួយចំនួន ជាបងចាស់ៗ ដែលគាត់ ឥឡូវគាត់ចាស់ៗ។ បើនៅជំនាន់នោះគឺជាលើកទី១ដែលខ្មែរយើងទៅរៀនបានជិះកប៉ាល់ គឺសម័យនោះអត់ទាន់មានកប៉ាល់ហោះអីរហ័សដូចសព្វថ្ងៃនេះទេ គឺជិះកប៉ាល់ពីព្រៃនគរ ហើយកាត់តាមសមុទ្ររហូតចតទៅក្រុងម៉ាកសី នៅប្រទេសបារាំង គឺបើគិតទៅ គឺថាដំណើរនេះយ៉ាងតិចក៏មួយខែដែរ។ គឺថានេះជាលើកដំបូងដែលខ្មែរយើងទៅ -- បានទៅរៀននៅបរទេស។ ហើយខ្មែរទៅរៀននៅបរទេសនេះ គឺមានទិសដៅ មានចិត្តចង់ខិតខំយ៉ាងណា ដើម្បីមកខំរៀនចំណេះវិជ្ជាមកកសាងប្រទេសជាតិរបស់ខ្លួនវិញ។ នេះគឺជាគោលបំណងរបស់គេនីមួយៗ។ ហើយដល់ទៅៗ គឺថាជំនាន់នោះខ្មែរទាំងអស់នោះ គឺរួមគ្នាទាំងអស់ចង់បានឯករាជ្យពីប្រទេសបារាំង ហើយអត់មានគិតជានិន្នាការឆ្វេង ឬនិន្នាការស្តាំអីទេ គឺទាំងអស់គ្នា ទាំងកូន ព្រោះអ្នកបានរៀនសូត្រ យើងគួរបញ្ជាក់ដែលគឺថា សុទ្ធ ភាគច្រើនសុទ្ធតែកូនអ្នកធំ ជាកូនស្តេច ឬក៏ជាកូនអភិជន ឬក៏កូនអ្នកមានមុខងារធំ ទើបអាចមានលទ្ធភាពបញ្ជូនកូនចៅទៅរៀននៅសាលាបានជំនាន់នោះ។ ព្រោះកូនអ្នកស្រែ៨០ ឬ៩០ភាគរយ គ្នាគ្មាន -- មានតែសាលាវត្ត អត់មានសាលារៀនសូត្រដូចកូនអ្នកធំទេ។

[០៩:១៤:០០]

ហើយ ប៉ុន្តែទាំងអស់គ្នាមានគោលបំណងចង់បានឯករាជ្យពីប្រទេសបារាំង។ ខ្ញុំឆ្លើយលោក *អារូកា* -- លោកដែលមេធាវីត្រង់កន្លែងនេះថា ទាំងអស់គ្នាពេលនោះអត់មាននិន្នាការឆ្វេង ឬស្តាំអីទេ គឺទិសដៅតែមួយស្រឡាញ់ជាតិ ហើយចង់បានឯករាជ្យពីប្រទេសបារាំង -- ពីអាណានិគមនិយមបារាំង។ ដូច្នេះបានន័យថាយ៉ាងម៉េច បានន័យថា ដែលហៅថា គេហៅថា បារាំងគេហៅថា "មណ្ឌលមាក្ស-ឡេនីន" នោះ គឺមិនមែនខ្មែរយើងទូទៅទេ អាហ្នឹងបែកពីក្រោយមកទៀត។ ហេតុម៉េចបានបែកពីក្រោយមកទៀត ពីព្រោះដល់តស៊ូបន្តិចទៅ វាមានបញ្ហាពីរ។ មានទិន្នាការទី១ ថាតើតស៊ូនោះ ត្រូវដើរផ្លូវណាតស៊ូដើម្បីកែរចនាសម្ព័ន្ធសង្គម ឬក៏តស៊ូដើម្បីគ្រាន់តែឲ្យបារាំងចេញទៅ យើងនាំគ្នាជំនួសបារាំងទៅ។

[០៩:១៥:០០]

ហើយដូចអស់លោកជ្រាបស្រាប់ហើយនៅជំនាន់នោះ គឺពិភពលោកកំពុងតែមានការប្រយុទ្ធគ្នារវាងលោកសេរី និងលោកសង្គមនិយម ដែលគេហៅថាកុម្មុយនីស្ត។ មានពិភពពីរប្រឆាំងគ្នា។ ហើយនៅស្រុកបារាំងពេលនោះ ពួកកុម្មុយនីស្ត គេមានៗឥទ្ធិពលខ្លាំងនៅក្នុងសភាពការណ៍នយោបាយប្រទេសបារាំង គឺបើបោះឆ្នោត គេមានពី៣០យ៉ាងតិចទៅ៣០ទៅ៤០ភាគរយ ដូច្នេះគឺថាវាទម្ងន់ហ្នឹងខ្លាំង។ ហើយពិសេសនៅក្នុងមជ្ឈដ្ឋាននិស្សិត និងមជ្ឈដ្ឋានបញ្ញវន្ត។ ដូចជាអ្នកបញ្ញវន្តធំៗ ដូចជា ហ្សង់ប៉ូហ្សាក, អាល់បែកាមីស គឺថាអ្នកល្បីល្បាញ គឺជារួមគឺមាននិន្នាការឆ្វេងទាំងអស់។ គឺអ្នកមាននិន្នាការស្តាំមិនសូវមានទឹកមាត់ប្រៃទេ។ ដូច្នេះ -- ហើយនិស្សិតបងប្អូនយើងមួយចំនួន ដែលជាកូនអ្នកធំ ជារួមគឺកូនអ្នកធំ មិនជាកូនអ្នកធំទាំងអស់គ្នា ប៉ុន្តែជារួមជាកូនអ្នកធំ វាមាន -- វា យើងចេញពីសង្គមមួយ។ សង្គមរបស់យើង គឺជាសង្គមមួយដែលជាសង្គមអាណានិគម ហើយខួរក្បាលយើងជាខួរក្បាលដែលមានអាណានិគមពាក់កណ្តាល ហើយនិងទំនៀមទម្លាប់យើងពាក់កណ្តាល។ ដល់ទៅគឺថា ដល់ទៅស្រុកបារាំងពេលនោះគឺថាយុវជនយើងម្នាក់ៗជួបប្រទះនឹងទំនាស់ដែលថា តើធ្វើយ៉ាងម៉េចមកដល់នេះ ដោះស្រាយយ៉ាងម៉េច ដើម្បីរករូបមន្តដើម្បីកសាង ដើម្បីយកទៅជួយប្រទេសជាតិបាទ។

[០៩:១៦:៥៨]

ហើយដូច្នេះ ក៏បកស្រាយជាសភាពនយោបាយ វាចែកជាពីរ។ មាននិន្នាការមួយ ខ្ញុំថានិន្នាការស្តាំ វង់ក្រចកទៅ គឺថាគាត់ក៏ ដូចជាបងៗមួយចំនួន គាត់និន្នាការដូចថាបារាំងហៅថា*ម៉ូឌឺរេ* គឺថាមាននិន្នាការទន់ គឺថាគាត់ចង់យើង -- គាត់កុំឲ្យមានការខ្លាំង យើងតស៊ូសម្រុះសម្រួលជាមួយអាណានិគម យើងធ្វើម៉េចបន្តកសាងប្រជាធិបតេយ្យបន្តិចម្តងៗ។ និន្នាការមួយទៀតក៏ចាប់មានឥទ្ធពលពីខាងឆ្វេង ជាពិសេសពីខាងដូចខ្ញុំបាននិយាយអំមិញ ពីខាងបារាំង ជាពិសេសពីបក្សកុម្មុយនីស្តបារាំងក៏ពួកនោះ ក៏ -- ហើយជាពិសេសនៅក្នុងប្រទេសនៅអាស៊ីយើងនេះ នៅឥណ្ឌូចិនយើងនេះ គឺកុំភ្លេចថា ពេលនោះសង្គ្រាមប្រឆាំងនឹងអាណានិគមបារាំងបានឈានទៅមួយជំហានទៀត ដោយមានការតស៊ូដោយលោកហូជីមីញ ហើយនៅប្រទេសចិនមាន ម៉ៅសេទុង គាត់បានឈ្នះ បដិវត្តន៍ចិនបានឈ្នះ។ ដូច្នេះបដិវត្តន៍ចិនឈ្នះ វាធ្វើឲ្យភូមិសាស្រ្តនយោបាយនៅអាស៊ីយើង វាដូចឥទ្ធិពលខាងកុម្មុយនីស្តហ្នឹងវាខ្លាំង ហើយនៅប្រទេសបារាំងក៏ខ្លាំងផង។ ឥទ្ធិពលកុម្មុយនីស្តខាងឆ្វេងនៅបារាំងផងនោះ ក៏និស្សិតយើងមួយចំនួនមានឥទ្ធិពល យកឥទ្ធិពលដែលនេះមកនៅក្នុងឥរិយាបថនយោបាយរបស់បងប្អូនយើងនីមួយៗ។ ហើយដូច្នេះ ក្នុងនិស្សិតមួយចំនួននោះ ក៏មាន -- ដោយសារមានការគាំទ្រពីនិស្សិតកុម្មុយនីស្តបារាំងផងនោះ

ក៏ដាក់ចិត្ត ក៏នាំគ្នាធ្វើ -- បារាំងហៅថា *ស៊ែក* ម៉ាក្ស-ឡេនីន មណ្ឌល -- ខ្ញុំមិនដឹងជាប្រែជាខ្មែរហៅម៉េចទេ ប៉ុន្តែថាគេហៅ *ស៊ែក* ម៉ាក្ស-ឡេនីន ប៉ុន្តែនេះជាការសម្ងាត់ ហើយមានបងៗមួយចំនួនធ្វើសម្រេចចិត្តធ្វើយ៉ាងនេះដូច្នេះ។ នេះខ្ញុំសូមឆ្លើយប៉ុណ្ណឹងសិនបាទ។

[០៩:១៩:១៦]

**ស៖** សូមអរគុណបាទ។ ដោយសារនេះវាជាបរិបទប្រវត្តិសាស្ត្រទាល់តែយើងលើក មិនមែនថាលើកតែមួយម៉ាត់វាបានយល់ទេ។ អ៊ីចឹង ខ្ញុំចង់ជម្រាបសួរបន្តទៀតថា កាលសម័យនោះគឺមាននិស្សិតខ្មែរយើងជាច្រើនដែលបានអញ្ជើញទៅរៀនសូត្រនៅស្រុកបារាំង។ ចុះនៅ -- ខ្ញុំចង់ដឹងថាតើទំនាក់ទំនងរវាងនិស្សិតខ្មែរយើងជាមួយបក្សកុម្មុយនីស្តបារាំងហ្នឹងយ៉ាងម៉េចដែរ? ហើយកត្តាអីខ្លះដែលជំរុញ ដែលធ្វើឱ្យគាត់ហ្នឹង អាចថាយល់អំពីបញ្ហាបក្សកុម្មុយនីស្តហ្នឹងបានចូលទៅទំនាក់ទំនងជាមួយបក្សកុម្មុយនីស្តបារាំងហ្នឹង ដើម្បីធ្វើការស្រោចស្រង់ជាតិ ឬមួយយ៉ាងម៉េច ពេលនោះបាទ?

[០៩:២០:២១]

**ឆ៖** នេះជា -- សំណួរទាំងអស់នេះវាមានសារៈសំខាន់ ហើយជាសំណួរទាក់ទងប្រវត្តិសាស្ត្ររបស់ជាតិយើង។ ហើយជា -- វាមានទំនាក់ទំនងជាមួយការវិវត្តន៍របស់ជាតិយើងសព្វថ្ងៃនេះ។ ហើយខ្ញុំសូមអរគុណនឹងសំណួរនេះ វាមានសារៈសំខាន់ជាគន្លឹះរបស់ប្រទេសកម្ពុជាយើង។ បើនិយាយ -- ហើយខ្ញុំមិនដឹងជាយើងអាចមានពេលពិភាក្សាគ្នាដល់កម្រិតមាណ ប៉ុន្តែវាមានសារៈសំខាន់ត្រង់កន្លែងនេះត្រង់កន្លែងថា ទិសដៅធំដែលខ្ញុំលើកឡើងវិញ គឺនិស្សិតទាំងអស់ដែលៗខ្ញុំថាជាបងៗយើង ខ្ញុំមិនប្រកាន់ព្រោះថាមុននឹងគាត់ទៅជាឧក្រិដ្ឋជន ឬក៏ទៅជាស្អី គឺវាមានទិសដៅល្អដូចគ្នា ល្អដើម្បីចង់ឱ្យជាតិអង្គរហ្នឹងបានរុងរឿង ថ្កុំថ្កើង ដើម្បីកុំឱ្យវាបាត់ទឹកដីរបស់ខ្លួនដែលមួយសតវត្សរ៍ហើយមួយសតវត្សរ៍ទៀតវាចេះតែបាត់បន្តិចម្តងៗ។ ដូច្នេះ តើធ្វើយ៉ាងម៉េចឱ្យជាតិកម្ពុជាហ្នឹងបានគង់វង្សតទៅទៀត ឱ្យរីកចម្រើនតទៅទៀត កុំឱ្យគេជិតខាងហ្នឹងលេបទឹកដីរបស់ខ្លួនបាន។ អាហ្នឹងជាបញ្ហាគន្លឹះដែលខ្មែរម្នាក់ៗបានរៀនសូត្រហើយ គឺចោទបញ្ហាហ្នឹង។ ចោទបញ្ហាហ្នឹង គឺបញ្ហា គឺម្នាក់ៗតាំងពីដឹងក្តីមកថាធ្វើម៉េចកុំឱ្យជាតិអញ្ជរលាយ។ អាហ្នឹងជាបញ្ហាគន្លឹះរបស់ខ្មែរ។

[០៩:២២:០៧]

ប៉ុន្តែក្នុងការដោះស្រាយខ្ញុំសូមនិយាយជាលោកទស្សនៈបន្តិចគឺថា ក្នុងការដោះស្រាយវាមានបញ្ហាត្រង់ហ្នឹង -- អាហ្នឹងសូមទោសអាហ្នឹងជា -- ខ្ញុំមិនបានរស់នៅជាមួយបងៗ ប៉ុន្តែខ្ញុំពិនិត្យក្រោយមក

គឺថាវាបញ្ហាអ៉ីចេះ។ បញ្ហាថាដើម្បីឲ្យជាតិយើងបានគង់វង្ស តើយើងធ្វើយ៉ាងម៉េច? មួយម៉ាត់ថាយើងធ្វើការកែទម្រង់តាមហើយ តស៊ូតាមមាគ៌ាមុ -- បារាំងហៅថា ម៉ូឌឺរេ មួយទៀតហៅមាគ៌ាឆ្វេងនិយម។ ហើយនិយាយម្តងទៀតគឺ មាគ៌ាឆ្វេងនិយម ជាមាគ៌ាដែលពិភពលោក ពេលនោះ ចលនាតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំងវាខ្ទរខ្ទារពេញសាកលលោកទាំងអស់ គឺថាប្រទេសណាតតិយលោកទាំងអស់បាទ។

**ស៖** ខ្ញុំៗ--

[០៩:២៣:០៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីព្យាយាមចូលទៅក្នុង -- ពាក់ព័ន្ធនឹងអង្គហេតុដែលចោទប្រកាន់ក្នុងដីកាដំណោះស្រាយ។ ទីនេះមិនមែនឲ្យនិទានពីរឿងប្រវត្តិសាស្ត្រទេ។ ប្រវត្តិដែលពាក់ព័ន្ធទៅនឹងក្នុងដីកាដំណោះស្រាយគឺប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាតែប៉ុណ្ណោះ ក្រៅពីនោះគឺជាធាតុផ្សំដែលចោទប្រកាន់ទៅលើជនជាប់ចោទនិងភស្តុតាងនានាដែលមានការចោទប្រកាន់ទៅលើជនជាប់ចោទ នៅក្នុងក្របខ័ណ្ឌវិសាលភាពនៃអង្គហេតុដែលបានកំណត់សម្រាប់ធ្វើសវនាការ។ មិនមែនសុំពេលវេលាទៅហើយប្រើប្រាស់ពេលវេលាហ្នឹងវាមិនមានបានរួមវិភាគទានបន្តិចបន្តួចនៅក្នុងការស្វែងរកការពិតនោះទេ។ ការតាំងសំណួរត្រូវមានការរៀបចំគិតគូរឲ្យមែនទែននៅលើចម្លើយ ដែលតបមកវិញគួរតែរួមវិភាគទានស្វែងរកការពិតនៅក្នុងរឿងក្តីនេះ។

[០៩:២៤:០៥]

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ខ្ញុំសូមបន្តប្រធានបទនេះបន្តិច។ ពាក់ព័ន្ធបរិបទនេះដែរថា តើអ្វីដែលគោលនយោបាយរបស់បក្សកុម្មុយនីស្តហ្នឹងវាយ៉ាងម៉េចដែលធ្វើឲ្យនិស្សិតយើងហ្នឹងចូលរួមជា -- បានន័យថាស្ម័គ្រចិត្តចូលរួមជាកម្លាំងហ្នឹង តើគោលនយោបាយគេហ្នឹងដែលធំៗហ្នឹងអ្វីខ្លះ? ហើយដែលពាក់ព័ន្ធនឹងបុគ្គលភាព ហើយវាពាក់ព័ន្ធនឹងកម្មសិទ្ធិនៃបុគ្គលដែរអត់ គោលនយោបាយរបស់ធំៗរបស់បក្សម៉ាក្ស-ឡេនីនបាទ?

[០៩:២៥:១២]

**លោក អ៊ុង ចុងហៀង៖**

**ឆ៖** បាទ សូមទោស ខ្ញុំសូមបញ្ជាក់សំណួរបន្តិចបាទ។ ខ្ញុំបក្សឡេនីន ខ្ញុំមិនមែនក្នុង -- តាមខ្ញុំក្តាប់បាន និស្សិតពេលនោះអត់ទាន់បង្កើតជាបក្ស ប៉ុន្តែជាក្រុម ជាក្រុមឡេនីន។ បើលោក -- ប៉ុន្តែខ្ញុំចង់និយាយសរុប ដើម្បីកុំឲ្យវែងឆ្ងាយត្រង់កន្លែងនេះ ត្រង់កន្លែងថា ខ្ញុំចង់និយាយថា ម៉េច ហេតុម៉េច មូលហេតុអី អ្វីដែលធ្វើឲ្យនិស្សិតខ្មែរទាំងនោះមួយចំនួនជ្រើសរើសមាគ៌ាឆ្វេងនិយម? បាទ អ៊ីចឹងខ្ញុំឆ្លើយរឿងហ្នឹងបានទេលោក?

**ស៖** បាទ សូមខ្លីបានហើយ។

**ឆ៖** ពីព្រោះថា បើយើងជាប្រទេស -- ជាយុវជនមកពីប្រទេស ខ្ញុំនិយាយនេះជាការពិសោធរបស់ខ្ញុំដែរ ពីប្រទេសតតិយលោក យើងទៅដល់យើងជួបប្រទះនឹងយុវជនចម្រើននិយម ហើយយុវជនចម្រើននិយមភាគច្រើនវាមាន ដូចថា ដូចជាយោគយល់យើង គាំទ្រយើង ដូច្នេះវាធ្វើឲ្យមិត្តភាពរវាងនិស្សិតចម្រើននិយម និងពីតតិយលោក និង ហើយនិងនិស្សិតចម្រើននិយមនៅប្រទេសបារាំងភាគច្រើនជាមាននិន្នាការជាកុម្មុយនីស្ត ហើយអានេះជាមូលហេតុធំចម្បង។

[០៩:២៦:៣៨]

មូលហេតុទី២ ដែលឲ្យខ្មែរ និស្សិតតតិយលោក មិនមែនតែខ្មែរ គឺនិស្សិតទាំងអស់ជ្រើសរើសមាគ៌ាឆ្វេងនិយម ពីព្រោះទី២ មាគ៌ាឆ្វេងនិយមវាមានកាលជំនាន់នោះវាមានប្រសិទ្ធភាព ដូចថាបដិវត្តន៍នៅស្រុកចិន បដិវត្តន៍នៅប្រទេសផ្សេងៗ។ ដូច្នោះវាមានឥទ្ធិពលអ៊ីចឹងបាទ។ បាទខ្ញុំសូមសរុប ពីព្រោះនិយាយទៅវាវែងឆ្ងាយពេក។

**ស៖** បាទៗ អរគុណ។ ឥឡូវខ្ញុំចូលមួយចំណុចទៀត ពាក់ព័ន្ធនឹងការរៀបចំដំណើរវិលត្រឡប់របស់លោក ហើយនិងដូចជានិស្សិតទាំងឡាយដែលមកស្រុកខ្មែរវិញ ថាតើមុននឹងយើងរៀបចំដណើរដែលអញ្ជើញមកវិញហ្នឹង ថាតើការទទួលនូវព័ត៌មានអ្វីខ្លះ ដែលពីប្រទេសខ្មែរយើងផ្តល់ទៅខាងនិស្សិតហ្នឹង ធ្វើឲ្យនិស្សិតហ្នឹងយល់ថា វាជាការត្រឹមត្រូវ ហើយចូលមកស្រុកខ្មែរវិញ?

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរនេះ ហើយខ្ញុំសូមអធ្យាស្រ័យ ខ្ញុំ -- ជាសំណួរដែលខ្ញុំតែងតែចោទបញ្ហាខ្លួនឯង ហើយបើតាមខ្ញុំយល់គឺព័ត៌មានដែលយើងទទួលបាន -- បើយើងមានជំនឿអ្វីមួយហើយ ដូចពួកយើងខ្ញុំពេលនោះ យើងមានជំនឿលើអ្វីមួយ ដូចយើង -- គេហៅ បារាំងហៅ “ស៊ិច” បើយើងចូលនិកាយអីមួយ គឺថា បើសិនជាឧបមាថា សារព័ត៌មាននៅបស្ចិមប្រទេសសរសេរជាក់ស្តែងយ៉ាងណា

ក៏ដោយក៏យើងអត់ជឿដែរ។ ពីព្រោះថាយើងជឿស្អីមួយ យើងជឿលើបងៗយើង យើងជឿលោក ខៀវ សំផន យើងជឿលោក ហ៊ូ នឹម យើងជឿ យើងទុកថាគាត់ហ្នឹងដូចជាៗព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ អ៊ីចឹង។ ដូចថាអ្នក ដូចថា -- ដូច្នេះយើងពួកបរទេសនិយាយថាយ៉ាងម៉េចក៏យើងៗអត់ជឿ។ យើងចូលចិត្តស្តាប់តែអ្វីដែលវា វាដូចថា ជាជំនឿ -- ដើម្បីវាត្រឹមត្រូវតាមទឹកចិត្តរបស់យើងពេលនោះដែលជឿ។ បាទ អាហ្នឹងខ្ញុំចង់និយាយ។

[០៩:២៩:១១]

ហើយព័ត៌មានដែលយើងបាននោះ គឺព័ត៌មានដែលយើងទទួលតាមរយៈខាងលោក អៀង សារី ហ្នឹងគាត់ផ្សព្វផ្សាយ ហើយយើងចាំតែជឿ យើងចេះតែជឿតាមគាត់ទៅ ហើយយើង -- អាកាសែតអីឡឺហ្វីហ្ការ៉ូ កាសែតញូវយ៉កថែមស៍ អីជួនកាលនិយាយអីៗហ្នឹង ថា អើ អាហ្នឹងជារបស់ចក្រពត្តិ យើង -- អញអត់ជឿ អញជឿតែផងបងៗអញ។ អ៊ីចឹងខ្ញុំសរុបសេចក្តីវាប៉ុណ្ណឹងបាទ។

**សៈ** បាទ អរគុណ។ ហើយខ្ញុំចង់ដឹងចំណុចដែលថា យើងបានរៀបចំដំណើរវិលត្រឡប់មកប្រទេសយើងវិញ ហើយនៅពេលនោះហេតុអីបានជាកាលវិលដំណើររបស់និស្សិតបញ្ញវន្ត ឬមួយមន្ត្រីរាជការ ដែលនៅបរទេសហ្នឹងវិលមកចូលទៅតាមប៉េកាំងទាំងអស់តើលោកដឹងចំណុចនេះដែរឬមួយក៏ម៉េច?

**ឆៈ** សភាពការណ៍ពេលនោះ គឺថាការហោះហើរពី -- ចូលប្រទេសកម្ពុជាត្រូវតែកាត់តាមប៉េកាំងទាំងអស់បាទ។ អត់មានៗកប៉ាល់ហោះណា ប្រទេសណាសផ្សេងទៀតពីចិន ពីប្រទេសចិនប្រជាមានិតទេ គឺដូច្នេះទាំងអស់គ្នាត្រូវតែជិះមកដល់ប៉េកាំង ហើយពីប៉េកាំងចូលប្រទេសកម្ពុជា។ អាហ្នឹងទាំង -- ព្រោះស្រុកខ្មែរពេលនេះជា វាមានការ -- វាឯកោ គឺមានផ្លូវច្រកចេញតែតាមប៉េកាំងមួយទេបាទ។

[០៩:៣១:០៥]

**សៈ** បាទ អរគុណ។ ចុះនៅពេលដែលយើងបានទៅដល់ខាង ទៅដល់ប៉េកាំង តើនៅប៉េកាំងហ្នឹងគេដកហូត និយាយចំគឺថា ទៅដល់នុ៎ងគេមានដកហូតអីវ៉ែអីវ៉ាន់របស់យើងដែរអត់ទេ?

**ឆៈ** បាទ អត់មានទេ។ ពិតមែនតែប៉េកាំងពេលនោះជាសម័យបដិវត្តន៍វប្បធម៌អី ប៉ុន្តែយើងមិនគេអត់មានធ្វើអីយើងទេ។

**សៈ** បាទ អរគុណ។ ចុះពេលដែលយើងជិះយន្តហោះមក ពេលដំណើរជិះយន្តហោះភ្នំពេញ

តើការដែលសាហ៊ុយសូដាអីគឺយើងចេញខ្លួនឯង ឬមួយយ៉ាងម៉េច?

**ឆ៖** មិន សូម្បីតែយើងចេញខ្លួនឯង ហើយសល់លុយប៉ុន្មានយើងប្រគល់ឲ្យអង្គការទាំងអស់ ដើម្បីទិញត្រាក់ទ័រ ដើម្បីកសាងប្រទេស។

[០៩:៣២:២០]

**ស៖** បាទ អរគុណ។ តើនៅពេលដែលយើងមកដល់ភ្នំពេញ ពេលមកដល់ភ្នំពេញគេបានបញ្ជូនអ្នកទាំងអស់នុ៎ងទៅៗនៅចំណុចណាបាទ? ហើយបានធ្វើអ្វីខ្លះនៅទីនោះ?

**ឆ៖** យើងចុះពីកប៉ាល់ហោះ ខ្ញុំនិយាយសរុប គេដឹកយើងមកចូលមន្ទីរក-១៥ ហើយគេចាប់ៗឆែកឆេរវ៉ាលីយើង គេដកហូតសៀវភៅ វិទ្យុ ឬក៏ម៉ាស៊ីនថតអីៗ យកទាំងអស់ទៅ ហើយគេៗឲ្យយើងនៅជាមួយបងប្អូនយើង ហើយគេមកនៅជាបន្តបន្ទាប់ហ្នឹងបាទ។ អានេះខ្ញុំនិយាយតែភាគច្រើន ពីព្រោះខ្ញុំចង់បញ្ជាក់ដែរ មានមួយចំនួនទៀតអត់ចូល ក-១៥ ទេ ដូចៗមួយចំនួនដូច ទូត ឬក៏មិត្តភក្តិខ្ញុំខ្លះគេដូចអ៊ុក កេត ដូចអីៗគេយកទៅមិនដឹងទៅកន្លែងណា ប៉ុន្តែក្រោយមកឃើញឈ្មោះនៅទួលស្លែង។ អាហ្នឹងជារឿងមួយទៀតដែលខ្ញុំអត់ដឹងទេបាទ។

**ស៖** បាទ តើនៅពេលដែលមកដល់កន្លែងដែលយើងរស់នៅហើយ ហើយគេថាតែងតែមកប្រជុំមកអប់រំថា ឲ្យយើងហ្នឹងកសាងខ្លួនបាទ តើអាក្រោយ -- ការកសាងខ្លួនហ្នឹង វាជាលក្ខណ: -- លក្ខខណ្ឌច្បាស់លាស់ឲ្យយើងកសាងខ្លួនទៅជាកសិករ ទៅជាកម្មករ ឬមួយកសាងខ្លួនហ្នឹងទៅជាកម្មាភិបាលរបស់ខ្មែរក្រហម ឬមួយយ៉ាងម៉េច?

[០៩:៣៥:១០]

**ឆ៖** អាសំណួរសំខាន់ ប៉ុន្តែខ្ញុំសូមនិយាយដោយសង្ខេប។ ទី១ អង្កាល់យើងមកដល់ យើងខិតខំរៀនសូត្រ ដើម្បីកសាងខ្លួនៗ ដើម្បីឲ្យដូចប្រជាជន កម្មករ កសិករ។ ហើយតើកសាងខ្លួន ទាំងអស់នេះយើងកសាងខ្លួនហើយ ទើបយើងសង្ឃឹមថា អង្គការយកយើងទៅធ្វើការងារតាម សមាទិដ្ឋិ សមត្ថកិច្ចរបស់យើង។ អានេះដែល -- នេះជាពិសោធន៍របស់ខ្ញុំ ហើយតាមខ្ញុំយល់ជា ជាដូចថាទឹកចិត្តរបស់បងប្អូនយើងទូទៅ។ យើងអត់បាននឹកឃើញថាវាទៅជាកម្មាភិបាលអី អង្កាល់ពេលនោះ ដូចជាវាគ្រាន់តែគិតអីចឹង។ ប៉ុន្តែដល់គិតដែលដល់ គិតឡើងវិញទៅ នៅបានមួយរយ:ទៅ ឃើញថាវាកសាងខ្លួន ធ្វើទិតៀនស្វ័យទិតៀន តែយើងអត់មានសិទ្ធិអីនឹងទិតៀនខ្លួនយើង យើងរើបន្ទាប់បង្អួស -- បន្ទុះបង្អាប់ខ្លួនយើង យើងបន្ទុះបង្អាប់មិត្តភក្តិយើងដែលមកជាមួយគ្នា ប៉ុន្តែយើងអត់មានសិទ្ធិទិតៀនអ្នកណាមួយដែលតំណាង

អង្គការទេ។ ដូច្នេះបើពេលណាយើងមិនសប្បាយចិត្ត ឬក៏អង្គការធ្វើអ៊ីចេះ ព្រោះបើជាទ្រឹស្ដីអង្គការ គេថា ទិតៀនទាំងអស់គ្នា។ ប៉ុន្តែបើយើងៗ -- គេឲ្យយើងយល់ គេថា អ្នកតំណាងអង្គការគឺជាសច្ចធម៌។ អង្គការបានន័យថា សច្ចធម៌ អង្គការបានន័យថា ការពិត។ ដូច្នេះបើប្រធានអង្គកានោះគេធ្វើអីយើងក៏ដោយ ក៏យើងនៅតែអត់អាចមានសិទ្ធិទិតៀនគេទេបាទ។

[០៩:៣៦:៥៨]

**ស៖** អរគុណច្រើន។ នៅចំណុចមួយទៀត ថានៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើលោកបានដឹងទេថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នោះថាតើដឹងព័ត៌មានពីប្រទេសកម្ពុជាហ្នឹងតាមមធ្យោបាយណាខ្លះ ដែលលោកបានដឹងនោះបាទ?

**ឆ៖** ខ្ញុំបានដឹងដោយអង្គាល់ហ្នឹង ខ្ញុំជិះ១ឡានជាមួយមិត្តភក្តិម្នាក់នៅលើស្ពានស្រុកបារាំង ស្ពានមីរ៉ាបូ ជាឈ្មោះ។ អ៊ីចឹងហើយដល់ឮសួរថា ជម្លៀសប្រជាជនពីភ្នំពេញ ប្រតិកម្មមិត្តដែលអ្នកបើកកប៉ាល់ -- អ៎! អ្នកបើក -- ដែលកាន់ចង្កូតឡានហ្នឹងប្រាប់ខ្ញុំ *(ឮមិនច្បាស់)* "យើស! អាចក្រពត្តិនិយាយផ្ដេសផ្ដាសទៀតហើយ។ នរណាជម្លៀសប្រជាជនចេញពីភ្នំពេញអ៊ីចឹង"។ អានេះដូចថាហ្នឹងព្រឹត្តិការណ៍មុនដំបូង ហើយដល់ហើយទៅបានគេធ្វើការងារសតិអារម្មណ៍ ជឿគេវិញទៅ។ ប៉ុន្តែព្រឹត្តិការណ៍មុនដំបូង អត់ជឿទេបាទ។

**ស៖** អ៊ីចេះចំណុចហ្នឹងវាអ៊ីចេះទេ ថាពេលដែលបែក៧៥ភ្លាម យើងទទួលបានព័ត៌មានហ្នឹង ថាតាមវិទ្យុចុះ។ ចុះផ្នែកមួយចំនួនទៀត ដូចថាផ្នែក កាសែត ផ្នែកព័ត៌មានផ្សេងៗ ថាតើវាញឹកញាប់ទេ គេផ្សាយហ្នឹងថា ការជម្លៀសហ្នឹងវាប៉ះពាល់អ៊ីចេះៗ ហើយយើងអត់ជឿមែន ប៉ុន្តែតើព័ត៌មានទាំងអស់ហ្នឹងធ្វើឲ្យយើងបានន័យថា ដឹងហើយដឹងទៀត វាស្រគាត្រចៀកដែរឬអត់បាទ?

[០៩:៣៩:០៣]

**ឆ៖** យើងបានដឹងពេលហ្នឹង ប៉ុន្តែយើងអត់ដូចថា យើងមិនឃើញការជាក់ស្ដែងនៅៗ -- យើងមិនឃើញការជាក់ស្ដែងដូចបងប្អូនយើងដែលវេទនានៅក្នុងស្រុកទេ បាទ យើងនៅឆ្ងាយឯណោះ យើងគិត -- យើងវាមានទស្សនៈផ្សេង។ ការជាក់ស្ដែងមួយ អាទស្សនៈនៅអឺរ៉ុបនោះផ្សេងពេលហ្នឹង។ ប៉ុន្តែសារព័ត៌មានគេចាប់ សារព័ត៌មាន ជាពិសេសសារព័ត៌មានអន្តរជាតិគេចាប់និយាយច្រើនដែរ។ ប៉ុន្តែយើង ដូចខ្ញុំជម្រាបអំមិញ យើងៗជឿស៊ប់លើអីមួយហើយ យើងមិនចូលចិត្តស្ដាប់ស្អីដែលវាផ្ទុយនឹងការយើងយល់ទេបាទ។

[០៩:៣៩:៤៩]

**ស៖** បាទ អរគុណ។ កាលពីម្សិលមិញ គឺលោកបាននិយាយពីការតស៊ូវណ្ណៈ ដែលការតស៊ូវណ្ណៈនេះវាកាន់តែស្រួចស្រាល់ និងការចាត់ជាសត្រូវក្នុងខ្លួន បានន័យថា ការកម្ចាត់សត្រូវក្នុងខ្លួន។ កាលដែលលោកធ្លាប់រស់នៅបឹងត្របែក តើធ្លាប់មានករណីដែលមានបុគ្គលណាត្រូវបានគេដាក់ទណ្ឌកម្ម ឬដាក់ទោសដោយសារនៅមាន បានន័យ នៅមានកម្អែលវណ្ណៈក្នុងខ្លួនដែរឬទេ? ហើយថាតើទណ្ឌ-កម្មហ្នឹងវាជាប្រភេទអ្វីបាទ?

[០៩:៤០:៤៧]

**ឆ៖** ទណ្ឌកម្មដែលវាមានការឈឺចាប់ជាងគេនោះ វាហួសពីទណ្ឌកម្ម -- អត់មានការវ៉ៃដំច្រំធាក់ទេ ខ្ញុំមិនដែលឃើញទេ តាំងពី -- មានតែបឹងត្របែកទេ កន្លែងផ្សេងៗទៀត ក៏ខ្ញុំមិនដែលឃើញដែរ។ ប៉ុន្តែវាជាទណ្ឌកម្មផ្លូវចិត្តលោក។ មនុស្សយើងគេមើលងាយណាស់ គេថា ពួកបងឯងហ្នឹងវាអត់បានការអីទេ ពួកបងឯងវា ធ្វើយ៉ាងម៉េចក៏កសាងខ្លួនអត់បានទេ ពួកបងឯងនេះជាចក្រពត្តិ ពួកបងឯងនេះ -- អាហ្នឹងវាធ្ងន់ៗណាស់អាហ្នឹង។

**ស៖** អរគុណ។ លោកបានលើកឡើងពីម្សិលមិញផងដែរ គឺថានៅបឹងត្របែកស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក អៀង សារី។ ថាតើលោកធ្លាប់ត្រូវបានគេប្រាប់ថា លោក អៀង សារី គ្រប់គ្រងត្របែកហ្នឹងពីពេលណាមកដែរ?

**ឆ៖** ខ្ញុំសូមបញ្ជាក់បន្តិច ដើម្បីបងប្អូនយល់។ ខ្ញុំរស់នៅបឹងត្របែកមានពីររយៈ។ ទី១ មុនយើងខ្ញុំទៅដីក្រហម ទៅជំរំដីក្រហម គឺក្នុងខែ -- ក្នុងមុនខែ ក្នុងអំឡុងខែ១២ ឆ្នាំ១៩៧៦។ អាហ្នឹងខ្ញុំមិនបានដឹងថា តើជំរំបឹងត្របែកហ្នឹងនៅក្រោមការគ្រប់គ្រងរបស់អ្នកណាទេបាទ។ ប៉ុន្តែដែលខ្ញុំនិយាយថា បឹងត្របែកដែលខ្ញុំត្រឡប់ពីដីក្រហមវិញ ២ខែមុនធ្លាក់ភ្នំពេញហ្នឹង គឺអាហ្នឹងបានខ្ញុំដឹងច្បាស់ថា បឹងត្របែកហ្នឹងនៅការគ្រប់គ្រង -- នៅក្រោម -- ស្ថិតនៅការគ្រប់គ្រងរបស់លោក អៀង សារី ព្រោះគាត់មកទទួលពួកយើងអី អាហ្នឹងដូចខ្ញុំបានអត្ថាធិប្បាយម្សិលមិញហើយបាទ។

[០៩:៤២:៥៩]

**ស៖** អរគុណបាទ។ ចំណុចមួយទៀត ដែលបានលើកឡើងថា លោក អៀង សារី គាត់មានឥទ្ធិពលខ្លាំងណាស់ ព្រោះថាប្រសិនបើសម្ដេចព្រះ សីហនុ ចង់ធ្វើអ្វីមួយ តែ អៀង សារី មិនចង់វិញ នោះអ្វីៗក៏មិនអាចធ្វើទៅបានដែរ។ នេះនៅក្នុងឯកសារ E3/97 លេខទំព័រទី៦ ជាភាសាខ្មែរបាទ។ តើ

ចំណុចនេះ លោកបានទទួលព័ត៌មានថាតើ -- ទទួលព័ត៌មានដឹងថា មានរឿងហ្នឹងកើតឡើងដែរអត់ទេ បាទ?

**ឆ៖** ខ្ញុំជឿថា ឯកសារនេះវាត្រឹមត្រូវ ព្រោះគ្រប់ពេលវេលាទាំងអស់ អៀង សារី គាត់តែងតែឲ្យគេដឹង តែងតែនិយាយគឺថា ឲ្យគេដឹងថា គាត់ហ្នឹងជាតំណាងប្រជាជន។ ហើយឥស្សរជនផ្សេងទៀតអាហ្នឹងគ្រាន់ជា មកគឺថា ដែលដូចថា បើយើងគិតឥឡូវ បើពាក្យបារាំង *លីហ្សឺយ៉ូអ៊ុយទីល* ដូចថា ជនភ្លើដែលគេត្រូវការបាទ។

[០៩:៤៤:៥៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ខ្ញុំសោកស្ដាយណាស់ដែលកាត់ផ្ដាច់លោកសាក្សីកំពុងតែឆ្លើយ ហើយនិងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ គឺអម្បាញ់មិញនេះមានការយោងទៅលើឯកសារមួយ ប៉ុន្តែយើងមិនមាន ERN ភាសាអង់គ្លេស ជាបារាំងនោះទេ។ អ៊ីចឹងតើលោកមេធាវីអាចផ្ដល់លេខ ERN ជាភាសាបារាំង និងជាភាសាអង់គ្លេសបានដែរឬទេ?

**លោក ឡោ ជុនធី៖**

បាទ ដោយសារតែកំពុងតែរក អ៊ីចឹងខ្ញុំសូមបន្តបន្តិច។

**សួរដោយលោក ឡោ ជុនធី៖**

ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិច ពាក់ព័ន្ធនឹងឯកសារ D141/1.2។ ERN ខ្មែរ 00659078 ហើយ ERN ពីរទៀតសូមចាំ អឺ -- ពួកនេះគឺជាសេចក្ដីប្រកាសរបស់និស្សិតកម្មសិក្សាការី មន្ត្រីរាជការយោធាអតីតជនភៀសខ្លួនដោយបង្ខំដែលរស់នៅអឺរ៉ុប និងអាមេរិក។ សូមបន្ថែមបន្តិចថា ERN អម្បាញ់មិញ ភាសាអង់គ្លេស 0028 -- អឺខ្ញុំសូមលើកសំណួរបន្តដូចថា សេចក្ដីប្រកាសហ្នឹង--

**ប្រធានអង្គជំនុំ៖**

ដូចនិយាយរឿងលេខ ERN អស់នៅអំមិញហ្នឹង លេខឯកសារ? ឲ្យកំបុតអ៊ីចឹង ហើយមានបញ្ហាអីទេលើការផ្ដល់លេខឯកសារ ជាភាសាអង់គ្លេស ហើយនិងភាសាបារាំង។ ឲ្យអស់ទេអំមិញនេះ

ឲ្យច្បាស់នៅ? មុននឹងបន្តទៀត សូមនិយាយឲ្យច្បាស់។ បើថារកមិនទាន់ឃើញទេ ប្រាប់ថារកមិនទាន់ឃើញទេ។ ចាំពេលណាបានរកឲ្យ ដើម្បីផ្តល់ជាលេខឯកសារជាភាសាបារាំង និងភាសាអង់គ្លេស។

[០៩:៤៩:០៣]

**លោក ឡោ ជុនធី៖**

សូមអរគុណលោកប្រធាន។ ឥឡូវខ្ញុំសូមជូនអម្បាញ់មិញដែលខ្ញុំយោងលេខឯកសារ E3 97 នោះ លេខ ERN អង់គ្លេសគឺ 00287100, លេខ ERN បារាំងគឺ 00241884 នេះគឺឯកសារ E3 97 -- E3/97 បាទ។

ហើយចំពោះឯកសារ D141/1.2 បន្តិចទៀតនឹងជូន ERN បារាំង និងខ្មែរបាទ -- បារាំង និងអង់គ្លេសបាទ។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

លោកប្រធាន ខ្ញុំៗសូមឲ្យបង្ហាញឯកសារនេះដែរ ហើយខ្ញុំមាន ខ្ញុំអាចជួយគាត់ ខ្ញុំមានលេខ ERN ខ្ញុំអាចជួយទៅគាត់បានបើសិនមានការអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីការពារក្តី យកមកជូនមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីពន្លឿននូវកិច្ចពិភាក្សានេះ! ហើយកិច្ចពិភាក្សានេះទំនងជាមិនមែនជាថ្ងៃចាប់ផ្តើមដំបូងទេ។ យើងធ្វើដូចជាជិតមួយឆ្នាំហើយ។

[០៩:៥១:៤៨]

**លោក ឡោ ជុនធី៖**

អរគុណបាទលោកមេធាវី។

ខ្ញុំបានរកឃើញលេខERN ឯកសារ D141/1.2 មានតែភាសាអង់គ្លេស។ សូមជូនអង់គ្លេសសិន 06657419, ភាសាបារាំងគឺ 00287879 ដល់ 00288154។ អរគុណ បាទដោយសារមានបញ្ហា--

**ប្រធានអង្គជំនុំ៖**

ដូចជាប្លែកបន្តិចនៅភាសាខ្មែរ និងភាសាអង់គ្លេសមានតែមួយទំព័រទេ ដល់ទៅភាសាបារាំងច្រើនទំព័រម្ល៉េះ?

**លោក ឡោ ជុនធី៖**

សូមទោសលោកប្រធាន អម្បាញ់មិញ ខ្ញុំទទួលខាងលោកមេធាវី។

[០៩:៥៣:៤៩]

**លោក អេនឌ្រូ អ៊ីនួហ្ស៊ី៖**

លោកប្រធានគឺ ERN -- ជាភាសាខ្មែរគឺមាននៅក្នុងសំណុំរឿងហើយ គឺមានឯកសារពី -- មានការដកបកប្រែទៅជាភាសាអង់គ្លេស។ ខ្ញុំសូមបញ្ជាក់ថា ជាភាសាខ្មែរ និងជាភាសាអង់គ្លេសគឺមាននៅក្នុងសំណុំរឿងហើយ។

**ប្រធានអង្គជំនុំ៖**

ប៉ុន្តែលោកមេធាវីបានបង្ហាញឯកសារដែលខ្លួនបានបង្ហាញនេះតែទំព័រជាភាសាខ្មែរ 00659078 និងជាភាសាអង់គ្លេស 06657419 បានន័យថាតែមួយទំព័រទេ។ ស្រាប់តែចេញជាភាសាបារាំងនេះវាច្រើនទំព័រ ពីលេខ ERN ប៉ុននេះ រហូតដល់ប៉ុននេះ។ ការបង្ហាញឯកសាររបៀបនេះ វាអត់ស៊ីសង្វាក់គ្នាទេ។ យ៉ាងច្រើនអាចខុសគ្នាមួយទំព័រ ទៅពីរទំព័រប៉ុណ្ណោះ។ ជាភាសាអង់គ្លេសមួយទំព័រ ទៅជាភាសាខ្មែរពីរទំព័រ ដោយសារទំហំអក្សរវាមានខ្នាតខុសគ្នា។

[០៩:៥៥:១០]

បានហើយលោកស្រីមេធាវី លោកស្រីអ្នកបង្កើតបញ្ហា ដូច្នេះមិនបាច់ធ្វើអន្តរាគមន៍អីទេ ទុកឲ្យមេធាវីដែលជាអ្នកមានភារកិច្ចក្នុងការលើកឯកសារមកដេញដោលជាអ្នកទទួលខុសត្រូវ។ យើងមិនអនុញ្ញាតឲ្យលោកស្រីនិយាយទេ ទុកលទ្ធភាពឲ្យមេធាវីដែលជាអ្នកសួរដេញដោលម្ចាស់ការក្នុងការស្វែងរក និងផ្ដល់លេខ ERN នៅក្នុងកិច្ចដំណើរការរបស់ខ្លួន។

**លោក ឡោ ជុនធី៖**

សូមទោសលោកប្រធាន ដោយសារការស្រាវជ្រាវរកលេខ ERN ខាងបារាំងហ្នឹងរកអត់ឃើញទេ គឺមានតែភាសាអង់គ្លេស។ តើ--

**ប្រធានអង្គជំនុំ៖**

លោកបន្តទៅមុខទៀត។ ហើយបើសិនជាលោកផ្អែកលើឯកសារ លោកត្រូវត្រៀមឱ្យហើយ គប្បីត្រៀមឱ្យហើយនូវលេខ ERN ទាំងបីភាសាដូចអ្វីដែលភាគីនានាបានធ្វើកន្លងមកជិតមួយឆ្នាំហើយ បើគិតទាំងសំណុំរឿង០១ បើគិតទាំង០២ ផងដូចជាយើងធ្វើនីតិវិធីនៃការដេញដោលរបៀបនេះច្រើនរយៈពេលច្រើនដែរហើយ។ មិនគួរមានបញ្ហានេះកើតឡើងទេ។

[០៩:៥៧:០០]

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ចំណុចនេះ ខ្ញុំគ្រាន់តែចង់សួរទៅលោកសាក្សីថានៅពេលដែលមុន ដែលយើងរៀបចំដំណើរចេញពីប៉ារីសនោះមានធ្វើសេចក្តីប្រកាសមួយដែរអត់ ហើយសេចក្តីប្រកាសហ្នឹងយើងមានការប្រជុំគ្នាយ៉ាងម៉េចដែលមុននឹងចេញសេចក្តីប្រកាសហ្នឹងបាទ? សូមអរគុណ។

**លោក អុង ហុងហឿង៖**

**ឆ៖** ជាទូទៅមុននឹងមកគឺថាសេចក្តីប្រកាសនេះវាចូលនៅក្នុងការតស៊ូចិត្តសាស្ត្រ ដើម្បីវ៉ៃព័ត៌មានចក្រពត្តិ និងអាណានិគម។ ហើយក្នុងពេលនោះ គេធ្វើសេចក្តីប្រកាសអត់មានប្រជុំគ្នាអីទេ គ្រាន់ថារៀបចេញអ្នកដែល -- អ្នកទទួលខុសត្រូវហ្នឹងគេធ្វើទៅ ប៉ុន្តែខ្ញុំមិនដឹងពីណាអ្នកធ្វើ គ្រាន់ដឹងថាជាអ្នកជិតស្និទ្ធជាមួយលោក អៀង សារី បាទ។

[០៩:៥៨:២៦]

**ស៖** លោកមានចាំដែរទេថា ក្នុងសេចក្តីប្រកាសហ្នឹងបានលើឡើងនូវចំណុចធំៗអីខ្លះដែរបាទ?

**ឆ៖** ចំណុចធំៗដែលខ្ញុំចាំជាងគេទី១ ពេលខ្ញុំមកហ្នឹងគឺថា ទី១ថាគឺថា បើសិនជា -- បើប្រសិនជាអង្គការបដិវត្តន៍ហ្នឹង វាព្រៃផ្សៃ ធ្វើបាបប្រជារាស្ត្រឯង ប្រទេសឯង ដូចសារព័ត៌មានចក្រពត្តិ និងអាណានិគមផ្សាយហ្នឹង ប្រជាពលរដ្ឋមិនគាំទ្រ ហើយក៏មិនអាចមានជ័យជម្នះបានដែរ។ អាហ្នឹងជាអាហ្នឹង ដែលខ្ញុំចាំជាងគេ។ អាហ្នឹងគឺថាក្នុងទិសដៅធំគឺ អ៊ីចឹង។ ហើយទី២ គឺថាបង្ហាញពីការតស៊ូនៅក្នុងប្រទេសហ្នឹងគឺវាកំពុងតែផុសផុល គឺអាហ្នឹងវាបញ្ហាសរុបសេចក្តីដែលខ្ញុំចាំមានប៉ុណ្ណឹង។ សូមទោស។

[០៩:៥៩:៥១]

**ស៖** ពេលដែលលោករស់នៅបឹងត្របែកហ្នឹង តើគេផ្តល់នូវសេរីភាព ឬមួយការទំនាក់ទំនងគ្នា

ហ្នឹង ក្នុងកម្រិតណាដែរ ឬមួយអត់មានទេបាទ?

**ឆ៖** ជាសរុប សេរីភាព ជាពាក្យដែលអត់មានសេរីភាព អត្ថន័យដែលយើងឲ្យក្នុងសង្គមធម្មតា។ វាអត់មាន -- អត់មានកន្លែងវានៅក្នុងមន្ទីរអប់រំទេ គ្រប់កន្លែងទាំងអស់បាទ។

**សៈ** សួរថាតើនៅពេលដែលរស់នៅ នៅក្នុងជំរំហ្នឹង តើកូនក្មេង តើគេប្រមូលទៅណាដែរបាទ?

**ឆ៖** ក្មេងៗគេប្រមូលឲ្យនៅម្តុំ គេធ្វើការងារឪពុកម្តាយ ហើយគេឲ្យហៅឪពុកម្តាយពួកមីងគេឈប់ឲ្យហៅម៉ែ ឬពុក ឬក៏ប៉ាៗអីតាមយើងសង្គមចាស់ហើយ។ ព្រោះទាំងអស់គ្នាជាកូនចៅរបស់អង្គការ។ ដូច្នេះវាអស់មានគ្រួសារ វាអស់មានដូចថាយើងហៅឪពុកម្តាយអីក្មេងៗ ប៉ុន្តែអង្កាល់ខ្ញុំនៅក-១៥ គឺខ្ញុំចាំ ក្មេងៗគេឲ្យស្បៀងច្រើនជាងពួកចាស់ៗ ព្រោះពេលខ្ញុំឮសួរក្មេងៗថា វាឃើញបានពួកចាស់ៗ វាថាបាយជ្រូក ប៉ុន្តែពេលបាយរបស់ពួកវាគ្រាន់បើជាង។ មិនមែនបានន័យថា វាគ្រាន់បើដូចយើងសព្វថ្ងៃទេ ប៉ុន្តែគ្រាន់បើជាងបាទ។

[១០:០២:00]

**សៈ** ចុះការបង្រៀនៗក្មេង តើមានការបង្រៀនក្មេងៗដែរ?

**ឆ៖** តាមខ្ញុំក្តាប់បាន តាមខ្ញុំឃើញ របបនាសម្ព័ន្ធដូចជា ហើយរបបនាសម្ព័ន្ធនៅក្នុងកម្ពុជាប្រជាធិបតេយ្យហ្នឹងវាអត់មាន -- គេហៅមានក្រសួងសិក្សាធិការ ប៉ុន្តែវាអត់មានទេបាទ។ ហើយនៅៗ -- ខ្ញុំមិនដឹងសហករណ៍យ៉ាងម៉េច ប៉ុន្តែនៅក្នុងមន្ទីរអប់រំអត់មានគេបង្រៀនឲ្យក្មេងហ្នឹងរៀនសូត្រអីប្រកបអីខ្លះអ៊ីចឹង ជាពិសេសធំៗ -- អ៊ូ! ក្មេងៗឮសួរតែវាច្រៀង "យើងខ្ញុំកុមារ ស្រឡាញ់អង្គការអត់មានព្រំដែន" ម៉្វៃៗខ្ញុំឮសួរតែអ៊ីចឹង វាច្រៀងតែបទដដែលៗហ្នឹង វាថា "យើងខ្ញុំអង្គការ ស្រឡាញ់អង្គការអត់មានព្រំដែន" មិនដឹងអីទៀត។ ប៉ុន្តែគ្រាន់ថា គេច្រៀង ឲ្យច្រៀងតែបទអ៊ីចឹង។ ប៉ុន្តែរៀនសូត្រអីឲ្យ រៀនមានម៉ាតេម៉េទិច មានចំណោទមានអីៗដូចខ្ញុំ ដូចអត់បានឃើញទេបាទ។ មានខ្លះទៅបង្រៀន -- ពេលខ្លះឃើញបង្រៀនឲ្យប្រកបឲ្យអីទេ ប៉ុន្តែឲ្យថាមានការសិក្សាស្រួលបួលអីអត់មានទេបាទ។ ផ្ទុយទៅវិញគេឲ្យក្មេងៗរៀនធ្វើកសិកម្ម ធ្វើស្អីៗ បោសទ្រុងជ្រូក ឬស្អីៗអ៊ីចឹងវាក្នុង -- អាហ្នឹងអ៊ីចឹងបាទ។

**សៈ** ចុះតើ ក្នុងមួយរយៈកាលដែលលោកបានរស់នៅនុំង មានជួបឃើញការរៀបអាពាហ៍ពិពាហ៍ដែរបាទ?

**ឆ៖** និយាយសរុប មិនមែនតែនៅក-១៥ ឬជំរំទេ។ ទី១ អ្នកមកបរទេសអត់មានសិទ្ធិរៀបចំការជាមួយបងប្អូននៅក្នុងស្រុកទេ។ គេចែកដាច់ ថាបើយើង -- បើមានយុវជនណាម្នាក់ ដូចថាពេលខ្លះ

ឃើញនារីណាមួយមក ដែលជាកម្មាភិបាល ឬក៏អ្នកគ្រប់គ្រង ឬអីមកឃើញអ៊ីចឹង ពេញចិត្តអី យើងអត់មានសិទ្ធិៗ រៀបចំអំពីមង្គលការជាមួយបងប្អូនមូលដ្ឋាន គឺ -- ហើយក្នុងដែលពេលខ្ញុំរស់នៅ គឺបងប្អូនយើងជារួម អ្នកមកបរទេសមានការជាមួយគ្នាបាទ។ អ្នកខ្លះៗនៅ ដូចមានមិត្តខ្ញុំខ្លះ រំភើបស្គាល់គ្នាចាំៗមកការនៅក្នុងស្រុក។ ស្គាល់គ្នាដូចថានៅបរទេសហើយ ត្រៀមខ្លួនមកការនៅក្នុងប្រទេសឯងហើយដល់មកស្រុកទៅ ក៏មានអ្នកខ្លះការអ៊ីចឹង រៀបចំមង្គលការអ៊ីចឹង រៀបចំមន្ទីរឲ្យគាត់ការអ៊ីចឹង ប៉ុន្តែមន្ទីរការហ្នឹងខ្ញុំបញ្ជាក់ឡើង នៅពេលខ្ញុំរស់នៅ៤ឆ្នាំហ្នឹង គេមិនដែលអនុញ្ញាតឲ្យបងប្អូនមកពីបរទេស មិត្តភក្តិខ្ញុំមកពីបរទេសរៀបមង្គលការជាមួយអ្នកមូលដ្ឋានទេ។

[១០:០៥:២១]

**ស៖** ប៉ុន្តែពេលៗដែលឃើញគេរៀបការហ្នឹង តើគេរៀបការយ៉ាងម៉េច តាមទំនៀមទម្លាប់ ឬមួយតែមួយគូ ឬមួយច្រើនយ៉ាងម៉េច?

**ឆ៖** ពេលរៀបការជាមួយមិត្តភក្តិខ្ញុំ ដូចថាខ្ញុំ -- តាមខ្ញុំដឹងមកគឺថា រៀបចំដូចម្តង ឬពីរដងទេ ខ្ញុំមិនចាំ ប៉ុន្តែមានមិត្ត ជាពិសេសមិត្តខ្ញុំម្នាក់ហ្នឹងគាត់រៀបការ ឃើញអង្គាល់ហ្នឹងដូចគ្រាន់តែជួបជុំគ្នាអ៊ីចឹង ការហៅ ដូចជាញ៉ាំអីបន្តិចបន្តួចជាមួយគ្នាអ៊ីចឹងទៅ ហើយអាហ្នឹងការទៅអាហ្នឹង។ ប៉ុន្តែដែលពិសោធន៍របស់ខ្ញុំឃើញ ដែលខ្ញុំឃើញបងប្អូនការដែលនៅ ខ្ញុំចេញពី ក-១៥ ហើយមុននឹងទៅដល់រោងចក្រគេទៅ គេហៅមន្ទីរកសិកម្មនោះ។ ខ្ញុំបានឃើញគេរៀបចំការ ដូចអង្គាល់ហ្នឹងឮសួរគេនិយាយ ប៉ុន្តែគេរៀបចំ គេឲ្យនាំពួកយើងខ្ញុំហ្នឹងបោសកន្លែងហ្នឹង បោសកន្លែងដែលមន្ទីរកសិកម្ម -- មន្ទីរៗ គេហៅមន្ទីរកសិកម្ម។ មន្ទីរកសិកម្មហ្នឹង គឺជាកន្លែងដែលគេឲ្យពួកយើងខ្ញុំមកនៅសំណាក់មួយរយៈមុនយកចែកៗគ្នាទៅតាមរោងចក្រ។ ហើយនៅកន្លែងហ្នឹង គឺកន្លែងមន្ទីរកុមារសង្គ្រោះ នៅជិតមហាវិទ្យាល័យច្បាប់ពីដើមបាទ។ ពីព្រោះខ្ញុំចាំច្បាស់ ព្រោះខ្ញុំក្រឡេកទៅឃើញមហាវិទ្យាល័យច្បាប់នៅខាងត្បូង។ ដូច្នេះ ឃើញអង្គាល់ហ្នឹង ខ្ញុំមានឃើញគេរៀបចំមន្ទីរមង្គលការជាមួយ -- មានលោក ចេង អន គាត់មក ឃើញរៀបចំ -- អាហ្នឹងយុទ្ធជនៗគេរៀបចំការដូច គេឲ្យខ្ញុំ ពួកខ្ញុំហ្នឹងបោសផ្ទះនៅជុំវិញហ្នឹងដើម្បីៗរៀបចំមន្ទីរការ -- មន្ទីរអាពាហ៍ពិពាហ៍ បងប្អូនប្រហែល២០ៗនាក់។ ហើយគេឲ្យខ្ញុំបោសផ្ទះអីជុំវិញៗ -- ពួកយើងខ្ញុំបោស។ ហើយតាមខ្ញុំដឹងមកពួកហ្នឹងនៅមួយគ្នាបាន១យប់ហ្នឹង ហើយទៅៗព្រឹកទៅចែក ទៅបាត់ទៅទៀតទៅ។ ខ្ញុំមិនដឹង -- អាហ្នឹងអ៊ីចឹង។ ខ្ញុំ--

[១០:០៧:៥០]

**ស៖** ចុះនៅក្នុងអំឡុងដែលបានរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ ជាពិសេសនៅជំរំបឹងត្របែកនោះ តើបានដឹងពីថា ការបោសសម្អាតខ្លាំងដែរអត់ទេបាទ?

**ឆ៖** និយាយសរុបខ្ញុំ អង្កាល់ហ្នឹងដូចជាថា ភ្លើក៏បានអីក៏បាន ប៉ុន្តែដូចវាអត់ដែលនឹកថា គេយកទៅសម្លាប់អី។ ប៉ុន្តែវានឹកឃើញ -- វាអត់នឹកឃើញថា ខ្លួនឯងថ្ងៃណាមួយស្លាប់ ឬក៏មិត្តភក្តិគេយកទៅសម្លាប់ អត់ដែលនឹកឃើញអ៊ីចឹងសោះ អត់ដែលនឹកអ៊ីចឹងបាទ។ ដល់ពេលចុងក្រោយ អាហ្នឹងចាប់ ដូចចាប់មានបារម្ភខ្លះ ប៉ុន្តែពីរឆ្នាំជាងមុនដំបូងអត់ដែលនឹកឃើញ។ ហើយដូច្នេះ អត់ដែលនឹកឃើញកន្លែងផ្សេងទៀតស្លាប់ ហើយដូចនៅៗបឹងត្របែកហ្នឹងភូមិសាស្ត្រអត់ឆ្ងាយពី អេស-ទ្វាំងតេអង(S-21)ទេ ប៉ុន្តែអត់ -- មិនដែលដឹងថា -- មិនដែលមានសង្ស័យថា មាន អេស-ទ្វាំងតេអង នៅហ្នឹងផងបាទ។ ទួលស្លែងហ្នឹងអត់ដែលគិត អត់ដែលៗនឹកឃើញទេបាទ។

[១០:០៩:០៧]

**ស៖** ប៉ុន្តែគឺថា មិនដែលនឹកឃើញអ៊ីចឹង ថាតើនៅពេលនោះដែលយើងរស់នៅជុំគ្នា មិនអ៊ីចឹងបាទ ដល់អ៊ីចឹងទៅមានការចាកចេញ មានការយកមនុស្សចេញអីអ៊ីចឹង សួរថាយកចេញហើយមានអ្នកហ្នឹងបានអញ្ជើញមកវិញដែរអត់ នៅពេលអំឡុងនុ៎ង?

**ឆ៖** អាហ្នឹងជាបាតុភូតមួយឆ្ងល់ដែរ គឺថាអ្នកចេញមានពីរ។ មានអ្នកចេញអង្កាល់ហ្នឹង អ្នកចេញហើយ បែកគ្នាហើយជួបគ្នាវិញមានដែរ មានដូចថា អង្កាល់ពួកយើងខ្ញុំនៅ ក-១៥ ពេលហ្នឹងពួកខ្ញុំមកដល់ភ្លាម គេមានមួយចំនួនគេឲ្យទៅនៅជំរំអីមួយទៀត តាឡី! ជំរំតាឡី តាឡីហ្នឹងខ្ញុំមិនដឹងនៅឯណា ប៉ុន្តែហ្នឹងកន្លែងធ្វើស្រែ។ អាហ្នឹងដល់ពួក -- មុនទៅពួក -- គេបញ្ជូនពួកខ្ញុំទៅរោងចក្រ ឬក៏សាលាកសិដ្ឋានរដ្ឋនោះ ហ្នឹងបានឃើញគ្នា។ អាហ្នឹងជាការឃើញ អាហ្នឹងជាការឃើញគ្នាវាជា គេហៅលក្ខណៈពិសេស។ ប៉ុន្តែក្រៅពីហ្នឹងគេយកទៅ អត់ដែលឃើញទេបាទ យកទៅចេះតែបាត់ យកទៅបាត់ៗ។ ជាពិសេសទៅនៅៗដីក្រហមហ្នឹង គឺថាមុននៅជំរំដីក្រហម ចាំច្បាស់គឺថា គេយកម្តងបួនដប់នាក់ៗ ហើយមុននឹងយកហ្នឹងគឺថា រៀបចំ គេរៀបចំ ជួនកាលគេដុតត្រី ជួនកាលគេកាប់មាន់ឲ្យទៅហូបតាមផ្លូវអ្នកធ្វើដំណើរ ហើយយើងទាំងអស់គ្នាធ្វើសប្បាយជូនមិត្តភក្តិ ព្រោះម្នាក់ៗបានចេញអ៊ីចឹងសប្បាយ ប៉ុន្តែដូចថា វាអត់ -- ហើយអ្នកចេញទៅហ្នឹង អត់ដែលមកវិញ។ គ្រាន់តែថា គ្រាន់តែដឹងថាប្រហែលគេយកទៅកន្លែងណា ដែលជំរំ អ៎! កន្លែង -- មិនមែនថាជំរំ ទៅ -- ក្រែងគេយកភ្នំពេញ យកមកធ្វើការអីៗតាមសមត្ថភាពរបស់ខ្លួន។ ប៉ុន្តែដូចលោកជ្រាបហើយ គឺថាពេលនុ៎ងវាអត់មានព័ត៌មានអី

អត់មានកាសែត អត់មានៗៗ ទទួលសំបុត្រ អត់អីមានអី ព្រោះអ៊ីចឹង -- ប៉ុន្តែយើងក៏អត់ដែលនឹកសង្ស័យថាយកទៅសម្លាប់។ អាហ្នឹងៗ អត់តែម្តង។

[១០:១១:៣២]

**ស៖** បាទ សូមអរគុណ។ ចំណុចមួយទៀតដែលកាលពីម្សិលមិញ គឺលោកថា នៅពេលនោះគេឱ្យចុះឈ្មោះទៅដីក្រហម ហើយលោក និង -- លោកបានចុះឈ្មោះទៅដែរ។ ហើយខ្ញុំចង់ដឹងថាតើចុះអ្នកឈ្មោះហ្នឹង គាត់នៅបឹងត្របែកដដែល ឬមួយគាត់ទៅណាបាទ? ព្រោះក្រោយមកលោកបានអញ្ជើញមកបឹងត្របែកវិញ។

**ឆ៖** តាមខ្ញុំដឹងថា ទី១ អ្នកចុះឈ្មោះហ្នឹង ជាទីបញ្ចប់ទៅ អ្នកចុះឈ្មោះមិនចុះឈ្មោះ អង្គការចង់យកពីណា ក៏យកទៅ គ្រាន់តែចុះឈ្មោះជារូបភាពទេបាទ មែនទែន។ ហើយអ្នកដែលបានទៅនៅបឹងត្របែកដដែល ឬក៏គេយកទៅកន្លែងណាផ្សេងទៀត ដល់ខ្ញុំទៅដីក្រហមបាត់ទៅ ខ្ញុំអត់ដឹងទេបាទ។ ប៉ុន្តែគ្រាន់ថា ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំទៅបានមួយរយៈ បងប្អូន -- បងថ្លៃខ្ញុំដែលគាត់លោកស្រី រស់ សារិន នោះគាត់អង្គុយ គាត់បានទៅដល់ដីក្រហមហ្នឹង ប្តីគាត់អត់ -- គេយកទៅបាត់។ អង្កាល់ហ្នឹងគឺខ្ញុំទៅក៏អត់ឃើញ ព្រោះគាត់ៗ អង្កាល់ពួកខ្ញុំទៅហ្នឹង ឃើញគាត់អត់បានទៅ ហើយគាត់នឹកក្នុងចិត្ត ប្រហែលគេចាំប្តីគាត់មកវិញ គេយកចាំទៅជាមួយគ្នា។ ប៉ុន្តែដល់ខ្ញុំទៅបានមួយរយៈទៅ ឃើញគាត់ទៅ ឃើញតែទៅជាមួយកូនបីនាក់ ជាមួយបងប្អូន មិត្តភក្តិទៀត ប៉ុន្តែប្តីគាត់អត់ឃើញទេបាទ។

[១០:១៣:២៨]

**ស៖** បាទ អរគុណបាទ។ ចំណុចមួយទៀតគឺ ថានៅទីនោះតែងតែមានការលើកប្រជុំស្វ័យទិតៀន ទិតៀន។ ខ្ញុំចង់ដឹថាតើមានបញ្ហាមួយដែលកើតឡើងទេ គឺការខុសសីលធម៌អី? តើលោកមានដែលបានជួបទេ ថាគេមានយកអារឿងហ្នឹងយកមកឱ្យប្តេជ្ញាឡើងវិញ ឬមួយយ៉ាងម៉េចអត់ទេបាទ?

**ឆ៖** សូមបញ្ជាក់សំណួរបន្តិចបាទ សីលធម៌ឈរលើស្អី? សីលធម៌នារីបុរស ឬសីលធម៌អី ខ្ញុំចង់ដឹងច្បាស់ សូមៗអធ្យាស្រ័យ។

**ស៖** បាទ សូមទោស ដោយសារបរិបទសម័យនោះ យើងថាខុសសីលធម៌ វាបញ្ហាស្ត្រី-បុរសបាទ។

**ឆ៖** នៅៗពេលរយៈពេលដែលពួកយើងខ្ញុំ មិនមែននៅតែបឹងត្របែកទេ នៅគ្រប់ពេលវេលាទាំងអស់ខ្ញុំមិនចាំថា មានបញ្ហាហ្នឹងរវាងគ្នាពួកខ្ញុំមកពីបរទេស មិនដែលមានបញ្ហាសីលធម៌ហ្នឹង មិន

ដែលមានបញ្ហាអីទាក់ទិននឹងរឿងហ្នឹងទេបាទ។

[១០:១៥:០០]

**ស៖** ចុះចំណុចមួយទៀត ថាតើវាមានបញ្ហាដែលការបំពានពីៗថ្នាក់ដែល អ្នកដឹកនាំហ្នឹងដែរ អត់ទៅលើអ្នកដែលយើងរស់នៅទីនោះ ពីបញ្ហាគេហៅថា រំលោភសេពសន្ថវៈដែរអត់ទេបាទ?

**ឆ៖** ការពិត ខ្ញុំអត់អាចសន្និដ្ឋានបាន គ្រាន់តែនៅតាខ្មៅឮសូរថា មានៗនារីម្នាក់នេះ ឮសូរមានពាក្យចចាមអារ៉ាម ប៉ុន្តែខ្ញុំគ្រាន់ថា អាហ្នឹងលោកចោទបញ្ហាខ្ញុំហើយ ក៏ខ្ញុំនិយាយអ៊ីចឹងទៅ ប៉ុន្តែក្រៅពីហ្នឹងខ្ញុំអត់ដែលៗឮសូរទេបាទ។

**ស៖** អរគុណបាទ។ ក្នុងចំណោមដែលបងប្អូនដែលអញ្ជើញមកពីបរទេសទាំងអស់ តើលោកមានបានជួបនរណាដែលជាជនជាតិភាគតិចចាមដែរអត់ទេបាទ?

**ឆ៖** ខ្ញុំមាន -- នៅដីក្រហមជាពិសេសខ្ញុំមានអនុស្សាវរីយ៍ដ៏ល្អ ហើយខ្ញុំជាមួយមិត្តចាមម្នាក់ដែលអង្គាល់នោះ គាត់និយាយថា គាត់ទៅរៀននៅឡាម៉ិច ឮ ប៉ុន្តែគាត់នៅក្រុមជាមួយខ្ញុំ ហើយថ្ងៃមួយគាត់ស្ទះទឹកនោម ហើយខ្ញុំធ្លាប់ឮសូរម៉ែខ្ញុំប្រាប់ថា ស្ទះទឹកនោមឲ្យយកដីដំបូក យកស្អីៗឫសឈើបីបួនមុខទៀតនោះទៅ ហើយគាត់ឃើញ -- អាហ្នឹងខ្ញុំមានអនុស្សាវរីយ៍ជាមួយគាត់ហ្នឹង។ ប៉ុន្តែអ៊ីចេះឃើញថា គាត់ហ្នឹងនៅក្រុមជាមួយខ្ញុំ ហើយគាត់មនុស្សល្អ ហើយក្រោយមកគេយកគាត់ទៅបាត់ទៅ មិនដឹងគេយកគាត់ទៅបាត់ដោយមូលហេតុអី ប៉ុន្តែគួរបញ្ជាក់ផងដែរថា នៅជំរំនៅដីក្រហម ឬជំរំផ្សេងៗ ទុកជាអ្នកណាជាមានមហាម៉េត ឬក៏អីៗ យើងដែលប្រកាន់ៗ ប៉ុន្តែគាត់នោះគាត់ញ៉ាំសាច់ជ្រូក ញ៉ាំ -- បើមានសាច់ម្ដងៗគាត់ញ៉ាំអ៊ីចឹង ជាមួយគេជាមួយឯង ដូចថាវាអាហ្នឹងជាៗ ដូចថា អាហ្នឹងរឿងរបស់គាត់ទេ។ ប៉ុន្តែចំពោះការទាក់ទងជាមួយពួកយើងខ្ញុំ យើងខ្ញុំអត់ដែលប្រកាន់ អត់ដែលអីគាត់ ជាមួយគាត់ទេ។

[១០:១៧:៥៣]

**ស៖** ដោយសារលោកបាននិយាយរួចហើយថា ការហូបចុកអីគាត់ហូបធម្មតា អានេះខ្ញុំចង់ដឹងថា តើវាមានការកំហិតណាមួយ ពីអ្នកដឹកនាំនៅក្នុងក្រុម ដែលមើលការខុសត្រូវពួកគាត់ទេថា កាលណាអ្នកឯងអត់ញ៉ាំសាច់ជ្រូក គឺមានបញ្ហា។ តើមានការកំហិតអ៊ីចឹង ឬមួយយ៉ាងម៉េច?

**ឆ៖** ពិបាកនិយាយដែរ បើនិយាយឲ្យចំទៅ។ យើងបើយើងនៅនេះ ដូចខ្ញុំនៅបែលហ្សិក នៅបារាំងអីអ៊ីចឹង បើយើងកាន់សាសនា យើងអត់ហូបសាច់ជ្រូក គេធ្វើម្ហូបអីមួយឲ្យយើងញ៉ាំទៅ អាហ្នឹង

វាចប់ហើយ។ យើងនៅជំរំជន ជំរំដូចពួកយើងខ្ញុំអ៊ីចឹង បានមានសាច់ម្តងៗទាំងអស់គ្នាវាហៀរទឹកមាត់ហើយ។ ដូច្នេះវា ខ្ញុំមិនចាំថា គេបង្ខំឲ្យគាត់ហូបសាច់ជ្រូក ឬហូបអីទេ ខ្ញុំមិនចាំទេ ខ្ញុំមិនអាចនិយាយប៉ុន្តែថា វាអត់ គ្រាន់តែខ្ញុំដឹងថា វាអង្គការគេអត់មាន គ្រាន់តែថា នែ៎ ដែលជនជាតិអ៊ិស្លាម ខ្ញុំអត់ធ្វើសាច់ជ្រូកឲ្យអ្នកឯងញាំទេ អាហ្នឹងវាអត់មានទេបាទ។ អត់មានដូចនៅស្រុកបារាំង នៅស្រុកបែលហ្ស៊ិកអីទេ អាហ្នឹងវាអត់មានអ៊ីចឹងទេបាទ។

[១០:១៩:២៩]

**ស៖** អរគុណ។ ខ្ញុំសូមចូលទៅបរិបទថ្មីមួយ ដែលនិយាយអំពីសាសនា ហើយនិងទំនៀមទម្លាប់ ថាតើនៅពេលដែលលោកអញ្ជើញមកដល់ៗទីក្រុងហ្នឹង តើលោកសង្កេតឃើញវត្តអារាមហ្នឹង តើមានព្រះសង្ឃ ឬមួយៗមានស្អីនៅក្នុងវត្តអារាមហ្នឹងដែរអត់ទេបាទ?

**ឆ៖** ខ្ញុំមិនដែលឃើញលោកសង្ឃទេទី១។ ទី២ ខ្ញុំៗមាន ដែលខ្ញុំធ្លាប់កាត់តាមទន្លេ -- អ៎! វត្តលង្កា ពីព្រោះវត្តលង្កា ខ្ញុំអង្កាល់នៅពីយុវជនមានបងខ្ញុំមួយគាត់បួស ហើយខ្ញុំតែម្តងៗកាត់តាមហ្នឹង ខ្ញុំតែងក្រឡេកមើល ហើយខ្ញុំឃើញវិហារវត្តលង្កាដែលខ្ញុំធ្លាប់មកលេងហ្នឹង ឃើញដូចជាៗ ទ្រុងជ្រូក ឬក៏ស្អីទេ ប៉ុន្តែខ្ញុំអត់ឃើញជ្រូកទេបាទ។ គ្រាន់តែថា ខ្ញុំវាអត់មាន ដូចថាវាអត់មានស្អីទាំងអស់នៅក្នុងវត្តនេះ។

**ស៖** អរគុណបាទ។ សំណួរចុងក្រោយរបស់ខ្ញុំថា ពាក់ព័ន្ធនឹងទំនៀមទម្លាប់នេះដែរ ថាតើនៅក្នុងរបបហ្នឹងពេលដែលយើងគោរពបូជាអីមួយ តើអាចនឹងធ្វើបានទេ? ហើយជាពិសេសនៅពេលដែលយើងបុណ្យចូលឆ្នាំខ្មែរអី តើគេមានការប្រារព្ធយ៉ាងម៉េចដែរ?

[១០:២១:២៩]

**ឆ៖** ដូចខ្ញុំ អនុស្សាវរីយ ដូចគ្មានរឿងបុណ្យចូលឆ្នាំ បុណ្យអីទេ គ្រាន់តែបុណ្យ១៧មេសាអ៊ីចឹង ជ័យជម្នះៗ អាហ្នឹងគេមាន គេមានធ្វើបុណ្យ កាប់ជ្រូកមួយ បើនៅដីក្រហមបាទ កាប់ជ្រូកមួយអីអ៊ីចឹង ឬក៏គេទៅរកជ្រូកព្រៃបានមកធ្វើបុណ្យអីមួយអ៊ីចឹង។ ប៉ុន្តែគ្រាន់តែថា ក្រៅពីហ្នឹង ដូចជាខ្ញុំអត់ចាំ អត់ចាំថាមានអីក្រៅពីហ្នឹង។ ប៉ុន្តែជួនកាលដូចជាបងប្អូនយើងពេលខ្លះ ដូចថាអត់មានរឿងសិល្បៈ អត់មានរឿងអីៗដូច ដូចអត់មានកម្មវិធី អត់ដែលឃើញបាទៗ។

**ស៖** អរគុណ។ ដោយសាររឿងពាក់ព័ន្ធនឹងទំនៀមទម្លាប់នេះដែរ ថាដូចលោកបានលើកឡើងអម្បាញ់មិញថាលោកមានមិត្តចាមអ៊ីចឹង តើមានសង្កេតឃើញគាត់ថា មានការ -- គាត់មានការគោរព

តាមទំនៀមទម្លាប់គាត់ដែរអត់ទេ?

**ឆ៖** ខ្ញុំអត់ឃើញទេបាទ។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណជាច្រើន។ ហើយខ្ញុំសូមថ្លែងអំណរគុណទៅលោកសាក្សី ហើយពេលនេះខ្ញុំអត់សំណួរហើយ។ បាទ សូមអរគុណ។

[១០:២២:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសម្រាប់សាក្សីនៅបន្ទប់រង់ចាំ សម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញ នៅវេលាម៉ោងដប់មួយខ្វះម្ភៃនាទី ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៣ នាទី ដល់ម៉ោង ១០:៤២ នាទី)*

[១០:៤២:១៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលសិទ្ធិមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។

ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ ជាមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនសួរទៅកាន់លោក។ ជាដំបូង ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីឲ្យលោកឆ្លើយតបទៅនឹងចម្លើយដែលលោកឆ្លើយទៅនឹងសំណួររបស់សហចៅក្រមស៊ើបអង្កេត។ ដូច្នេះ លោកប្រធាន ខ្ញុំសូមអនុញ្ញាតដកស្រង់យកនូវឯកសារលេខ E3/97។ ERN ជាភាសាបារាំង 00241894, ERN ជាភាសាខ្មែរ 00270705, ERN ជាភាសាអង់គ្លេស 00287110។

[១០:៤៣:៣៩]

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៖**

**ស៖** លោកសាក្សី ខាងសហចៅក្រមស៊ើបអង្កេតបានសួរសំណួរលោក ហើយខ្ញុំសូមអាននូវសំណួរនិងចម្លើយ ដើម្បីឲ្យលោកឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ។ មានសំណួរសួរថា "តើនៅពេលណាដែលលោកដឹង អៀង សារី គឺជាអ្នកគ្រប់គ្រងរួមនៅជំរំបឹងត្របែក?" លោកបានឆ្លើយថា "ខ្ញុំបានដឹងរឿងនេះ បន្ទាប់ពីត្រឡប់មកពីដីក្រហមវិញ"។ ហើយលោកបន្តទៅទៀត នេះជាផ្នែកដែលខ្ញុំចាប់អារម្មណ៍ "ពីមុនខ្ញុំគិតថា គាត់ជាអ្នកទទួលខុសត្រូវសំខាន់លើពួកខ្មែរដែលបានត្រឡប់មកពីបរទេស"។ លោកសាក្សី ខ្ញុំចោទសួរលោកពាក់ព័ន្ធទៅនឹងផ្នែកទី២ នៃចម្លើយរបស់លោក។ តើលោកចង់មានន័យថាម៉េច ដែលលោកឆ្លើយថា អៀង សារី ជាអ្នកទទួលខុសត្រូវលើពួកខ្មែរដែលបានត្រឡប់មកពីបរទេសនោះ?

**លោក អ៊ុង ចុងហៀង៖**

**ឆ៖** សូមគោរពអ្នកស្រីមេធាវី។ ខ្ញុំយល់ថាអ្វីៗដែលទាក់ទងនឹងកិច្ចការបរទេស ឬអ្វីៗដែលទាក់ទងខ្មែរនៅបរទេស អ្វីៗដែលខ្មែរបរទេសចូលស្រុកគឺតាមខ្ញុំក្តាប់បាន គឺលោក អៀង សារី ជាអ្នកទទួលខុសត្រូវ។ ពីព្រោះគាត់នេះហើយដែលបានរៀបចំខ្មែរឲ្យចូលស្រុក។ ដូច្នេះ ខ្ញុំយល់ថា អ្នកចូលស្រុក គឺនៅក្រោមការទទួលខុសត្រូវរបស់លោក អៀង សារី។ ពីព្រោះលោកអៀង សារី ជាអ្នកធ្វើដំណើរ លោកអៀង សារី ជាអ្នករៀបចំបង្កើតកិច្ចការផ្សេងៗដើម្បីប្រមែប្រមូលធ្វើការងារសតិអារម្មណ៍ឲ្យបងប្អូនខ្មែរនៅបរទេសចូលមកប្រទេសវិញ។ ហើយ ដូច្នេះហើយបានជាខ្ញុំយល់ថា នេះជាគោលការណ៍ខ្ញុំយល់ថា ក្នុងសតិអារម្មណ៍របស់ខ្ញុំគឺ ។ខ្ញុំមិនអាចថាលោក នួន ជា ឬអាចថាលោកណាផ្សេងទេ ប៉ុន្តែ

ចំពោះខ្ញុំគឺលោក អៀង សារី គាត់ជាអ្នកទទួលខុសត្រូវ ព្រោះគាត់ -- លោក នួន ជា ព្រោះខ្ញុំមិនដឹង -- អត់ដែលស្គាល់គាត់ ប៉ុន្តែលោក អៀង សារី ខ្ញុំតែងតែជួបគាត់ តែងតែឃើញគាត់ ហើយទាក់ទងជាមួយខ្មែរនៅបរទេស។ ដូច្នេះ តាមយោបល់ខ្ញុំ គឺគ្មានអ្នកណាក្រៅពីលោកអៀង សារី ទេ។ នេះមួយ។

[១០:៤៦:២៩]

ទី២ ដល់ខ្ញុំ -- ហេតុអ្វីបានខ្ញុំនិយាយថា ទី២ ដែលលោក អៀង សារី ពួកខ្ញុំមកពីដីក្រហមវិញ គឺពេលនេះហើយដែលយើងខ្ញុំបានជួបគាត់។ ពេលហ្នឹងគាត់ថា គាត់ដូចជាក្នុងសតិអារម្មណ៍គាត់ថា គាត់សួរថា ពួក -- ម៉េចទៅនៅដីក្រហម? ពីណាបញ្ជូនពួកយើងខ្ញុំទៅ? ដូច្នេះ ខ្ញុំគ្រាន់ឮសួរអ៊ីចឹងមក ថា ចុម ម៉េចក៏គាត់អត់ដឹង? ហើយខ្ញុំថា យី! បើអត់ដឹង អ៊ីចឹងបានសេចក្តីថា ឬមួយគាត់ចង់លាងខ្លួនថា មិត្តភក្តិខ្ញុំ – ខ្ញុំបន្តទៀតបានទេ? – ឬក៏គាត់ចង់ថាយ៉ាងម៉េច? បានន័យថា អ្នកចេញពីដីក្រហមហ្នឹង គាត់អត់ដឹងថាទៅណាឬយ៉ាងម៉េច? ព្រោះពេលនោះខ្ញុំមិនដឹងថា អ្នកចេញពីដីក្រហមនោះស្លាប់ដូចពេលនេះទេ។ ហើយខ្ញុំក៏ចោទបញ្ហាមួយទៀត ចុះបើគាត់អត់ដឹង ហេតុដូចម្តេចបានជាក្មួយ -- អ្នកចេញពីដីក្រហមទាំងអស់បាត់ខ្លួន ក្មួយគាត់ពីរនាក់នៅរស់? ខ្ញុំមិនមែនថាចង់ឲ្យក្មួយនៅស្លាប់ទេ ប៉ុន្តែថា បើអ្នកក្រៅគាត់អត់ដឹង ម៉េចក៏អ្នកចេញក្រៅពីក្មួយគាត់ពីរនាក់នៅរស់? អាហ្នឹងខ្ញុំចោទជាបញ្ហា។ ហើយរហូតដល់ឥឡូវ ខ្ញុំបញ្ហានេះ ខ្ញុំនៅតែអត់មានចម្លើយ។

**ស៖** សូមអរគុណលោកសាក្សី។ នៅក្នុងចម្លើយលោកនោះ លោកបានរៀបរាប់ឈ្មោះមួយចំនួន ខ្ញុំចង់ឲ្យលោកប្រាប់ថាតើជាខ្មែរដែលរស់នៅ -- ដែលមកពីបរទេសឬក៏អត់នោះ? ខ្ញុំនឹងចាប់ផ្តើមជាមួយនឹងឈ្មោះមួយដែលលោកបាននិយាយកាលពីម្សិលមិញ គឺលោក រស់ សារិន។ កាលពីម្សិលមិញនេះ លោកបានឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាថា លោក រស់ សារិន ជាបងថ្លៃរបស់លោក ហើយគាត់ថា ប្រពន្ធរបស់គាត់ហ្នឹងបានសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងនេះ។ ហើយលោកប្រាប់ថា រស់ សារិន ជាអតីតប្រធានអាកាសយានដ្ឋានពោធិ៍ចិនតុង ហើយលោកបានឆ្លើយថា លោកបានជួបគាត់នៅនៅបឹងត្របែក នៅពេលដែលលោកបានទៅដល់នៅឆ្នាំ៧៦។ ដូច្នេះតើលោកអាចបញ្ជាក់បានទេថា លោក រស់ សារិន នេះគឺជាជនជាតិខ្មែរដែលត្រឡប់មកពីបរទេស?

[១០:៤៩:២៧]

**ឆ៖** បាទខ្ញុំអាចបញ្ជាក់បាន១០០ភាគរយថា លោក រស់ សារិន ភរិយាគាត់ និងកូនបីនាក់ ពិតជាបានមកពីបរទេស។

**ស៖** សូមអរគុណ។ កាលពីម្សិលមិញលោកបានឆ្លើយទៅនឹងសហព្រះរាជអាជ្ញាថា លោកបានជួប រស់ សារិន នៅបឹងត្របែក។ នៅពេលដែលលោកជួបគាត់ភ្លាមនោះ តើលោកមានចំណាប់អារម្មណ៍យ៉ាងម៉េចដែរ ពេលដែលលោកឃើញគាត់នោះ គាត់ -- តើលោកមានគិតយ៉ាងម៉េចដែរ នៅពេលដែលបែកគ្នាយ៉ាងយូរ ហើយបានឃើញជួបនោះ? តើគាត់មានសតិអារម្មណ៍យ៉ាងម៉េចដែរនៅពេលនោះ?

**ឆ៖** ជារួមសតិអារម្មណ៍គាត់ពេលនោះ អត់ខ្ពស់អីទេ គឺគាត់ស្ដាយខ្លួនដែលបាននាំកូនគាត់ដែលកំពុងរៀនសូត្រមកនៅជាប់ហ្នឹងក្នុងមន្ទីរឃុំឃាំងហ្នឹងបាទ។

**ស៖** កាលពីម្សិលមិញលោកក៏បានឆ្លើយថា លោកបានឃើញឈ្មោះ រស់ សារិន នៅក្នុងបញ្ជីគុកទួលស្លែង ហើយលោកក៏បានឆ្លើយទៅនឹងសហព្រះរាជអាជ្ញាថា កាលពីម្សិលមិញនេះថា អង្គការបានហៅគាត់យកចេញទៅនៅពេលគាត់នៅបឹងត្របែក។ តើលោកមានវត្តមានដែរឬទេ នៅពេលដែលគេហៅលោក រស់ សារិន ចេញទៅនោះ?

[១០:៥១:១៦]

**ឆ៖** ពេលនោះ គឺមានគេហៅសមាជនៅបឹងត្របែក នៅសាលមួយនៅបឹងត្របែកដែលមាន ភុំ ជាអ្នកឧទ្ទេសនាម ហើយគេយកលោក រស់ សារិន ទៅហើយនិងលោក ភឹង តុន, លោក ឈូក មឹងម៉ៅ និងខ្មែរបរទេសមួយចំនួនទៀត ខ្ញុំនៅជាសាក្សីនៅទីនោះ ហើយខ្ញុំចង់មកលាគាត់ដែរ ប៉ុន្តែមិនអាចមានសិទ្ធិចេញទៅបាន។ ប៉ុន្តែ គឺខ្ញុំបានឃើញគាត់។ គាត់ចេញពីសាលប្រជុំបាទ។

**ស៖** សូមអរគុណលោកសាក្សី។ នៅពេលនោះ តើលោកដឹងទេ ថាហេតុអ្វីបានជាអង្គការហៅលោក រស់ សារិន ទៅនោះ?

**ឆ៖** បាទ អត់ដឹងទេ គ្រាន់ថា សង្ឃឹមថា គាត់ប្រហែលជាអង្គការត្រូវការគាត់ទៅជួយធ្វើការនៅបើកពោធិ៍ចិនតុងឡើងវិញហើយមើលទៅ គ្រាន់តែសង្ឃឹមអ៊ីចឹងបាទ។

[១០:៥២:៤៦]

**ស៖** សូមអរគុណ។ តើលោកស្គាល់ឈ្មោះ ហម សុគុង ទេ? ខ្ញុំគិតថាប្រហែលខ្ញុំអានពាក្យឈ្មោះនេះត្រូវហើយ ហម សុគុង តើលោកស្គាល់គាត់ទេ?

**ឆ៖** ខ្ញុំស្គាល់ច្បាស់ ហម សុគុង នេះគឺ ព្រោះខ្ញុំធ្លាប់ស្គាល់គាត់ពីស្រុកបារាំង។ គាត់នៅផ្ទះបុរីអន្តរជាតិ ផ្ទះហូឡង់ជាមួយនិងភរិយាខ្ញុំ។

**ស៖** តើគាត់ជាជនជាតិខ្មែរ ដែលត្រឡប់មកពីបរទេសមែនទេ?

**ផ៖** ប្រាកដមែនហើយ។

**ស៖** នៅក្នុងខ្សែជីវិតរបស់លោកដែលលោករៀបរាប់នៅ ក-១៥ នៅបឹងត្របែក នៅដីក្រហម ហើយបន្ទាប់មក មកបឹងត្របែកវិញហ្នឹង តើលោកមានធ្លាប់បានឃើញគាត់ទេ ក្នុងអំឡុងពេលហ្នឹង? ហើយបើឃើញ តើឃើញនៅឯណាដែរ?

**ផ៖** ខ្ញុំឃើញគាត់ជារយៈពេលចុងក្រោយ ពេលខ្ញុំកំពុងកាប់ដីនៅចម្ការដំឡូងឈើគាត់បានលើកដៃលា លាពួកយើងខ្ញុំនៅក្រោយម៉ូតូមួយដែលដឹកនាំដោយ ដឹកចេញពីដីក្រហមបាទ។

**ស៖** *(មីក្រូហ្វូនមិនដំណើរការ)*

**អ្នកបកប្រែ៖**

លោកប្រធាន អ្នកបកប្រែស្តាប់អត់ឮទេ ព្រោះគាត់អត់បានបើកមីក្រូ។

**ស៖** សូមអភ័យទោស តើលោកដឹងថាទេ មានរឿងអីកើតឡើងចំពោះលោក ហម សុគុង នេះ?

**ផ៖** រហូតដល់សព្វថ្ងៃនេះ ខ្ញុំអត់ដឹងថា គាត់នៅឯណាទេ ប៉ុន្តែខ្ញុំមិនៗចាំច្បាស់ ខ្ញុំភ្លេចថាតើខ្ញុំមានឃើញឈ្មោះគាត់នៅទួលស្លែងអត់ ខ្ញុំៗភ្លេចទៅបាទ។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកស្គាល់ឈ្មោះ ហុកឃី ដែរឬទេ?

**ផ៖** បាទ ស្គាល់។ ស្វាយ ហុកឃី។

**ស៖** តើគាត់ជាជនជាតិខ្មែរដែលត្រឡប់មកពីបរទេសមែនទេ?

**ផ៖** បាទ ប្រាកដមែនហើយ។

[១០:៥៦:២១]

**ស៖** តើលោកមានបានជួបគាត់ទេ នៅក្នុងខ្សែជីវិតរបស់លោកតាំងពីក-១៥ រហូតទៅដល់បឹងត្របែកនោះ?

**ផ៖** បាទ ខ្ញុំបាន -- គាត់បានទៅដីក្រហម ហើយគាត់ៗស្លាប់នៅទីនោះបាទ។

**ស៖** លោកសាក្សី តើលោកដឹងទេ ថាហេតុដូចម្តេចបានជាគាត់ស្លាប់?

**ផ៖** ពិបាកនិយាយណាស់ ពីព្រោះអ៊ីចេះ ពីព្រោះខ្ញុំចាំក្នុងសតិអារម្មណ៍របស់ខ្ញុំ ហើយអ្នកនៅទីនោះ គឺថាគាត់បានធ្វើអត្តឃាតខ្លួនឯង។ ប៉ុន្តែក្រោយមកដល់ខ្ញុំសរសេរអ៊ីចឹង ភរិយាគាត់បានថា គាត់មិនច្បាស់ទេ ប្រហែលជាខ្មែរក្រហមទេ ដែលសម្លាប់ប្តីគាត់។ ដូច្នេះ ខ្ញុំៗមិនអាចអះអាង ប៉ុន្តែគ្រាន់តែច្បាស់ គឺគាត់ស្លាប់នៅដីក្រហម។

**ស៖** សូមអរគុណលោកសាក្សី។ ដើម្បីបន្តទៅនឹងចម្លើយរបស់លោកនេះ ខ្ញុំសូមអានសម្រង់ចេញពីសៀវភៅរបស់លោក។

**លោកស្រី ម៉ារី ហ្គ័រ៉ូដ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីដកស្រង់ចេញពីសៀវភៅរបស់លោកសាក្សី ដែលមានចំណងជើងថា "ខ្ញុំជឿខ្មែរក្រហម" ដែលមានលេខ D141/1.2។ ERN ជាភាសាបារាំង 00287893, ERN ជាភាសាខ្មែរ 00831070។ ឯកសារនេះមិនមានជាបកប្រែជាភាសាអង់គ្លេសទេលោកប្រធាន។

[១០:៥៨:៤០]

**សួរដោយលោកស្រី ម៉ារី ហ្គ័រ៉ូដ៖**

**ស៖** ខ្ញុំសូមអានឃ្លាមួយនៃសៀវភៅរបស់លោក ដើម្បីឲ្យលោមានមតិឆ្លើយតបទៅអ្វីដែលលោកបានឆ្លើយអំពីកាលៈទេសៈខ្មៅងងឹតនៃការស្លាប់របស់លោក ហុកឃី។ ខ្ញុំសូមអានឃ្លានៅក្នុងសៀវភៅដែលលោកបានពន្យល់អំពីមូលហេតុដែលលោកសរសេរសៀវភៅនេះ។ លោកឆ្លើយថា៖ "ខ្ញុំគ្មានបំណងសរសេរសៀវភៅប្រវត្តិសាស្ត្រទេ តែទិសដៅនៃសៀវភៅនេះ គឺរៀបរាប់អំពីការលាងខួរ ការកម្ទេចបុគ្គល ការខ្លាចទុក្ខវេទនា ការស្រេកឃ្លាន ការឈ្លោះប្រកែកគ្នានៅពេលដែលគេយកមនុស្សទៅដាក់ក្នុងមន្ទីរឃុំឃាំង ហើយធ្វើទារុណកម្ម។ ខ្ញុំផ្ទៀតបង្ហាញថា នៅពេលវេទនាយើងអាចប្រព្រឹត្តអំពើ ដែលនៅធម្មតាយើងស្អប់ខ្ពើម។ ខ្ញុំបង្ហាញឲ្យឃើញថា អ្នកខ្លះដោយឱកាសនិយម ឬក៏ដោយការលាងខួរនោះក្បត់គ្នាឯង។ ខ្ញុំលើកឧទាហរណ៍ពីនេះពីនោះដើម្បីបង្ហាញឲ្យឃើញថា ក្នុងបុគ្គលយើងម្នាក់ៗ មានការប្រទាញប្រទង់គ្នា ហើយមនុស្សម្នាក់ៗមានអត្តសញ្ញាណខុសៗគ្នា។

[១០:៥៩:៤៣]

នៅក្នុងសៀវភៅនេះ ខ្ញុំបានលើកឡើងតម្កើងវីរភាពរបស់គ្នាយើងមួយចំនួន ដែលប៉ាន -- ដែលក្លាហានប៉ានប្រឆាំងនឹងពួកខ្មែរក្រហម។ អ្នកខ្លះគេលួចរត់ អ្នកខ្លះទៀតធ្វើឃាតខ្លួនឯង។ ជីវិតរបស់ពួកអ្នកបាត់បង់ទៅ នៅជាអមតៈនៅក្នុងព្រលឹងរបស់ខ្ញុំ"។ ខ្ញុំចង់ឲ្យលោកឆ្លើយតប ទៅនឹងឃ្លាចុងក្រោយរបស់លោកនេះ តើលោកគិតថាដំណោះស្រាយ ចំពោះថាអ្នកដែលស្ថិតនៅក្នុងព្រលឹងរបស់លោកនោះគឺថា គឺអ្នកដែលរត់គេច ហើយនិងអ្នកដែលធ្វើអត្តឃាតខ្លួនឯងនេះ ខ្ញុំសូមយោបល់ពីលោកអំពីចំណុចនេះ។

**ឆៈ** ខ្ញុំជឿជាក់ថា សាក្សីពិតប្រាកដមែនទែននោះ គឺជាសាក្សីដែលពួក អ្នកដែលស្លាប់ទៅ យើងខ្ញុំដែលរស់នៅគឺ មិនមែនជាសាក្សីពិតប្រាកដទេ បើនិយាយតាមជម្រៅចិត្ត ដែលជានៅក្នុងបេះដូងរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំចង់និយាយថា ទោះជា--

[១១:០១:២២]

**សៈ** សូមអរគុណលោកសាក្សី។ ខ្ញុំនឹងដូរប្រធានបទហើយ ព្រោះលោកពេលនេះដូចជាក្តុកក្តួល ខ្ញុំចង់និយាយអំពីការស្នាក់នៅបឹងត្របែក គឺបន្ទាប់ពីលោកស្នាក់នៅដីក្រហម លោកទៅនៅបឹងត្របែក ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយ។ ខ្ញុំសូមទោសផងដែលធ្វើឲ្យក្តុកក្តួលបែបនេះ តែជាការសំខាន់ណាស់ចំពោះខ្ញុំ ខ្ញុំត្រូវតែលើកឡើងនូវឃ្លា ព្រោះថាវាមានចំណុចពាក់ព័ន្ធចាប់អារម្មណ៍មួយចំនួន ជាពិសេស ពាក់ព័ន្ធទៅនឹងរបៀបនៃការសរសេរសៀវភៅរបស់លោក។ ខ្ញុំមិនចង់ឲ្យលោកអារម្មណ៍ក្តុកក្តួលទេ។ សូមឲ្យលោកសម្រួលអារម្មណ៍។ ជាពិសេស សូមឲ្យលោកឆ្លើយតបទៅនឹងរយៈកាលទី២ ដែលលោកនៅបឹងត្របែក។

កាលពីម្សិលមិញនោះ លោកបានឆ្លើយថា លោកដំបូងនៅប-៣០ បន្ទាប់មកគេផ្ទេរលោកទៅ ប-៣២ ហើយកាលពីម្សិលមិញនេះ លោកបានឆ្លើយយ៉ាងច្បាស់ថា នៅក្នុងបឹងត្របែកនោះមានជំរំបី ប-៣០, ប-៣១, ប-៣២។ ខ្ញុំមានសំណួរខ្លីៗ ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងការដឹកនាំ បេ-៣០ និង បេ-៣២ គឺខ្ញុំសួរបន្តទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ដែលពាក់ព័ន្ធទៅនឹងក-១៥ ថានៅទីនោះគឺកម្មាភិបាលខ្មែរក្រហម ប្រើប្រាស់បញ្ញាជនដើម្បីឲ្យដឹកនាំអ្នកទោស។ ដូច្នេះ សូមឲ្យលោកមានមតិយោបល់ ពាក់ព័ន្ធទៅនឹងចំណុចនេះ។

[១១:០២:៥៥]

**ឆៈ** សូមអភ័យទោស។ បាទ ពួកខ្មែរក្រហម ក៏ដូចជាពួកណាហ្ស៊ី ជំនាន់ជ្វីហ្វដែរ គឺថាគេចាត់តាំងគ្នាយើង ពួកយើងខ្ញុំដែលមកបរទេសហ្នឹងឲ្យធ្វើការត្រួតត្រាគ្នាឯងជំនួសគេ អង្គាល់ខ្ញុំដឹងដូចនៅជ្វីហ្វអ៊ីចឹងគេ ពួកណាហ្ស៊ី គេធ្វើដូចគ្នា។

**សៈ** ដើម្បីបន្តទៅនឹងចម្លើយរបស់លោកនេះ តើលោកអាចបញ្ជាក់បានទេ ថាតើអ្នកណាជាអ្នកទទួលខុសត្រូវ ឬក៏មេ -- អាចជាអ្នកទទួលខុសត្រូវ ឬក៏មេ ប-៣០ នៅពេលដែលលោករស់នៅទីនេះនោះ?

**ឆៈ** តាមខ្ញុំចាំដូចជា លោក ហំ ហ៊ុយ ជាខ្មែរ អ៎! ជាអ្នកមកពីបរទេសដែរ។ នេះជាលោក អ៎!

លោកស្រីចង់សួរខ្ញុំខ្មែរមកពីបរទេសជាអ្នក -- ឈ្មោះខ្មែរមកពីបរទេស ឬក៏អង្គការខ្មែរក្រហម។

**ស៖** តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ អំពីសកម្មភាពរវាងមេដឹកនាំខ្មែរក្រហម ដែលដឹកនាំ ហើយនិងបញ្ញាជនដែលដឹកនាំនេះ សូមឲ្យលោកផ្តល់ឈ្មោះទាំងពីរមក ប្រសិនបើលោកដឹងនោះ?

[១១:០៤:៥៩]

**ឆ៖** ពេលខ្ញុំមកពីដីក្រហមវិញ នៅចូលបឹងត្របែក ខ្ញុំ ដូចជាខ្ញុំមិនចាំថាមានអ្នកប្រចាំការត្រួតពិនិត្យពួកយើងខ្ញុំ ដូចកាលពួកខ្ញុំមុនទៅដីក្រហមទេ។ គឺពួកយើងខ្ញុំត្រូវការទៅ -- ត្រួតត្រាផ្ទាល់ពីសំណាក់លោក អៀង សារី និងអ្នកនៅជុំវិញគាត់។ ហើយនៅចំពោះពួកយើងខ្ញុំ គឺតាមខ្ញុំចាំ នៅ ប-៣០ មានដូចលោក ហំ ហ៊ុយ ជាមនុស្សល្អ ហើយតាមខ្ញុំចាំបាទ។

**ស៖** តើលោកមានបានចូលរួមនៅក្នុងការជ្រើសតាំង ឬក៏ជ្រើសតាំង ហំ ហ៊ុយ នេះ ឡើងវិញទៀតទេ?

**ឆ៖** បាទ បានចូលរួម ពីព្រោះទាំងអស់គ្នាចូលរួម ហើយលោក អៀង សារី ជាអ្នកធ្វើប្រធានអង្គប្រជុំ។ គឺជាទាំងអស់ សមាជិកទាំងអស់ លើកដំបូង គឺមន្ទីរនីមួយៗ ៣០, ប-៣០, ប-៣១, ប-៣២ គឺគេ ទី១ គេប្រជុំទាំងអស់គ្នា ហើយបន្ទាប់មកទៀត ថ្ងៃក្រោយបន្ទាប់បន្តិចមកទៀត គឺប្រជុំ មន្ទីរនីមួយៗ ដើម្បីចាត់តាំងរើសគណៈកម្មការ។ ហើយគណៈកម្មការនេះ ខ្ញុំសង្កេត គណៈកម្មការចាត់តាំងលោក អៀង សារី ឲ្យរើស -- ឲ្យខ្មែរបរទេសហ្នឹង រើសគ្នាឯង ដើម្បីទទួលខុសត្រូវក្នុងរង្វង់គ្នាឯង។ ហើយខ្ញុំបញ្ជាក់ថែមទៀត គឺថាពេលនោះ បរិយាកាសធូរស្រាល អត់មានអីតានតឹង ដូចពីដើមទេ។ ហើយពេលនោះ លោកពីដើមឡើយ គឺថាអត់មានការពិភាក្សាជាមួយសមាជិកមន្ទីរ អ្នកនៅក្នុងមន្ទីរទេពីដើមឡើយ គឺអង្គការជាអ្នកចាត់តាំង តំណាងអង្គការជាអ្នកចាត់តាំង។

[១១:០៧:២២]

លើកនេះ លោក អៀង សារី គាត់បាននិយាយថា ឥឡូវយើងធ្វើប្រជាធិបតេយ្យ ដូច្នេះឲ្យៗពីណាឈរឈ្មោះទៅ ហើយមានអ្នកគាំទ្រលើកដៃទៅ ហើយដូចន័យថា គាត់ៗ ឥឡូវហ្នឹង គឺថាយើងធ្វើប្រជាធិបតេយ្យ។ ដូច្នេះ ប្រជាធិបតេយ្យពិតប្រាកដរបស់អង្គការសព្វថ្ងៃហ្នឹង។

**ស៖** សូមអរគុណ ចំពោះចម្លើយរបស់លោក លោកសាក្សី។ តើអ្នកណាជាប្រធានគណៈកម្មការ ប-៣២ នៅសម័យដែលលោកនៅទីនោះ នោះ?

**ឆ៖** លោក ហោ ណាំហុង បាទ។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកមានបានចូលរួមនៅក្នុងការជ្រើសរើសតាំងគាត់ ឬក៏ជ្រើសរើសតាំងឡើងវិញ ជាប្រធាន ប-៣២ ទេ?

**ឆ៖** បាទ ខ្ញុំបានចូលរួម។

**ស៖** តើលោក អៀង សារី មានវត្តមានដែរឬទេ នៅពេលធ្វើការជ្រើសរើសនេះ?

[១១:០៨:៥៩]

**ឆ៖** បាទ លោក អៀង សារី មានវត្តមាន ជាអ្នកប្រធានអង្គប្រជុំ។

**ស៖** សូមអរគុណលោកសាក្សី។ នៅពេលដែលនិយាយអំពីការជ្រើសរើស ហំ ហ៊ុយ ហើយ និងប្រធាន ប-៣២ លោកបានលើកឡើងអំពីកិច្ចប្រជុំពីរ ដែលលោកបានចូលរួម ដែលមានវត្តមានរបស់លោក អៀង សារី។ ហើយកាលពីម្សិលមិញ លោកបាននិយាយថា លោកបានជួប អៀង សារី ពីរដង គឺនៅ ប-៣០ ឬ ប-៣២។ ខាងសហព្រះរាជអាជ្ញាបានសួរលោកកាលពីម្សិលមិញ អំពីកិច្ចប្រជុំទាំងពីរនេះ។ ឥឡូវនេះ ខ្ញុំចង់ទៅឱ្យបានឆ្ងាយបន្តិច ដោយប្រើប្រាស់នូវសម្រង់នៃសៀវភៅរបស់លោក។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

ដោយសុំការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញអំពីសៀវភៅមួយគឺ "ខ្ញុំជឿខ្មែរក្រហម" ដែលបញ្ជាក់អំពីកិច្ចប្រជុំពីរនេះ។ គឺឯកសារលេខ D141/1.2។ ចំពោះកិច្ចប្រជុំទី១នោះ គឺយើងមាន ERN ជាភាសាខ្មែរនិងបារាំង។ ជាភាសាបារាំង 00288092, ERN ជាភាសាខ្មែរ 00831246។ គឺទំព័រទី២១៣ នៃសៀវភៅរបស់លោក។ ខ្ញុំសូមអានសម្រង់នេះ។ ដូច្នេះខ្ញុំ បន្ទាប់មក ខ្ញុំនឹងឱ្យលោកផ្តល់យោបល់ទៅលើឃ្លារបស់លោកនេះ។ លោកបាននិយាយអំពីកិច្ចប្រជុំទី១ នៅ ប-៣០ ដែលមានវត្តមានរបស់ អៀង សារី។ លោកបាននិយាយថា "បន្ទាប់មកទៀត អៀង សារី ក៏និយាយអំពីសត្រូវដែលបន្តធ្វើវិទ្ធង្សនាចំពោះផែនការបម្រើប្រជាជនដ៏ទី ជាទីស្រឡាញ់នេះ។ គាត់បាននិទាននូវប្រវត្តិរបស់ការប្រយុទ្ធរបស់ក្រុមគាត់ប្រឆាំងនឹងការកៀបសង្កត់ដឹកនាំរបស់បក្សកុម្មុយនីស្តវៀតណាម ហើយគាត់បានប្រាប់ឈ្មោះខ្លះៗរបស់មេក្បត់ និងខ្សែរយៈ ដូចជា រស់ ញឹម, ឈូក, សោ ភឹម, កុយ ធួន, នង សួន។ល។ អៀង សារី ចង់ធ្វើឱ្យយើងដឹងនូវសារដ៏សំខាន់ គឺមហាគុណូបការៈរបស់ក្រុមគាត់ ដែលសម្រេចបាននូវខេមរយានកម្មបក្សកុម្មុយនីស្តខ្មែរ។ បើគ្មានខេមរយានកម្មនេះទេ ប្រទេសកម្ពុជាប្រហែលជាត្រូវប្រទេសវៀតណាមលេបជាអវសានទៅហើយ។ ហើយបើពួកយើងជាអ្នកដែលមកពីបរទេសគេធ្វើបាបនេះ ក៏ដោយសារតែមានភ្នាក់ងារបក្សកុម្មុយនីស្តវៀតណាម"។ លោកសាក្សី តើលោកមាន

ការអត្ថាធិប្បាយអ្វីពាក់ព័ន្ធទៅនឹងសម្រង់នៅក្នុងសៀវភៅរបស់លោកនេះទេ?

[១១:១១:៤៧]

**ឆ៖** បាទ ខ្ញុំនៅតែ ខ្ញុំគ្មានអត្ថាធិប្បាយទេ គ្រាន់តែជាការដែលខ្ញុំបានឃើញ ហើយខ្ញុំនៅតែជឿរហូតដល់សព្វថ្ងៃនេះ។ ហើយគាត់បាននិយាយដូច្នេះមែន។

**ស៖** សូមអរគុណលោកសាក្សី។ លោកបានរៀបរាប់អំពីកិច្ចប្រជុំទី២ ដែលលោកបានចូលរួម ហើយលោកបានរៀបរាប់បញ្ជាក់យ៉ាងច្បាស់នៅក្នុងសៀវភៅរបស់លោក។ នៅក្នុងសៀវភៅដែលមានលេខ D141/1.2។ ERN ជាភាសាបារាំង 00288100, ERN ជាភាសាខ្មែរ 00831254។ លោកបានរៀបរាប់អំពីកិច្ចប្រជុំទី២នេះ ខ្ញុំសូមអានកថាខណ្ឌនេះដើម្បីឲ្យមានយោបល់ឆ្លើបតបពីលោក។ លោកបានបញ្ជាក់ថា "នៅចុងខែតុលា មានការប្រជុំមួយដោយមានវត្តមាន អៀង សារី ផងដើម្បីជ្រើសរើសក្រុមដឹកនាំថ្មីនៅ ប-៣២។ ពេលនោះ ខ្ញុំអត់មានឡើងនិយាយអ្វីទេ ហើយធ្វើយ៉ាងណាដើម្បីកុំឲ្យគេចាប់អារម្មណ៍មកលើខ្ញុំ។ ខ្ញុំគ្រាន់តែចូលរួមប្រជុំតាមតម្រូវការ ហើយទះដៃតាមគេឯង។ លោក ហោ ណាំហុង ធ្វើជាប្រធានគណៈកម្មាធិការដែលមានសមាជិក៥នាក់។ អៀង សារី ធ្វើខទ្មេសនាមនូវអ្វីដែលគាត់បាននិយាយកាលពីប៉ុន្មានថ្ងៃមុន។ យើងចាប់ផ្តើមប្រយុទ្ធស្លាប់រស់ ប្រឆាំងនឹងវៀតណាម និងសហព័ន្ធឥណ្ឌូចិន។ ឬមួយគេស្លាប់ ឬមួយយើងស្លាប់? គ្មានមធ្យោបាយណាក្រៅពីនេះទេ ប្រជាជនកម្ពុជានៅតែជាមួយយើងដើម្បីប្រយុទ្ធតទល់នឹងអ្នកឈ្លានពានយើង។ វៀតណាមកាន់តែឯកោៗ សហគមន៍អន្តរជាតិនៅជាមួយយើង"។ លោកសាក្សី ខ្ញុំមានសំណួរដដែល តើឃ្លាដែលខ្ញុំកំពុងតែអានចេញពីសៀវភៅរបស់លោកនោះ តើលោកមានយោបល់អ្វីបន្ថែមទៅលើអ្វីដែលលោកបានសរសេរនេះទេ?

[១១:១៣:៤៧]

**ឆ៖** បាទ អត់មានទេ គឺខ្ញុំនៅតែយល់ឃើញថា របស់ដែលខ្ញុំសរសេរ គឺវាត្រឹមត្រូវតាមដែលខ្ញុំបានឮនៅពេលនោះ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីនិយាយឲ្យយឺតជាងអម្បាញ់មិញបន្តិច!

អញ្ជើញចុះ! ប៉ុនសូមឲ្យនិយាយឲ្យបានយឺត។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមកដល់សំណួរចុងក្រោយហើយលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៖**

**ស៖** តើលោកមានសរសេរកំណត់ហេតុប្រចាំថ្ងៃនៅក្នុងចន្លោះឆ្នាំ៧៦ ដែលលោកចូលមកកម្ពុជា ហើយនិងដើមឆ្នាំ៧៩ ដែរឬទេ?

**លោក អុង ថុងហឿង៖**

**ឆ៖** យើងខ្ញុំ គ្រួសារ -- ភរិយាខ្ញុំ និងខ្ញុំតែងតែលួចកត់ ជាពិសេសភរិយាខ្ញុំគឺសៀវភៅផ្នែកទី១ គឺឈរលើ *កាតណេ* កូនសៀវភៅរបស់ភរិយាខ្ញុំដែលបាន គាត់បានកត់។ បានកត់ ដល់ពេលខ្ញុំរត់ទៅដល់ស្រុកថៃ ខ្ញុំបានផ្អែកលើការដែលគាត់បានកត់នោះ សរសេរសៀវភៅខ្ញុំ ហើយអត្ថបទចុងក្រោយបន្ទាប់ពីខ្ញុំមកពីដីក្រហម គឺអាហ្នឹង ខ្ញុំឈរលើអ្វីដែលបានកត់ខ្លួនឯង។

**ស៖** សូមអរគុណ។ ដើម្បីឲ្យកាន់តែច្បាស់ទៀតនោះ គឺថានៅក្នុងផ្នែកទីមួយនៃរឿងរ៉ាវរបស់លោកនោះ គឺលោកផ្អែកទៅលើកំណត់ហេតុរបស់ប្រពន្ធរបស់លោក ហើយនៅពេលនៅដីក្រហម លោកបានកត់ត្រាដោយខ្លួនឯង ហើយយកលោកយកមកប្រើប្រាស់កំណត់ត្រានេះ ដើម្បីយកមកសរសេរជាសៀវភៅរបស់លោក។ តើអ៊ីចឹងមែនទេ?

[១១:១៦:២៣]

**ឆ៖** បាទអ៊ីចេះ គឺថាប្រពន្ធខ្ញុំមានកូនសៀវភៅតូចមួយគាត់បានកត់ពីពេលដែលគាត់ -- តាំងពីខ្ញុំមិនទាន់ដល់ស្រុក តើគាត់មាន -- ពេលចូលស្រុកហ្នឹងគាត់និយាយខ្លីៗ តើគាត់បានឃើញអ្វីខ្លះ? គាត់មានសតិអារម្មណ៍អ្វីខ្លះតាំងពី -- ហើយដល់ខ្ញុំចូលស្រុក គាត់បានបង្ហាញខ្ញុំ ហើយៗខ្ញុំគាត់ក៏លាក់ទុកវិញទៅ ហើយដល់រហូតដល់កំណត់នេះ គាត់បានធ្វើជារៀងរហូតដល់ៗៗនៅដីក្រហមបាទ។ ដល់ពួកយើងខ្ញុំចេញពីដីក្រហម ហើយបន្ទាប់ពីដីក្រហម គឺនេះឈរលើអាដែងសេចក្ដីកត់ត្រាផ្ទាល់ខ្លួនរបស់ខ្ញុំ។

**ស៖** ដើម្បីចូលខ្លឹមនៃសំណួររបស់ខ្ញុំ ខ្ញុំចង់ដឹងថាតើជំពូកដែលមានចំណងជើងថា "ភ្នំពេញក្រោម អៀង សារី" នេះដែលខ្ញុំបានអានអម្បាញ់មិញនេះ សម្រង់ទាំងពីរ។ តើជំពូកនេះត្រូវបានសរសេរដោយលោកពិគ្រោះមើលនូវកំណត់ត្រារបស់លោកមែនទេ? ជាពិសេសខ្ញុំចង់ដឹងថា តើលោកបានមានប្រភពអ្វីខ្លះដើម្បីយកមកសរសេរជំពូកមួយនេះ?

**ឆ៖** ខ្ញុំសរសេរឈរលើស្អីដែលខ្ញុំបានកត់ត្រាមក ដល់ពេលខ្ញុំដល់ជំរំខៅអ៊ីដាងនៅ -- រត់ទៅដល់ជំរំខៅអ៊ីដាង ជំរំប្រទេសសៀម ហើយនិងពិភាក្សាជាមួយភរិយារបស់ខ្ញុំ។

[១១:១៨:៣០]

**ស៖** សូមអរគុណលោកសាក្សី។ តើលោកសរសេរផ្នែកដំបូងនៃសៀវភៅនេះនៅពេលណា?

**ឆ៖** ពេលខ្ញុំរត់ទៅដល់ប្រទេសថៃ។ ក្នុងចុងឆ្នាំ១៩៧៩។

**ស៖** តើនៅពេលណាដែលលោកបោះពុម្ពសៀវភៅនេះ?

**ឆ៖** ខ្ញុំបោះពុម្ពនៅ២០០៣។ ហេតុដូចម្ដេចបានជាខ្ញុំបោះពុម្ពនៅ២០០៣? ពីព្រោះខ្ញុំសរសេរហើយក៏ទៅ។ ខ្ញុំថាទុកឲ្យកូនមើល ប៉ុន្តែថ្ងៃមួយមានលោក ហង់រី ឡូកា គាត់បានអាន ហើយគាត់ក៏ថាគាត់ ហើយនិងអ្នកផ្សេងទៀតដូចជា ដាវីដ ឆេនដ៍ល័រ ឬក៏ ស្ទីវ ហ៊្វិន ហេដឌ័រ ឬក៏អ្នកគេធ្លាប់ស្គាល់ខ្ញុំ គេថាម៉េចក៏មិនយកទៅបោះពុម្ព បោះផ្សាយដើម្បីចែកគេផ្សេងទៀតឲ្យបានដឹងផង? ខ្ញុំក៏សុខចិត្តធ្វើឲ្យអ្នករោង ពុម្ពបារាំងផ្សាយទៅបាទ។

[១១:២០:១២]

**ស៖** សូមអរគុណលោកសាក្សី។ នៅពេលដែលយើងអានសៀវភៅនេះទៅ យើងមានអារម្មណ៍ថា លោកបានសរសេរលាយឡំគ្នានូវរឿងរ៉ាវពិត ហើយនិងសក្ខីកម្មជាក់លាក់ ជាពិសេសការពិចារណាខាងផ្នែកនយោបាយ និងប្រវត្តិសាស្ត្រ។ តើលោកអាចពន្យល់ឲ្យបានច្បាស់ទេ អំពីរបៀបដែលលោកសរសេរសៀវភៅនេះ? ពីព្រោះថាសៀវភៅនេះត្រូវបានដាក់ទៅក្នុងសំណុំរឿង ហើយវាគឺជាភស្តុតាងដ៏សំខាន់មួយនៃសំណុំរឿង។ ដូច្នេះ ខ្ញុំចង់យល់អំពីរបៀបដែលលោកសរសេរសៀវភៅនេះ។

**ឆ៖** ជារួម ខ្ញុំសរសេរសៀវភៅនេះឈរលើ -- មិនមែនឈរលើការសងសឹក ឬក៏ឈរ -- ខ្ញុំមិនចង់និយាយពីថា អង្កាល់ពេលនោះ ពួកខ្មែរក្រហមធ្វើបាបពួកខ្ញុំយ៉ាងម៉េចខ្លះទេ។ អានេះមិនមែនជាសំខាន់ទេ គឺការងារសំខាន់របស់ខ្ញុំ ខ្ញុំចង់និយាយថា បើៗពួកយើង ពេលយើងរស់នៅគ្រប់កាលៈទេសៈណាក៏ដោយ បើសិនគេចាប់យើងឲ្យនៅកន្លែងមួយខ្វះសេរីភាព តើយើងម្នាក់ៗមានប្រតិកម្មរបៀបម៉េច? អានេះគឺថា ខ្ញុំចង់និយាយពីអ្វីៗដែលជាផ្លូវចិត្តរបស់ជនជាប់ចោទម្នាក់ៗ។ តើអ្នកនេះ គឺខ្ញុំយល់ឃើញថា មនុស្សម្នាក់ៗគឺក្នុង -- សូម្បីតែបុគ្គលខ្លួនឯងក៏យើងមានខុសគ្នា។ ជួនកាលបុគ្គលយើងវាៗមានទឹកចិត្តអ៊ីចេះ ជួនកាលវាមានទឹកចិត្តអ៊ីចុះ ហើយអ្នកផ្សេងទៀតក៏អ៊ីចឹង មានការផ្លាស់ប្ដូរ ហៅថាអត្តសញ្ញាណរបស់យើងម្នាក់ៗវាផ្លាស់ប្ដូរ វាមិនមែន មិននៅនឹងទេ។

[១១:២១:៥៩]

ជួនកាលគឺថា យើងអាចធ្វើល្អ ជួនកាលយើងអាចធ្វើមិនល្អ គឺអាហ្នឹងជាបទពិសោធន៍របស់ខ្ញុំ ហើយខ្ញុំមិននិយាយក្នុងទិសដៅធំ ហើយខ្ញុំមិនចង់និយាយថា អ៊ូ! ខ្មែរក្រហមវេទនាណាស់ នៅខ្មែរ

ក្រហមគេធ្វើបាបខ្ញុំអ៊ីចេះមួយ អ៊ីចេះពីរ អាហ្នឹងខ្ញុំអត់ចង់និយាយអ៊ីចឹងទេ។ ខ្ញុំចង់និយាយពីដូចខ្ញុំបានអត្ថាធិប្បាយជូនអំមិញ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមានសំណួរចុងក្រោយដើម្បីជាការបញ្ចប់។ ខ្ញុំចង់សួរទាក់ទងទៅនឹងចំណងជើងនៃសៀវភៅរបស់លោក "ខ្ញុំជឿខ្មែរក្រហម"។ សំណួររបស់ខ្ញុំចង់ដឹងថា តើនៅពេលណាដែលលោកជឿខ្មែរក្រហម ហើយចាប់ពីពេលណាមក ដែលលោកឈប់ជឿខ្មែរក្រហម?

**ឆ៖** និយាយមែនទែនទៅ វាមានបញ្ហា ខ្ញុំបើសិននិយាយថា ខ្ញុំដូចខ្ញុំបានអត្ថាធិប្បាយមកហើយខ្ញុំបាន -- បើសិនជាចង់និយាយថា ខ្ញុំគាំទ្រចលនាតស៊ូ ខ្ញុំគាំទ្រលោក ខៀវ សំផន ,លោក ហ៊ូ យន់, ហ៊ូ នឹម បើក្នុងន័យថា នេះជាខ្ញុំគាំទ្រខ្មែរក្រហម គឺខ្ញុំគាំទ្រខ្មែរក្រហមតាំងពីខ្ញុំមានអាយុ២៥ឆ្នាំអីមកបាទ។ តាំងពីដើមមក។

[១១:២៣:៣៣]

ប៉ុន្តែ ខ្ញុំសូមបញ្ជាក់បន្តិចគឺថា ការនេះមិនមែនបានន័យថាខ្ញុំ ៗ *អាទីត*-- ចំណងជើងសៀវភៅហ្នឹង មិនមែនជាចំណងជើងដែលខ្ញុំបាន ចំណងជើងជាបារាំង មិនមែនជាចំណងដែលខ្ញុំរើសខ្លួនឯងទេ ជាចំណងជើងដែលរោងពុម្ពគេអ្នកទទួលខុសត្រូវគេស្នើខ្ញុំ។ ដូច្នេះ -- ប៉ុន្តែ ខ្ញុំមិនដឹងជាខ្ញុំឆ្លើយសំណួរលោកស្រីត្រឹមត្រូវដែរអត់។

**ស៖** ខ្ញុំពេញចិត្តណាស់ចំពោះចម្លើយនេះ។ សូមអរគុណលោកសាក្សី ខ្ញុំអស់សំណួរហើយ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ បាទ ជាបន្តនេះ តើអស់លោក លោកស្រីចៅក្រមមានសំណួរអីសួរសាក្សីរូបនេះទេ?

សូមអញ្ជើញលោកចៅក្រមហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ សូមអរគុណលោកសាក្សីដែលបានផ្តល់សក្ខីកម្មនៅទីនេះ ហើយនិងការប្រឹងប្រែងមកដល់ទីនេះ។

[១១:២៤:៥៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សីខ្ញុំសូមត្រឡប់មកសួរសំណួរលោកមួយចំនួន ទាក់ទងទៅនឹងជំនួបរបស់លោកជាមួយលោក អៀង សារី នៅបឹងត្របែក។ ហើយខ្ញុំក៏ចង់ដកស្រង់សម្រង់មួយដើម្បីបន្ថែមលើសម្រង់ដែលបានលើកឡើងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺថាត្រូវយោងទៅសៀវភៅរបស់លោក គឺថាឯកសារ D141/1.2 ទំព័រ២១៤ ហើយនិង២១៥ នៃសៀវភៅរបស់លោក គឺថា ERN លេខ ជាភាសាបារាំងលេខ 002890 និង 80 និង 93 ទៅដល់ 94, ជាភាសាអង់គ្លេស គឺ 00785878 ទៅដល់ 79, ERN ជាភាសាខ្មែរ ខ្ញុំពិបាកបន្តិចពីព្រោះថា ឃើញមានលេខ ERN ដូចតទៅនេះ គឺថា 00659077 ទៅដល់ 95 នៅចុងកន្ទុយ។ បាទ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីជំនួបរបស់លោកជាមួយលោក អៀង សារី ហើយនិងលើអ្វីដែលលោកបាននិយាយ ទាក់ទងទៅនឹងសេចក្តីប្រកាសរបស់លោក អៀង សារី ទាក់ទងនឹង វ៉ាន់ ពីនី។

[១១:២៦:៣០]

លោកនិយាយដូចតទៅនេះ៖ "រដ្ឋមន្ត្រីចាត់តាំងម្នាក់ផ្សេងទៀត ដែលជាថា សមាសភាពមិនល្អមកពីបរទេស ហើយ វ៉ាន់ ពីនី ដែលត្រូវបានឆ្លើយដាក់ដោយឯកសារចំនួនបីថា ជាប់ពាក់ព័ន្ធនឹង សេ.អ៊ី.អា ហើយនិង អេស.ដេ.អឺ.សេ.អឺ ត្រង់ចំណុចនេះលោកបានថា ពីមុនគាត់បញ្ជាក់ថា ត្រូវការតែពីរឯកសារទេ តែឥឡូវនេះ ត្រូវតម្រូវឱ្យមានបី ដើម្បីអាចចាប់មនុស្សម្នាក់បាន"។ សំណួរខ្ញុំដូចតទៅនេះ លោកបានបើកអព្ភន្តរដាក់ពាក្យសម្រង់ តើលោកអាចបញ្ជាក់ ឬក៏រំឭកថា នេះជា -- នៅក្នុងអព្ភន្តរនេះ ជាពាក្យពេចន៍របស់ អៀង សារី ដោយផ្ទាល់ ឬក៏យ៉ាងម៉េច?

**ឆ៖** នេះជា -- ខ្ញុំអះអាងថា នេះជាពាក្យពេចន៍ដែលខ្ញុំចាំ អៀង សារី ពីព្រោះអ៊ីចេះ! ពីព្រោះ វ៉ាន់ ពីនី ជាមនុស្សដែលខ្ញុំស្គាល់យូរហើយ ហើយគាត់ជាត្រូវជាមិត្តភក្តិរបស់បងខ្ញុំក្តី ហើយដូច្នេះខ្ញុំៗតែងតែមានការរាប់អានគ្នាយូរហើយ។ ដូច្នេះពាក្យនិយាយអីពី អៀង សារី -- អ៎! និយាយពី វ៉ាន់ ពីនី ធ្វើឱ្យខ្ញុំចាប់ជាងគេ។ ដូច្នេះ ខ្ញុំអាចអះអាងថា ជាពាក្យដែល អៀង សារី បាននិយាយមែន។

[១១:២៨:៣០]

**ស៖** បាទ សូមអរគុណ។ បាទឥឡូវខ្ញុំសូមបន្តអានសៀវភៅលោកទៀត ពីព្រោះថាបន្តិចទៀតលោកនិយាយរឿងមួយដែលគួរឱ្យចាប់អារម្មណ៍។ បាទ ខ្ញុំសូមអានម្តងទៀត "អៀង សារី បន្តធ្វើបទ

បង្ហាញទៀត ដោយនិយាយថា កម្ពុជាកំពុងតែឈានទៅកាន់ប្រជាធិបតេយ្យដ៏មហាសាល។ ដើម្បីទៅដល់ប្រជាធិបតេយ្យមហាសាលនេះ គាត់ឲ្យឧទាហរណ៍លើមិត្តភក្តិមួយចំនួនដែលបានទិតៀន សារ៉ែន"។ បាទ នេះនៅក្នុងកិច្ចប្រជុំមួយនៅបឹងត្របែកដែលមនុស្សមួយចំនួនទិតៀន សារ៉ែន ហើយលោកលើកឡើងពាក្យពេចន៍មួយចំនួនដែលលោកថា នេះជាពាក្យពេញរបស់ អៀង សារី ដែលថា "មិនមែនជាការងាយស្រួលនោះទេ ជារឿយៗពេលដែលយើងជួបប្រជាជន ឧទាហរណ៍នៅឈូកជាដើមនៅកំពតនោះ។ ខ្ញុំចោទសំណួរទៅអ្នកដែលនៅសហករណ៍ថា តើគាត់បានអាហារបីពេលក្នុងមួយថ្ងៃដែរឬទេ? ពីដំបូងពួកប្រជាជនទាំងអស់នោះ មិនហ៊ានឆ្លើយទេ ប៉ុន្តែដល់ពេលដែលគេទុកចិត្តខ្ញុំហើយ គេឆ្លើយថា អត់បានបីពេលក្នុងមួយថ្ងៃទេ។ ហើយក្នុងពេលនេះ ខ្ញុំក៏ចោទសួរថា ម៉េចក៏គាត់មិនសុំអាហារបីពេលមួយថ្ងៃទៅប្រធានសហករណ៍ ហើយបងប្អូនយើង កសិករយើងហ្នឹងមានរឿងរ៉ាវជាច្រើនដែលត្រូវនិយាយ ក៏ប៉ុន្តែពួកគេមិនហ៊ានប្រើសិទ្ធិសេរីភាពរបស់ខ្លួននោះទេ។ ដូច្នេះ យើងបានបង្កើតវិធីសាស្ត្រថ្មីមួយទៀត ដើម្បីជំរុញគាត់ឲ្យហ៊ាននិយាយ។ ខ្ញុំប្រាប់គាត់ថា មិនត្រូវភ័យទៀតទេ គុកលែងមានទៀតហើយនៅប្រទេសយើង។ មុន ពីមុនយើងឃើញឮពាក្យគេប្រទេចជាច្រើន អាគុក អាជាប់គុក ឬក៏អាគុកច្រវាក់ ឬក៏អាអ្នកជាប់គុកថោកទាប"។ បាទ នៅត្រង់ចំណុចនេះ ខ្ញុំចង់ដឹងថាបើតាមលោកចាំនោះ តើពាក្យពេចន៍ទាំងអស់នេះជាពាក្យពេចន៍របស់លោក អៀង សារី ដែរឬទេ?

[១១:៣១:០០]

**ឆ៖** ខ្ញុំអាចអះអាងថា ពាក្យពេចន៍នេះជាពាក្យពេចន៍របស់ អៀង សារី ដែលខ្ញុំចាំ។

**សៈ** បាទ ឥឡូវខ្ញុំសូមបន្តអានទៀត "និយាយទៅដូចអធិកអធម ដូចពេញចិត្តខ្លួនឯង គាត់បន្តថា យើងត្រូវតែបញ្ឈប់ប្រើពាក្យ គុក។ គុកលែងមានទៀតហើយនៅប្រទេសយើង។ នៅលើឆាកអន្តរ-ជាតិ នយោបាយបរទេសរបស់យើងឈរនៅលើមូលដ្ឋាន គឺថាអធិបតេយ្យភាពជាតិ ហើយនិងត្រូវបានប្រទេសបរទេសទាំងអស់គាំទ្រ ជាពិសេសប្រទេសមិនចូលបក្សសម្ព័ន្ធ។ ពួកសេរីនិយមសូវៀត ហើយនិងពួកចូលដៃចូលជើងវៀតណាមកាន់តែឯកោទៅៗហើយ។ ដើម្បីប្រឆាំងសត្រូវខាងក្រៅ យើងត្រូវជាដំបូងត្រូវតែកម្ទេចសត្រូវខាងក្នុងសិន។ បក្សយើងបានឈ្នះលើសត្រូវខាងក្នុងហើយ។ បើពុំមានពួកចូលដៃចូលជើងនៅខាងក្នុងទេ ពួកឈ្លានពានវៀតណាមនឹងមិនអាចឈ្នះលើយើងបាននោះទេ"។ ហើយសូមបញ្ជាក់ ដកស្រង់នៅត្រង់នេះ ហើយពាក្យនេះនៅក្នុងអត្ថន្តរ "ហើយបន្ទាប់មកទៀតគាត់ -- លោក អៀង សារី បានឲ្យយើងនិយាយ ហើយឲ្យប្រើប្រាស់សេរីភាពរបស់យើងនៅក្នុងប្រទេសតែមួយគត់ គឺ

ថាយើងអាចនិយាយអ្វីក៏បានដែរ គ្មានអ្នកណាហ៊ានធ្វើបាបអ្វីយើងទេ ដោយហេតុថាលែងមានគុកទៀតហើយ”។ ហើយត្រង់ចំណុចនេះ តើពាក្យពេចន៍ទាំងអស់នេះ លោកចាំថាពាក្យពេចន៍ទាំងអស់នេះពិតជាបាននិយាយដោយលោក អៀង សារី មែនទេ?

[១១:៣២:៥៧]

**ឆ៖** បាទ ខ្ញុំអាចសន្និដ្ឋាន ស្បថថា ខ្លឹមសារនៃពាក្យទាំងនេះជាពាក្យដែលលោក អៀង សារី បាននិយាយនៅពេលនោះ។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី លោកជាសាក្សីមិនអាចផ្តល់ចម្លើយជាសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួនរបស់លោកតបទៅនឹងសំណួរទេ។

**លោក អ៊ុង ចុងហឿង៖**

សូមគោរពលោកប្រធាន ប្រហែលជាមិនយល់នៃសេចក្តីឆ្លើយរបស់ខ្ញុំបាទ។ ខ្ញុំបាទចង់និយាយថា សេចក្តីដែលខ្ញុំបានឮអម្បាញ់មិញ គឺជាសេចក្តីដែលខ្ញុំបានចងចាំ មិនមែនជាសេចក្តីស្មានទេបាទ។ សូមបញ្ជាក់។ ខ្ញុំបានចងចាំថា លោក អៀង សារី បាននិយាយនៅពេលប្រជុំនេះពិតប្រាកដមែន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** បាទ លោកសាក្សី បើតាមលោកចាំ តើលោកគិតថា អ្នកដែលលោកបានជួបទាំងប៉ុន្មាននោះមានសិទ្ធិសុំអាហារគ្រប់គ្រាន់ នៅពេលដែលខ្លួនមិនមានអាហារគ្រប់គ្រាន់។ តើនៅសម័យនោះសិទ្ធិសុំទាមទារអាហារគ្រប់គ្រាន់នេះមានដែរឬទេ?

[១១:៣៥:០៣]

**លោក អ៊ុង ចុងហឿង៖**

**ឆ៖** បាទ តាមខ្ញុំចាំ គឺគ្មានទេបាទ អាហារគ្រប់គ្រាន់ គឺគ្មានដាច់ខាត។ គ្មានសិទ្ធិទេ គ្មានសិទ្ធិមានអាហារគ្រប់គ្រាន់ទេ។

**ស៖** ហើយអ្នកដែលលោកបានជួប ហើយបើតាមបទពិសោធន៍របស់លោកនៅក-១ នៅបឹង-- អ៎! ក-១៥ សូមទោស នៅនៅបឹងត្របែក និងនៅដីក្រហមជាដើម ឬកន្លែងផ្សេងទៀត នេះជាបទពិសោធន៍ ស្ថិតនៅក្នុងមន្ទីរឃុំឃាំង ហើយនៅពេលដែលលោកនិយាយ ឮអម្បាញ់មិញថា ពេលលោក អៀង សារី ថា នៅកម្ពុជាប្រជាធិបតេយ្យពុំមានគុកនោះ តើពេលលោក អៀង សារី និយាយដូច្នេះនេះ

មិនបានបង្កឲ្យមានប្រតិកម្មអ្វីទេឬ?

**ឆ៖** បាទពេលនោះ ខ្លួនខ្ញុំផ្ទាល់ភ្ញាក់ខ្លួនហើយ ខ្ញុំគិតថាវា យើងនៅក្នុងគុកហើយ គុកទូទាំងប្រទេសហើយ គាត់និយាយអីក៏បានដែរ។ ប៉ុន្តែខ្ញុំអត់ហ៊ានធ្វើបាតុកម្មអីទេ ព្រោះ គ្រាន់ស្តាប់អ៊ីចឹងទៅបាទ ខ្ញុំមិនហ៊ានទេបាទ។ ប៉ុន្តែ ខ្ញុំៗតាំងខ្លួនខ្ញុំថា ពួកយើងខ្ញុំនៅក្នុងគុកហើយ ហើយទូទាំងប្រទេសកម្ពុជាពេលនោះគុក ជាគុក។

**ស៖** ឲ្យជាក់ច្បាស់ជាងនេះទៀត ក្រោយពីពេលជួបគ្នានេះហើយ នៅពេលដែលលោកបានឮគាត់និយាយទាំងអម្បាល់មាននេះហើយ តើគាត់មានប្រាប់លោកថា លោកមានសិទ្ធិសេរីភាពក្នុងការចាកចេញពីបឹងត្របែក លោកអាចទៅកន្លែងណាក៏បាន លោកអាចទៅជួបក្រុមគ្រួសារលោកបានដែរឬទេ? គេបានផ្តល់ប៉ាស្ព័រឲ្យលោកវិញដែរឬទេ?

[១១:៣៧:២៥]

**ឆ៖** ទាំងអស់នេះអត់មានទេបាទ គ្រាន់តែៗសម្តីដែលគាត់និយាយហ្នឹង គ្រាន់តែនិយាយដើម្បីពេញចិត្តខ្លួនឯងអ៊ីចឹង ប៉ុន្តែវាអត់ឈរលើជាក់ស្តែង ការពិត ពួកយើងខ្ញុំនៅតែជាប់។ ពិតមែនតែ គេឲ្យហូបចុកអីស្រួលបួល គ្រាន់បើជាងមុន គេបញ្ចុកបន្ទី ជួនកាលគេយកក្រពើមកឲ្យញ៉ាំ អំ! មកឲ្យហូបនៅបឹងត្របែកអ៊ីចឹង។ ប៉ុន្តែគ្រាន់ថា ជាគ្រាន់តែផ្តល់អ្នកជាប់គុកហ្នឹងឲ្យសប្បាយ ប៉ុន្តែអ្នកជាប់គុកយូរហើយ ដល់បានហូបចុកសប្បាយដែរ ព្រោះយើងតែជាប់គុកយូរ វាដូចជាស៊ុំបន្តិចដែរអង្កាល់ហ្នឹងបាទ។ បើបានគេឲ្យសម្រួលបន្តិចមកដូចធូរស្រាល។ ប៉ុន្តែសិទ្ធិទៅដើរហើរទៅណា ទៅស្រុកបារាំងវិញ ទៅជួបមិត្តភក្តិនៅក្រុងប៉ារីសអីអាហ្នឹង តាមមើលគ្មានពីណាស្រមៃអ៊ីចឹងទេបាទ។

**ស៖** លោកសាក្សី នៅពេលណាមួយក្នុងបទពិសោធន៍របស់លោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ គេមានបានផ្តល់យុត្តិកម្ម ដែលអាចពន្យល់ពីការឃុំឃាំងខ្លួនលោកដែរឬទេ? តើមានហេតុផល ផ្លូវច្បាប់អីណាមួយទេ? តើគេមានបានប្រាប់លោកថា មានប្រព័ន្ធ ឬក៏នីតិវិធីណាមួយដែលអាចអនុញ្ញាតឲ្យលោកជំទាស់នឹងការឃុំខ្លួនរបស់លោកនៅកន្លែង ដែលលោកស្នាក់នៅ នៅក្នុងរបបខ្មែរក្រហម?

[១១:៣៩:២២]

**ឆ៖** និយាយរួម គឺថាយើង នៅពេលនោះ និយាយឲ្យច្បាស់ គឺថា អ្វីដែលត្រឹមត្រូវគឺ អង្គការ ឬក្រោយមក ពេលយើងខ្ញុំមកដីក្រហមវិញ គេប្រើពាក្យ “គណបក្សកុម្មុយនីស្តកម្ពុជា” ហើយខ្ញុំយក

ឧទាហរណ៍គេថា អៀង សារី គាត់ថា យើងមានសិទ្ធិនិយាយ បើឧបមា នៅឈូកអ៊ីចឹង គាត់ទៅជួប អ៊ីចឹង មានសិទ្ធិថា ហូបបាយបីពេល គាត់សួរអត់ប៉ាន។ ហើយយើងដូច្នេះ ក៏ថា អ្នកទិតៀន សាវ៉ន ហ្នឹង វាត្រឹមត្រូវ គាត់ថាអ៊ីចឹង។ ពីព្រោះ -- ហើយហ្នឹងគាត់ថាអ៊ីចឹង ហ្នឹងជាពាក្យដែលគាត់និយាយ។ ប៉ុន្តែជាក់ស្ដែងយ៉ាងម៉េច? ជាក់ស្ដែងនៅក្នុងរបប គេហៅរបបដែល *(ឮមិនច្បាស់)* និយម បើពេល -- ព្រោះថា សាវ៉ន។ សាវ៉ន ជានរណា? សាវ៉ន ជាអង្គការ។ គឺអង្គការ បើយើងនិយាយទិតៀន សាវ៉ន ឧបមាពេលនោះយើងថា ប៉ុល ពត ធ្វើហ្នឹងអត់ត្រឹមត្រូវ ប៉ុល ពត មានការខ្វះខាត គឺថាបើជាស្ដេច គាត់អាចនិយាយថា ស្ដេចហ្នឹង គេគាត់ជាសោយរាជ្យ គាត់មានការខ្វះខាតបាន ប៉ុន្តែបើរបបដូច ប៉ុល ពត អ៊ីចឹង បើ ប៉ុល ពត សារភាពថា គាត់មានការខ្វះខាត អង្គការមានការខ្វះខាត អាហ្នឹងរបបហ្នឹង វារលាយឯងហើយ។ ដូច្នេះ គេមិនអាចអនុញ្ញាតឲ្យថា អង្គការខ្វះខាត សាវ៉ន ខ្វះខាត ឬក៏អ្នកណាត្រួត យើងខ្វះខាតទេ គឺគេថា យើងអ្នកជាប់គុកហ្នឹង ខ្វះខាត អាហ្នឹងមានសិទ្ធិនិយាយអ៊ីចឹង។ ប៉ុន្តែអង្គការ អ្នកខ្វះខាត អាហ្នឹងអត់មានទេបាទ។ អត់មាន អង្គការអ្នកខ្វះខាត អត់មាន អង្គការធ្វើខុស អត់មាន ព្រោះអង្គការ ពេលណាអង្គការថា ខ្ញុំអង្គការខុស អាហ្នឹងវា អាការស្របច្បាប់គេប៉ុន្មានមកវារលាយ បាត់អស់ហើយ។ ខ្ញុំសូមឆ្លើយអ៊ីចឹង អានេះជាការសង្កេតរបស់ខ្ញុំបាទ។

[១១:៤១:៥៨]

**សះ** បាទ ជាសំណួរលម្អិត។ លោកបាននិយាយនៅក្នុងសៀវភៅរបស់លោកថា បានចូលរួម ក្នុងការកម្ទេច ការដ្ឋានកម្ទេចព្រះវិហារមួយនៅទីក្រុងភ្នំពេញ។ តើលោកអាចជម្រាបជូនតុលាការបាន ទេ អំពីមូលហេតុនៃការកម្ទេចព្រះវិហារហ្នឹង?

**ឆះ** បាទ អាហ្នឹង កាលហ្នឹងខ្ញុំនៅទើបមកដល់ស្រុកបានបន្តិច ខ្ញុំនៅក-១៥ នៅឡើយ។ យប់ មួយនោះគេឲ្យពួកខ្ញុំមួយចំនួន មិនដឹងប៉ុន្មាននាក់ទេ គ្នាជាងដប់នាក់ ឲ្យជិះឡានកាម្មុងទៅធ្វើការងារ។ ដល់ទៅគឺថា ទៅដល់ឃើញខ្ញុំមិនដឹងនៅណាច្បាស់ហើយទេ កាលហ្នឹងយប់ ប៉ុន្តែដូចថា ទៅដល់គឺ ពួកខ្ញុំទៅឃើញមនុស្ស ឮសូរពេលជិតទៅដល់ឮសូរមនុស្សរាប់ ឮសូរសំឡេងមនុស្សច្រើនមែនទែន។ ដល់ខ្ញុំ ពួកខ្ញុំទៅដល់ទៅក៏គេឲ្យយើងទាំងអស់គ្នាហ្នឹងរ៉ៃៗថ្ម រ៉ៃសសរថ្មធំៗហ្នឹង ដើម្បីទិសដៅគេយក ដែក។ បាទទិសដៅគេយកដែក។ ហើយឮពួកហ្នឹងទាំងអស់ហ្នឹង គេថា អាទាំងអស់ហ្នឹងចេញពីវិហារ ដែលនៅមុខស្ថានីយ៍រថភ្លើងបាទ។

[១១:៤៣:៤៣]

**ស៖** នៅសម័យនោះ អង្គាល់នោះតើលោកដឹងថា អគារហ្នឹងជាអគារអ្វីទេ? ឬក៏លោកអត់ដឹងថា អគារហ្នឹងជាអគារអ្វីទេ?

**ឆ៖** ខ្ញុំដឹងថា អគារហ្នឹងជា ខ្ញុំធ្លាប់ឃើញអង្គាល់ពីខ្ញុំនៅពីតូច។ បាទ ខ្ញុំដឹងថា អគារហ្នឹងជាវិហារកាតូលិក។

**ស៖** តើមូលហេតុនៃការកម្ទេចព្រះវិហារនោះ គេមានបានប្រាប់ពីមូលហេតុហ្នឹងទេ ជូនលោក? តើគេកម្ទេចដោយសារតែអាហ្នឹងជាវិហារកាតូលិក ឬក៏មានមូលហេតុអីផ្សេងក្រៅពីការដែលថា កម្ទេចដោយសារតែអាហ្នឹងជាវិហារកាតូលិក?

**ឆ៖** កាលនោះ គេអត់មាននិយាយអីទេ ឃើញបងប្អូនយប់ហើយ វាសស្រាក់សស្រាំធ្វើគេឲ្យហើយទៅដល់ភ្លាម គេឲ្យពូថៅមួយ ញញួរវ៉ៃក៏ចេះតែវ៉ៃហ្នឹងគេទៅ ប៉ុន្តែអត់មានអ្នកណាពន្យល់ធ្វើអីទេបាទ។ គ្រាន់តែថា ខ្ញុំវ៉ៃរួមចំណែកនឹងគេដែរ វ៉ៃនឹងគេអ៊ីចឹងទៅ ហើយប៉ុន្តែដល់ថ្ងៃក្រោយ ខ្ញុំមើលអាដែកដែលវ៉ៃ ពិបាកវ៉ៃដែរ ប៉ុន្តែឃើញ ដល់ខ្ញុំមក អេស-ទ្រាំងតែអង នេះ ខ្ញុំឃើញអាដែងដែកគេ គេធ្វើទារុណកម្មជន ដែលគេចាប់នោះ គឺខ្ញុំឃើញហ្នឹង ខ្ញុំមិនដឹងជាដែកហ្នឹង វាមកពីណា ប៉ុន្តែខ្ញុំសតិអារម្មណ៍ខ្ញុំឃើញ ចុម! តិចអាដែកហ្នឹង មកពីហ្នឹងដឹង ចេះតែសួរខ្លួនឯង ប៉ុន្តែខ្ញុំគ្មានអីច្បាស់ទេ អាហ្នឹង។

[១១:៤៥:៥៧]

**ស៖** ខ្ញុំមានសំណួរមួយទៀត នៅក្នុងសៀវភៅរបស់លោក លោកនិយាយជាច្រើនដង ឈ្មោះសហការីរបស់លោក អៀង សារី។ លោកនិយាយថា គាត់ឈ្មោះ ជាប ហើយលោកក៏និយាយផងដែរថា គាត់ជាអ្នកដែលមកទទួលលោក នៅពេលដែលវៀមណាមចូលមកដល់។ តើលោកចាំឈ្មោះ ជាប នេះទេ? ឬក៏ ជាម ទេ?

**ឆ៖** ខ្ញុំឃើញមុខគាត់ ប្រហាក់ប្រហែល ព្រោះថ្ងៃមុន ខ្ញុំឃើញមុខគាត់នៅក្នុងកាសែត ឃើញនិយាយ គាត់មកធ្វើនៅអង្គុយកន្លែងហ្នឹង ដូចខ្ញុំប៉ុន្មានថ្ងៃមុន ឃើញដូចគាត់ហ្នឹងហើយ ប្រហាក់ប្រហែល ប៉ុន្តែប្រហែលជាគាត់ហ្នឹង។ គាត់ធ្វើជាដៃស្តាំរបស់ សួរ ហុង។

**ស៖** បើខ្ញុំមិនប្រាកដថា យល់ចម្លើយរបស់លោកទេ។ លោកចង់និយាយថា ពេលដែលលោកឃើញរូបថតរបស់ ជាម នៅក្នុងកាសែតនោះ លោកគិតថា លោកហ្នឹងហើយ ដែលលោកហៅថា ជាបនៅក្នុងសៀវភៅលោកនោះ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំមិនប្រាកដ១០០ភាគរយ ប៉ុន្តែខ្ញុំសង្ស័យបាទ។

[១១:៤៧:៥១]

**ស៖** លោកបានរៀបរាប់ អំពីបទពិសោធន៍ផ្ទាល់ខ្លួនដ៏ឈឺចាប់របស់លោក ជូនតុលាការ។ ខ្ញុំមានសំណួរមួយចោទសួរទៅលោក បើសិនជាសំណួរនេះ ធ្វើឱ្យលោកក្ដុកក្ដួលក្នុងចិត្ត លោកមិនបាច់ឆ្លើយទេ។ តើលោកអាចជម្រាបជូនបានទេ ថាក្រោយពីឆ្លងកាត់បទពិសោធន៍កម្ពុជាប្រជាធិបតេយ្យនោះ លទ្ធផលចំពោះគ្រួសារលោក ហើយនិងអ្នកញាតិ មិត្តជិតស្និទ្ធរបស់លោក ពីព្រោះថាលោកមានសមាជិកក្រុមគ្រួសារជាច្រើន។ តើលោកអាចរៀបរាប់ប្រាប់តុលាការអំពីអ្វីដែលលោកបានឆ្លងកាត់ ហើយនិងអារម្មណ៍ ដែលលោកទទួលរងរហូតដល់ពេលនេះ?

**ឆ៖** អារម្មណ៍ដែលខ្ញុំទទួលពេលនេះ គឺថានិយាយសរុបទៅ គ្រួសារខ្ញុំត្រូវរលត់រលាយ ឪពុកខ្ញុំគេចាប់ មិនដឹងគាត់ស្លាប់នៅណា។ ឪពុកខ្ញុំ ឪពុកផ្ទាល់របស់ខ្ញុំ គេចាប់ៗ។ គិតទៅ ខ្ញុំចេះតែគិតថា ពេលខ្ញុំមកដល់ស្រុកហ្នឹង គេចាប់ថ្ងៃប្រហាក់ប្រហែលគ្នា ហើយដល់ខ្ញុំស្រាវជ្រាវទៅ ហើយបន្ទាប់មកខ្ញុំមានបងប្រុសប្អូននាក់ទៀត ហើយនិងបងប្រុស និងប្អូនប្រុសប្អូននាក់ ហើយនិងប្រពន្ធគេ បងថ្លៃខ្ញុំ និងក្មួយៗស្លាប់។ នៅសល់ក្មួយមួយ ដែលរត់ -- អ៎! ដែលបានរស់ នៅរស់ ក្រៅពីនោះ ស្លាប់អស់ បងប្អូនប្អូននាក់ គ្រួសារគាត់ និងកូនក្មួយៗ កូនចៅគាត់ និងឪពុកខ្ញុំបាទ។ ហើយមិត្តភក្តិដែលខ្ញុំ ជំនាន់ខ្ញុំភាគច្រើន ហើយមិត្តភក្តិហ្នឹង គេជាមិត្តភក្តិដែលខ្ញុំរស់នៅជាមួយគ្នានៅកម្ពុជាក្ដី មកពីបរទេសក្ដី គឺភាគច្រើនបានស្លាប់អស់។ គឺដែល ដូច្នេះគឺថាជីវិតខ្ញុំ ពេល រយៈពេល៤ឆ្នាំនោះ គឺថា ធ្វើឱ្យអ្វីៗដែលមានជាសុភមង្គលក្នុងជាមនុស្ស វាអស់។ ប៉ុន្តែខ្ញុំមានសតិអារម្មណ៍មួយដែរ ពីព្រោះថា ខ្ញុំមកនេះ ខ្ញុំមិនមែនមកដើម្បីចង់សងសឹកអ្នកនេះ អ្នកនោះទេ ប៉ុន្តែគ្រាន់ចង់ ខ្ញុំថាខ្ញុំមកដើម្បីធ្វើអ្វីមួយដើម្បីកុំឱ្យ មិនមែនថាមិនឱ្យទេ ប៉ុន្តែរួបរួមវិភាគទានធ្វើអ្វីមួយ កុំឱ្យការព្រៃផ្សៃបែបនេះកើតមានដល់ជំនាន់ក្រោយទៀត។ នេះជាទិសដៅដ៏ស្លូតស្ដើងរបស់ខ្ញុំមកនេះ។ ប៉ុណ្ណឹងបាទ។ ខ្ញុំមិនមែនមកចង់សងសឹងអីទេ ប៉ុន្តែការនេះជាៗ វាកន្លងផុតទៅហើយ។ ហើយគ្មានអ្វីមកអាចមកផ្សះផ្សាបានទេ។ គ្រាន់ថា យើងត្រូវ យើងរស់នៅយើងត្រូវធ្វើយ៉ាងម៉េច កុំឱ្យរបៀបនេះ ការកាប់សម្លាប់គ្នាបែបនេះ កើតមានឡើងទៀត។

ហើយខ្ញុំយល់ថា ការទាំងអស់នេះ វាកើតមានឡើងដោយសារយើង ដោយសារមនុស្សយើង វាៗជាមនុស្សល្អ វាល្អផង វាអាក្រក់ផង។ គឺថាមនុស្សយើងម្នាក់ៗ គឺថាវាមានធាតុពីរ ធាតុល្អ ធាតុអាក្រក់។ ដូច្នេះហើយធាតុអាក្រក់ហ្នឹង វាអាចធ្វើឱ្យយើងខ្មែរខ្មៅដូចជំនាន់ខ្មែរក្រហមអ៊ីចឹង។

[១១:៥២:១៧]

**ស៖** សមាជិកគ្រួសារលោកមួយចំនួនរស់នៅទីក្រុងភ្នំពេញនៅពេលនោះ តើនៅក្នុងអ្នកដែលរស់មានជីវិតនោះ មានអ្នកណាខ្លះដែលរៀបរាប់អំពីបទពិសោធន៍នៃការជម្លៀសចេញពីទីក្រុងដែរឬទេ លោកអាចជម្រាបជូនតុលាការបន្តិចបន្តួចបានទេ ទាក់ទងនឹងការជម្លៀសចេញពីទីក្រុងភ្នំពេញនោះ?

**ឆ៖** បាទ គ្រួសារខ្ញុំនៅផ្លូវពោធិ៍ចិនតុងជិតកន្លែងក-១៥ ផ្ទះមាននៅសម័យនោះ គឺខ្ញុំមានបងមួយគាត់ធ្វើជាទូត ហើយគាត់មានផ្ទះមួយ។ ហើយដល់ពេលច្របូកច្របល់កើតសង្គ្រាមទៅគ្រួសារខ្ញុំ -- ឪពុកម្ដាយខ្ញុំបានមករស់នៅ ភៀសខ្លួនមករស់នៅផ្ទះបងខ្ញុំ ហើយក្នុងនោះមានដូចគ្រួសារខ្មែរផ្សេងទៀតគាត់បានយកក្មួយៗអីមកនៅជាមួយច្រើនគ្នានៅក្នុងផ្ទះហ្នឹង ផ្ទះបងខ្ញុំ ដែលបងខ្ញុំ គាត់នៅបរទេសឯណោះ។ ហើយដល់ពេលជម្លៀសតាមម្ដាយខ្ញុំ ហើយនិងប្អូនខ្ញុំដែលរស់នៅ គាត់នៅរស់ គាត់បាននិយាយគឺថា ដល់ជម្លៀសភ្លាម គាត់អត់ទាន់ចេញទេ គាត់នៅផ្ទះនៅពោធិ៍ចិនតុងហ្នឹង ហើយដល់តាមគាត់ក្ដាប់បាន ពីរថ្ងៃក្រោយមកបានគាត់ជម្លៀសទៅ។ ពេលជម្លៀសហ្នឹង គាត់បានឃើញថាមានគាត់ បងខ្ញុំមានបងមួយគាត់ធ្វើជា -- គាត់ធ្លាប់បួស ហើយគាត់ក្រោយមកគាត់ធ្វើជាសាស្ត្រាចារ្យនៅ-- ហ្នឹងជាបងប្រុស។ សាស្ត្រាចារ្យមហាវិទ្យាល័យភ្នំពេញ ហើយគាត់ ពេលនោះគាត់ប្អូនស្រីខ្ញុំ បងខ្ញុំហ្នឹងគេហែកឪបួម ហែកអីលាក់ទៅតាមផ្លូវហ្នឹងទៅ។ ហើយគាត់ក៏ឃើញមានការកាប់សម្លាប់គ្នានៅតាមផ្លូវរហូត។ ទៅគាត់ទៅ គាត់ធ្វើដំណើរ -- ខ្ញុំនិយាយសរុបទៅ គាត់ធ្វើដំណើររហូតដល់ស្រុកកំណើតម្ដាយខ្ញុំនៅសាម៉លារ នៅស្រុកព្រៃកប្បាស។ គាត់ទៅៗ ហើយនៅបានមួយរយៈ ខាងណោះគេ ខាងព្រៃកប្បាសហ្នឹងគេមិនព្រមទទួល។ ហើយណាមួយទៀត ឪពុកខ្ញុំគាត់ជាអ្នកស្រុកទន្លេ គាត់ដូចថាគាត់វាចង់ទៅរកឃើញស្រុកកំណើតរបស់គាត់វិញ។ គាត់ក៏ចេះ គេមិនចង់ឲ្យគាត់នៅស្រុកសាម៉លារហ្នឹងផង ហើយគាត់ចង់ទៅជួបបងប្អូន គាត់មានបងគាត់ពីរ -- គ្រួសារគាត់នៅបងគាត់២នាក់។ បងស្រីគាត់២នាក់ គាត់ចង់ទៅរស់នៅ -- ព្រោះផ្ទះខ្ញុំនៅមាត់ទន្លេឯណោះ។ ដូច្នេះគាត់ក៏ៗរកមធ្យោយទៅ -- ដឹកគ្រួសារទៅស្រុកកំណើតខ្ញុំហ្នឹងទៅ នៅមាត់ទន្លេៗ។ ដល់ទៅគាត់ទៅជិតដល់ទៅ មានបងប្អូនខ្លះឃើញ -- អង្គាល់ហ្នឹងឃើញគាត់គេ -- ដូចថាគេប្រាប់គាត់ថា កុំទៅអី ប៉ុន្តែគាត់ៗដូចថា គាត់ចេះតែនិយាយថា គាត់វាធ្លាប់បួស គាត់គេស្រឡាញ់គាត់អីចេះមួយ អីចេះពីរ គាត់ថាគាត់អត់អី អ្នកស្រុកគាត់ -- អ្នកស្រុកហ្នឹងគេស្រឡាញ់គាត់ គ្មាននរណាធ្វើបាបគាត់ទេ គាត់ក៏ដាច់ចិត្តទៅៗ បានខ្ញុំមិនដឹងគាត់នៅប៉ុន្មានថ្ងៃទេ ក៏គេចាប់គាត់យកទៅ គេថាយកទៅឲ្យធ្វើកញ្ច្រែង ហើយទៅ -- ហើយដល់យកទៅចូលទៅវត្តទៅ។ ហើយដាក់ស្តែង ដល់ក្រោយមកបានម្ដាយខ្ញុំគាត់បាត់មួយថ្ងៃហើយមួយថ្ងៃទៀត

គាត់ចេះតែទាមទារទៅរក ប៉ុន្តែដោយថា ថ្ងៃមួយគេបាត់ប្រហែលជិតមួយខែ គាត់ថា យាយឯងបើសិនជាចង់រស់កុំចេះតែទាមទារអ៊ីចឹង។ ហើយដល់ហើយទៅវាៗ -- បានគាត់ដឹងក្រោយមកថា គេយកគាត់ទៅមន្ទីរឃុំឃាំង ប៉ុន្តែមិនដឹងឯណាទេមន្ទីរឃុំឃាំង ខ្ញុំអត់ដឹង។ រហូតដល់ឥឡូវខ្ញុំស៊ើបសួរដែរ ប៉ុន្តែខ្ញុំអត់ដឹងដូចវានៅឯណាពិតប្រាកដទេ។ គ្រាន់តែថា គេយកគាត់ទៅបាត់ទៅ។ បាត់តាំងពីនាក់ទៅ។

[១១:៥៦:៣០]

ហើយអ្នករស់នៅផ្សេងទៀត ដែលមានបងខ្ញុំធ្លាប់ធ្វើសាស្ត្រាចារ្យ និងកូនចៅគាត់អីប៉ុន្មាន ក៏គេដឹកជម្លៀសទៅត្រជាក់ចិត្តអីឯណានៅបាត់ដំបងឯណោះ ព្រោះជាការជម្លៀសទៅបាត់ដំបងហ្នឹងទៅ។ ហើយដល់បាត់ដំបងហ្នឹងទៅ ក៏ជម្លៀសទៅអត់បាយអត់ឃ្លានអី បងខ្ញុំនឹងក៏គាត់គេ -- ពេលមួយនោះគេ -- គាត់ៗរើសស្បែកគោហូបអីអ៊ីចឹងទៅ គេវ៉ៃគេដំ គេអីគាត់ទៅ ហើយក៏គាត់ បងគាត់ហ្នឹង ប្រពន្ធគាត់គ្រួសារបងថ្លៃខ្ញុំ ហើយក្មួយពីរនាក់ក៏ស្លាប់នៅហ្នឹងទៅ។ នៅក្នុង -- ហើយមានរស់នៅតែម្ដាយ -- អ្នកនៅរស់ -- ខ្ញុំនិយាយសរុបទៅ ម្ដាយខ្ញុំ ហើយនិងប្អូនស្រីមួយ ហើយនិងក្មួយមួយដែលពូជបងខ្ញុំហ្នឹងនៅរស់ដែរ សព្វថ្ងៃនេះរស់នៅបរទេស។ ហើយចំណែកបងខ្ញុំមួយទៀត ធ្វើ -- បងទី៣ ធ្វើ -- បងដែលស្លាប់នេះគឺបងទី២។ បងទី៣ ធ្វើជាអ្នកវិស្វករនេសាទ គាត់នៅកំពង់សោម។ អង្កាល់ហ្នឹងគាត់ៗពេលសង្គ្រាមហ្នឹងគាត់ទៅបរទេស ហើយគាត់ទៅធ្វើអីនៅ -- គេឲ្យគាត់រៀន ទៅរៀនធ្វើចិញ្ចឹមមូលចិញ្ចឹមខ្យងអីនៅទុយណេស៊ីហ្នឹង គាត់បានចូលទៅប៉ារីស ហើយគាត់ក៏នៅ -- គាត់បានជួបខ្ញុំនៅឯណោះ ហើយគាត់ដូចថា គាត់ពេលសង្គ្រាមអីស្រុកខ្មែរហើយ គាត់អន្ទះអន្ទែង គាត់ចង់ -- ចិត្តមួយគាត់ចង់នាំកូន កូនចៅទៅនៅស្រុកបារាំង។ ប៉ុន្តែខ្ញុំ -- គាត់ដឹងថាខ្ញុំសំលៀងខ្លួនមកស្រុកទៅហើយ គាត់ថា អ្ហឺ! គាត់ធ្លាប់រៀន*ហ្វាក់គុលតេ* គាត់ធ្លាប់រៀនមហាវិទ្យាល័យ គាត់ធ្លាប់ស្គាល់ ហ៊ូ យន់, ហ៊ូ នឹម អ៊ីចឹងជាពិសេស ហ៊ូ យន់ ជាគ្រូអីគាត់អីអ៊ីចឹង គាត់ចេះតែ អ្ហឺ! ដូចមិនអីទេ។ អ៊ីចឹងគាត់ៗចូលស្រុកមកវិញមក។

[១១:៥៨:៤៦]

ហើយដល់ចូលស្រុក ដល់ -- ហ្នឹងបងហ្នឹងក៏ -- ហ្នឹងក៏មួយពូជហ្នឹង កូនគាត់បីនាក់ ប្រពន្ធគាត់ហ្នឹងបាត់ ៗទៅ រហូតដល់ឥឡូវខ្ញុំមិនដឹងនៅឯណាទេ គឺមិនដឹងស្លាប់នៅឯណា អីនៅណា ហើយនិងប្អូនខ្ញុំ ប្អូនពៅខ្ញុំមួយទៀតនៅជាមួយគាត់ហ្នឹងស្លាប់ទាំងអស់គ្នាទៅ។

ហើយបងទី៤ នៅពេលដែលធ្លាក់ហ្នឹង ដូចនៅក្បាលថ្នល់ ហើយគាត់ធ្វើវិស្វករអី ហើយគាត់

មួយពូជហ្នឹងក៏មិនដឹង -- ខ្ញុំគ្មានព័ត៌មានអីទេ គ្រាន់ថា មួយពូជហ្នឹងមិនដឹងកូនប៉ុន្មានហើយ ខ្ញុំភ្លេចហើយ ប៉ុន្តែគ្រាន់ថា មួយពូជហ្នឹងទាំងអស់គ្នាស្លាប់ ស្លាប់បាត់ទៅដែរ។ ដូច្នេះៗ សរុបទៅគឺថា វា -- ហើយផ្ទះសម្បែងខ្ញុំនៅៗភូមិកំណើតខ្ញុំនោះ ក៏គេរុះរើអីចោលអស់តាំងពីជំនាន់ហ្នឹងមក។ ដូច្នេះ វាអាទាំងអស់ហ្នឹងជាៗរឿងផ្ទាល់ខ្លួនរបស់ខ្ញុំ។ ហើយខ្ញុំ -- ជារឿងដែលខ្ញុំមិនអាចបំភ្លេចបាន ប៉ុន្តែជារឿងកន្លងផុតទៅហើយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកសាក្សី។ បាទ សូមអរគុណលោកសាក្សីដែលបានមកផ្ដល់សក្ខីកម្ម ហើយនិងបានឆ្លងកាត់ពេលវេលាដែលគួរឲ្យក្ដុកក្ដួល ហើយនិយាយរៀបរាប់ជូនតុលាការនាពេលនេះ។ លោកប្រធានខ្ញុំអស់សំណួរហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលត្រូវសម្រាក់ពិសារអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយនៅរសៀលនេះនឹងបន្តស្ដាប់ សវនាការគឺបន្តស្ដាប់សក្ខីកម្មសាក្សី អ៊ុង ចុងហឿង ដោយការតាំងសំណួរពីសំណាក់ក្រុមមេធាវីអ្នកការពារក្ដី ដែលនឹងចាប់ផ្ដើមដោយក្រុមមេធាវីការពារក្ដីលោក នួន ជា មុនមេធាវីពីរក្រុមទៀត។

[១២:០១:១៣]

ហើយមន្ត្រីរដ្ឋបាលតុលាការសម្រួល និងផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មវិញនៅរសៀលនេះ នៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំក្រោកឈរនេះ គឺដើម្បី ខ្ញុំបានទទួលដំណឹងថា កូនក្ដីរបស់ខ្ញុំគឺមានការឈឺឆ្អឹងខ្នង ឈឺក្បាល ហើយនិងមិនបានមានលទ្ធភាពផ្ចង់អារម្មណ៍បានទេ។ ហើយគាត់សូមតាមដានល្ងាចនេះនៅបន្ទប់ខាងក្រោម ហើយនិងខ្ញុំដាក់សំណើតាមនីតិវិធីជូនតុលាការ។ សូមអរគុណ។

[១២:០១:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បានស្តាប់សំណើសុំជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ ដោយមូលហេតុមានបញ្ហាសុខភាព។ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ផ្តល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយដែលស្ថិតក្រោមសាលសវនាការនេះ សម្រាប់រយៈដំណើរការសវនាការនៅរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោមដោយរសៀលនេះទុកលោក នួន ជា ឲ្យនៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៣នាទី ដល់ម៉ោង ១៣:៣១នាទី)*

[១៣:៣១:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ លោកមាន -- សូមៗបង្អង់បន្តិច! មាន -- លោកមានបញ្ហា?

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក អៀង សារី!

**លោក អាង ឧត្តមៈ**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សហភាគា សហព្រះរាជអាជ្ញា និងអស់លោកទាំងឡាយចូលរួមសវនាការនេះ។ សូមអធ្យាស្រ័យដោយសារឡើងមករំខានបន្តិច ក៏ប៉ុន្តែដើម្បីជាប្រតិចារឹក និងកំណត់ត្រា ខ្ញុំបាទសូមលើការកត់សម្គាល់មួយទាក់ទងនឹងដំណើរនីតិវិធីរបស់យើង។

[១៣:៣២:៥៣]

ខ្ញុំបានកត់សម្គាល់ឃើញថា តាមរយៈសំណួរដែលសួរទៅលោក អ៊ុង ចុងហឿង ជាពិសេសតាមរយៈសំណួរលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ព្រឹកមិញនេះ ដោយប្រយោល ឬដោយចំពោះ ឬដោយអចេតនាយ៉ាងម៉េច ក៏ខ្ញុំមិនប៊ានសន្និដ្ឋាន។ ប៉ុន្តែបានបណ្តោយ អនុញ្ញាត អ៎! ខ្ញុំសូមទោស មិនប្រើអនុញ្ញាតទេ បានបណ្តោយឲ្យសាក្សីសម្តែងនូវទុក្ខសោក។ នេះដែលជាការផ្ទុយ ហើយការធ្វើបែបនេះវាអាចប៉ះពាលដល់ពេលវេលារបស់យើងផង ហើយវាអាចធ្វើឲ្យមានការមិនច្បាស់លាស់ទៅលើចរិតលក្ខណៈរបស់សាក្សីផង។ វាផ្ទុយពីៗលោកចៅក្រមប្រធានកន្លងមក សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី គឺលោកៗអនុញ្ញាត ឬសួរដើមបណ្តឹងរដ្ឋប្បវេណី ថាអាចសម្តែងទុក្ខសោកបាន។ ក៏ប៉ុន្តែសម្រាប់សាក្សីលោកមិនដែលបានអនុញ្ញាតឲ្យធ្វើបែបនេះ។ ប៉ុន្តែតាមរយៈសំណួរទាំងអស់ប៉ុន្មានព្រឹកមិញនេះហ្នឹង គឺថាយើងឃើញថា សាក្សីទៅជាសម្តែងទុក្ខសោកដូចជាក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីវិញ។ ហាក់ដូចជាស្តាប់មើលទៅ ដើរៗតួនាទីពីរ ជាសាក្សីផង ជាដើមបណ្តឹងរដ្ឋប្បវេណីផង។

ខ្ញុំគ្រាន់តែទាញការកត់សម្គាល់ និងការចាប់អារម្មណ៍ទេ តើយើងឲ្យមានសភាពការណ៍នេះបែបហ្នឹងតទៅទៀតនៅពេលអនាគត សម្រាប់សាក្សីដទៃទៀត?

សូមអរគុណ។

**ប្រធានអង្គជំនុំៈ**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៣:៣៤:៤៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកអស់លោក លោកស្រីចៅក្រមជាទីគោរព។ ខ្ញុំមានការភ្ញាក់ផ្អើលដែលខាងការពារក្តី លើកបញ្ហានេះ ដោយនិយាយថាសាក្សីមិនអាចសម្តែងភាពរំភើបរបស់ខ្លួនបាន។ ក៏ប៉ុន្តែត្រូវយល់ថា ការរំភើបយើងមិនអាចគ្រប់គ្រងបានទេ។ សាក្សីគាត់បាននិយាយអំពីបទពិសោធន៍របស់គាត់ ហើយនិងបានផ្តល់សក្ខីកម្មលើអ្វី ដែលគាត់បានឆ្លងកាត់ ហើយយើងបែងចែកសេចក្តីភាពរំភើប ហើយនិងអ្វីដែលសក្ខីកម្មនោះពិបាកនឹងធ្វើណាស់ ហើយយើងមិនអាចហាមឃាត់ឱ្យមនុស្ស មិនឱ្យរំភើបនោះទេ។ អ៊ីចឹងលោកមេធាវីគួរតែយល់កន្លែងនេះផងដែរ ព្រោះជាមនុស្ស។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំមិនត្រឹមតែថា ភ្ញាក់ផ្អើលនោះទេ គឺថា ខ្ញុំហាក់ដូចជាស្រគាត្រចៀកផងដែរ ព្រោះថា ខ្ញុំ យើងដឹងថា ហេតុអីក៏ថា ត្រូវយល់ -- ថាមានអ្នកណាម្នាក់ដែលអាចនិយាយអំពីអង្គហេតុទាំងអស់នេះ ដោយមិនរំភើបនោះ ឬក្តុកក្តួលនោះ។ ហើយខ្ញុំក៏ឆ្ងល់ផងដែរ ដែលថា ដែលគេបន្ទោសលោកសាក្សីនេះ ដែលថាគាត់ហ្នឹងមានចរិត ហាក់ដូចជាជនរងគ្រោះ ហើយនេះជារឿងធម្មតារបស់គាត់ទេ ព្រោះគាត់ផ្តល់សក្ខីកម្មដោយធម្មជាតិរបស់គាត់។

[១៣:៣៦:១២]

**លោក អាង ឧត្តម៖**

សូមជម្រាប--

**ប្រធានអង្គជំនុំ៖**

បានហើយចប់ត្រឹមហ្នឹងហើយ អត់ -- មិនអនុញ្ញាតទេ យើងប្រាប់ជម្រាបដល់ភាគី ដែលពាក់ព័ន្ធនឹងរឿងក្តីសូមឱ្យពិនិត្យនូវបណ្តាវិធាន ដែលពាក់ព័ន្ធទៅនឹងរបៀបតាំងសំណួរដេញដោល។ ហើយនិងសិទ្ធិជំទាស់តវ៉ារបស់ខ្លួន ដែលបានអនុវត្តរៀងៗខ្លួនកន្លងមកហើយ នៅក្នុងកិច្ចដំណើរការនេះ។ នៅពេលណាដែលសំណួរនុ៎ងវា មិនចាំបាច់ សំណួរដែលវាមិនសមស្រប សំណួរដែលច្បាប់ហាមឃាត់ គឺភាគីលើកឡើងជំទាស់ អង្គជំនុំជម្រះពិចារណាសម្រេច អំពីបញ្ហានោះ។

សង្ឃឹមថា ភាគីពាក់ព័ន្ធ ជាពិសេស អាង ឧត្តម ដែលមានបានកត់សម្គាល់បញ្ហានេះ សង្ឃឹមថា

លោកនឹងយល់ដឹង ហើយនិងតាំងសំណួរត្រឹមត្រូវបំផុត នៅក្នុងការដែលដំណើរការចាប់ពីពេលនេះទៅខាងមុខ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤០:៤៦]

**ប្រធានអង្គជំនុំ៖**

សេចក្ដីកត់សម្គាល់ដែលលើកឡើងដោយលោកមេធាវី អាង ឧត្ដម ដែលបានធ្វើអម្បាញ់មិញនេះមិនសមរម្យទេ មិនមានចែងនៅក្នុងវិធាន ឬក៏ក្រមនីតិវិធីព្រហ្មទណ្ឌនៅកម្ពុជាជាធរមានទេ។ ហើយអង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា សាក្សីបានចូលមកឆ្លើយផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះគឺមាន -- បានរួមវិភាគទានយ៉ាងល្អប្រសើរបំផុត នៅក្នុងការរួមចំណែកក្នុងការពិចារណាដើម្បីស្វែងរកការពិតក្នុងរឿងក្ដីនេះ។ ហើយចំណុចមួយទៀត សូមរំឭកលោក អាង ឧត្ដម ថានៅពេលក្រោយទៀត ទី១ សង្ឃឹមថាខ្លួនលោកនឹងប្រព្រឹត្តទៅបានល្អប្រសើរ នៅក្នុងការអនុវត្តនីតិវិធីក្នុងការតាំងសំណួរដេញដោលចំពោះអ្នកណា គោលដៅដែលខ្លួនត្រូវសួរ។ ទី២ មុននឹងធ្វើអត្ថាធិប្បាយអ្វីដែលខ្លួនលើកឡើង លោកត្រូវកំណត់ប្រាប់ជាមុនអំពីប្រធានបទ ដែលលោកមានបំណងចង់និយាយសង្ខេបដើម្បីឲ្យអង្គជំនុំជម្រះថាអនុញ្ញាត ឬក៏មិនអនុញ្ញាតឲ្យធ្វើដូច្នេះ ដើម្បីចៀសវាងមានបញ្ហាដែលកើតឡើងដូចនៅទីនេះ ហើយដូចជាមានការបំភិតបំភ័យធ្វើ ឬធ្វើឲ្យ -- ដោយចេតនាធ្វើឲ្យសាក្សីបាត់បង់នូវជំនឿចិត្តរបស់ខ្លួននៅក្នុងការផ្ដល់សក្ខីកម្ម។

សូមអញ្ជើញលោក សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

[១៣:៤២:៥៦]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់បន្ថែមនូវមតិមួយបន្ថែមទៅលើអ្វី ដែលលោកប្រធានបានសង្ខេបយ៉ាងត្រឹមត្រូវឥតខ្ចោះ។ គឺថាអង្គជំនុំជម្រះសាលាដំបូងមានការសោកស្ដាយយ៉ាងខ្លាំងចំពោះសាក្សី ដែលបានផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយអង្គ -- ហើយយើងសូមថ្លែងអំណរគុណចំពោះសាក្សីទាំងអស់ដែលបានមកផ្ដល់នៅទីនេះ។ ដូច្នេះហើយ យើងសូមថ្លែងអំណរគុណចំពោះលោកសាក្សីទាំងអស់ដែលបានផ្ដល់សក្ខីកម្ម ហើយយើងមិនចង់ឲ្យមានការរិះគន់ ឬក៏ការវាយការប្រហារណាមួយទៅលើសាក្សី ដែលបានមកផ្ដល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះនេះឡើយ។

សូមអរគុណ។

[១៣:៤៣:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ក្រុមមេធាវីការពារក្តីលោក នួន ជា!

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រី។ជម្រាបសួរលោកសាក្សី ហើយខ្ញុំសូមថ្លែងអំណរគុណចំពោះលោកសាក្សីដែលបានអញ្ជើញមកទីក្រុងភ្នំពេញ ដើម្បីផ្តល់នូវសក្ខីកម្ម។ ខ្ញុំសូមជម្រាបថានៅរសៀលនេះ ខ្ញុំប្រហែលជាចំណាយពេល១ម៉ោង។

មេធាវី សុន អរុណ បានប្រាប់ខ្ញុំថាមិនមានការបកប្រែ។ អត់មានបញ្ហាអីទេលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** ដូច្នេះខ្ញុំសូមចាប់ផ្តើមនូវសំណួររបស់ខ្ញុំ។ ហើយមេធាវីជាតិគាត់នឹងសួរនៅពេលក្រោយ។ ដូច្នេះ ខ្ញុំសូមជម្រាបសួរដល់ខាងព្រះរាជអាជ្ញា និងខាងភាគីទាំងអស់ ហើយលោក -- តាមរឿងរបស់លោកនៅថ្ងៃ៧ មករា -- ខ្ញុំសូមនិយាយអំពីព្រឹត្តិការណ៍ ដែលកើតឡើងនៅពេលនោះ។ ហើយបន្ទាប់មកខ្ញុំនឹងនិយាយអំពីអ្វីដែលលោកបានពិភាក្សាកាលពីរសៀលថ្ងៃអង្គារ។ ហើយខ្ញុំសង្ឃឹមថាមិនមានការជំទាស់ ឬក៏មានលើកឡើងនូវការជំទាស់ពីខាងភាគីណាមួយឡើយ។

[១៣:៤៥:១៤]

ហើយឥឡូវនេះ ខ្ញុំសូមដកស្រង់នូវប្រតិចារឹក គឺនៅក្រោយ គឺព្រឹត្តិការណ៍ក្រោយថ្ងៃ៧ មករា ឆ្នាំ៧៩ ដែលថាវាអាចពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១។ ដូច្នេះខ្ញុំសូមលើកសំណួររបស់ខ្ញុំពាក់ព័ន្ធនឹងចំណុចមួយនេះផងដែរ។

លោកសាក្សី ពាក់ព័ន្ធទៅនឹងអ្វីដែលបានជម្រាប អង្គជំនុំជម្រះកាលពីថ្ងៃអង្គារ ខ្ញុំសូមដកស្រង់ពីប្រតិចារឹក ប្រសិនបើខ្ញុំនិយាយខុស សូមលោកកែខ្ញុំផង។ លោកបានជម្រាបអង្គជំនុំជម្រះកាលពីរសៀលថ្ងៃអង្គារថា “ខ្ញុំត្រឡប់មកទីក្រុងភ្នំពេញនៅក្នុងខែ៥ ឬខែ៦ ឆ្នាំ៧៩ ហើយនៅពេលនោះខ្ញុំបានទៅទួលស្លែង ដែលគេហៅថា ស-២១។ ហើយខ្ញុំធ្វើការនៅទីនោះអស់រយៈពេលមួយៗរយៈពេល”។ តើត្រឹមត្រូវដែរឬទេ ដែលលោកសាក្សីបំពេញការងារនៅទួលស្លែងនៅក្នុង គឺនៅក្នុងឆ្នាំ ៧៩ហ្នឹង? ហើយ

ប្រសិនបើមិនត្រឹមត្រូវ ឬក៏ម៉េចសូមលោកជម្រាបមកខ្ញុំផង។ សូមអរគុណ។ តើលោកធ្វើការនៅទីនោះរយៈពេលប៉ុន្មានដែរ? សូមអរគុណ។

[១៣:៤៦:២៤]

**លោក អ៊ុង ចុងហឿង៖**

**ឆ៖** ខ្ញុំបានធ្វើការនៅទួលស្លែងប្រហែលមិនចាំច្បាស់ ប្រហែលជា២ខែ ទៅ៣ខែបាទ។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកបំពេញការងារអ្វីដែរនៅក្នុងរយៈពេល២ ឬក៏ ៣ខែនោះ?

**ឆ៖** ខ្ញុំរៀបចំសំណុំរឿង ជាពិសេសគឺសារភាពរបស់ជនដែលគេត្រូវសម្លាប់នៅ -- ទុកសំណុំរឿងការនាំចេញរបស់គាត់នៅ អេស-ទ្វាំងតេអង ពេលនោះ ហើយជួយរៀបចំឲ្យមានជារបៀបរៀបរយបាទ។

**ស៖** អរគុណលោកសាក្សី។

**លោក អេនឌ្រូ អ៊ីនូហ្សុី៖**

ឥឡូវនេះខ្ញុំចង់លើកយកនូវឯកសារ ដែលមានលេខ D107/27.19 ហើយឯកសារនេះ គឺមាននៅលើ អ៊ីនធឺហ្វេស គឺឯកសារ D108/27.19។ ហើយនិងឯកសារមួយទៀត គឺ D108/27.1 ហើយ ERN នៃឯកសារនេះគឺ 00170692 ដល់ 00170773, ហើយភាសាបារាំង គឺមានលេខ 00648960 ដល់ 00649033, ហើយភាសាខ្មែរគឺ 00324672 ដល់ 00329832 -- 4798។ ឥឡូវនេះ ខ្ញុំសូមប្រគល់នូវឯកសារមួយច្បាប់ជូនដល់សាក្សី។ សូមលោកប្រធានអនុញ្ញាត។ ហើយខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់ផងដែរ ប្រសិនបើមានការអនុញ្ញាត។ គឺភាសាអង់គ្លេសដែលមាន 00170692, ខ្មែរ 00648960។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនៅលើទំព័រទី១ នៃឯកសារនេះនៅលើអេក្រង់ផងដែរ លោកប្រធាន។

[១៣:៤៩:១៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកមេធាវី យកទៅជូនសាក្សីពិនិត្យ!

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** លោកសាក្សី សូមលោកពិនិត្យទៅលើទំព័រដើម គឺគម្របទំព័រ។ គឺជាបទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជា នៅព្រំដែនកម្ពុជាថៃ។ រៀបចំឡើងនៅក្នុងអំឡុងឆ្នាំ១៩៨០ ហើយជាការសម្ភាសដោយជនជាតិជប៉ុនមួយ ដែលមានឈ្មោះថា ម៉ាសាតូ ម៉ាត់ស៊ូស៊ីតាក់ និងមួយទៀត គឺរបស់លោក ស្ទីវ ហ្វិន ហេដឌ័រ។ លោកសាក្សី តើលោកចាំដែរឬទេ ថាលោកបានផ្ដល់ចម្លើយទៅដល់បុគ្គលទាំងពីររូបនេះ នៅក្នុងឆ្នាំ១៩៨០ នៅក្បែរព្រំដែនកម្ពុជាថៃ តើលោកចាំដែរឬទេ?

**ឆ៖** ខ្ញុំចាំថា ខ្ញុំបានជួប ស្ទីវ ហ្វិន ហេដឌ័រ ជាមួយអ្នកកាសែត ឬក៏ជនជាតិជប៉ុនម្នាក់ ប៉ុន្តែខ្ញុំអាហ្នឹង ខ្ញុំមិនបានអាន មិនដឹងជា ហើយឯកសារនេះ ខ្ញុំជាលើកទី១ ដែលខ្ញុំបានឃើញបាទ។

[១៣:៥១:២៦]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ យើងនឹងពិនិត្យមើលមួយជំហានម្ដងៗ ហើយខ្ញុំនឹងរំឭកលោកអំពីចំណុចទាំងអស់នេះ។ ដូច្នេះ សូមលោកបើកមើលទំព័រទី១០ នៃឯកសារនេះ។ ហើយខ្ញុំគិតថា ភាសាខ្មែរ គឺទំព័រ១៥ ហើយភាសាអង់គ្លេសមាន 00170701, ខ្មែរគឺ 00324680, បារាំង គឺ 006489649។ ដូច្នេះ ខ្ញុំអនុញ្ញាតថា សូមចាប់ផ្ដើមពិនិត្យមើលនូវទំព័រទី១០ជាភាសាអង់គ្លេស ខ្ញុំចាប់អារម្មណ៍ទៅលើទំព័រទី១០ ជាភាសាអង់គ្លេសនេះ។ គឺប្រសិនបើយើងមើលជាទំព័រខ្មែរ គឺទំព័រ១៥។ ខ្ញុំសូមអាននូវឯកសារនេះ "បច្ចុប្បន្ននាយកទួលស្លែងជនជាតិខ្មែរ ឈ្មោះ អ៊ុំង ប៊ិច ដែលជាប្អូនរបស់អ៊ុំង គាត បច្ចុប្បន្នរស់នៅក្នុងប្រទេសបារាំង។ ប៊ិច ហាក់ដូចជាមិនមែនប្រភពគួរឲ្យជឿជាក់បានណាស់ណាទេ។ គាត់បាននិយាយអំពីរឿងរ៉ាវជាច្រើន ដែលស្ដាប់ទៅ ពិបាកយល់ណាស់។ គាត់និយាយថា ជួន ជឿន, វន វ៉េត និង សុន សេន ក៏នៅក្នុងទួលស្លែងផងដែរ។ នាយកសារមន្ទីរដែលជនជាតិវៀតណាម ឈ្មោះ ម៉ៃ ឡាំ ក៏និយាយដែរ ថាបន្ទាប់ពី សុន សេន បានវិលពីប្រទេសចិន គាត់បានប៉ុនប៉ងធ្វើរដ្ឋប្រហារមួយតាមការណែនាំរបស់ចិន ហើយគាត់ក៏ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅក្នុងទួលស្លែង"។ តើលោកចាំដែរឬទេ លោកបានពិភាក្សាជាមួយ ស្ទីវ ហេដឌ័រ អំពីបញ្ហានាយកមន្ទីរទួលស្លែងជនជាតិខ្មែរ និងជនជាតិវៀតណាមនោះ?

[១៣:៥៣:២៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ លោកប្រធាន ខ្ញុំគ្រាន់តែចង់បំភ្លឺទេ។ តាមការពិតទៅ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា ផ្នែកនេះ ជាការសន្ទនាគ្នារបស់ជនអៀសខ្លួននេះ គឺជា -- ការសន្ទនារវាង អុង ថុងហឿង ហើយនិង--

**អ្នកបកប្រែ៖**

លោកប្រធាន ខ្ញុំស្តាប់ឈ្មោះគាត់និយាយអត់បាន។ លោកប្រធាន សូមឲ្យអានឈ្មោះម្តងទៀត។

[១៣:៥៤:០៣]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ជាការសន្ទនាដែលកើតមានឡើងរវាងមនុស្សពីរនាក់។--

**ប្រធានអង្គជំនុំ៖**

លោក។ៗ តំណាងសហព្រះរាជអាជ្ញា និយាយម្តងទៀត ហើយនិយាយឲ្យបានយឺត និងបញ្ជាក់ឈ្មោះឲ្យបានច្បាស់។ ព្រោះអ្នកបកប្រែ អត់បានបកប្រែឈ្មោះដែលលោកនិយាយដល់ហ្នឹង ច្បាស់លាស់ទេ។ គាត់ស្តាប់មិនយល់ ស្តាប់មិនបាន អាបញ្ហាឈ្មោះដែលលោកនិយាយដល់ពាក់ព័ន្ធនឹង។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ មិនមែនជាការជំទាស់នោះទេ លោកប្រធាន។ នេះ ខ្ញុំគ្រាន់តែចង់ទាញចំណាប់អារម្មណ៍លោកមេធាវី លើការដែលថាសម្រង់ដែលត្រូវបានអានអម្បាញ់មិញនេះ គឺជាវគ្គបន្តនៃចំនួនទំព័រជាច្រើន ដែលមានសរសេរទាក់ទងទៅនឹងប្រភពនៃការសន្ទនានេះ -- នៃការសម្ភាសនេះ ហើយមានឈ្មោះ គឺថាមានឈ្មោះ អុង ថុងហឿង ហើយនិងឈ្មោះមួយទៀត សូ –អេស-អា-អ៊ុយ-វេ– គឹមហុង បាទ សូ គឹមហុង។ ខ្ញុំសូមទាញចំណាប់អារម្មណ៍តុលាការ ហើយនិងមេធាវី គឺថាយើងគួរតែដឹងថា តើអ្នកណាបាននិយាយអ្វី ហើយពីព្រោះថាអានេះជាការពិភាក្សារវាងមនុស្សពីរនាក់ ពីព្រោះថាតាមអត្ថបទនេះ អ្វីដែលនិយាយនេះ វាអាចថាជាពាក្យសម្តីរបស់អ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងពីរនាក់ហ្នឹង។ អ៊ីចឹងយើងត្រូវតែបំភ្លឺទាក់ទងទៅនឹងរបៀបសម្ភាសរបស់អ្នកកាសែតជនជាតិជប៉ុន ហើយនិងលោក ស្ទីវ ហេដឌ័រ នេះ។

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំអត់មានបញ្ហាថាទេ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ទៅលើចំណុចនេះ។

**សួរដោយលោក អេនទ្រូ អ៊ីនូហ្វ៊ី៖**

**ស៖** លោកសាក្សី តើលោកចាំថាលោកបានផ្ដល់នូវចម្លើយបែបនេះ ឬមួយក៏លោកបានផ្ដល់ទៅឱ្យអ្នកណាម្នាក់ទៀត គឺផ្ដល់ទៅឱ្យលោក សូ គឹមហុង វិញ?

**លោក អុង ថុងហឿង៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ចម្លើយបែបម៉េចបាទ?

**ស៖** ខ្ញុំចង់និយាយទៅលើផ្នែកដែលខ្ញុំបានអានជូនលោកនៅមុននេះ គឺទំព័រទី១៥ ដែលខ្ញុំបានអានជូនលោកមុននេះបន្តិច គឺឯកសារដែលនៅចំពោះមុខលោកនេះ។ ប្រសិនបើលោកមើលក្នុងអេក្រង់របស់លោក ឃើញឯកសារត្រង់ចំណុចដែលមានគូសពណ៌ គូសប្រអប់ពណ៌នៅជុំវិញនោះ។

[១៣:៥៧:០៧]

**ឆ៖** ខ្ញុំមិនអាចអះអាងថា ខ្ញុំបាននិយាយទាំងអស់នេះ ទាំងអស់នេះទេ។ ប៉ុន្តែក៏ខ្ញុំ កាលពេលនោះ ក៏ខ្ញុំបានឮសួរពាក្យចចាមអារ៉ាមរបៀបនេះដែរ ប៉ុន្តែខ្ញុំមិនដឹងថា ខ្ញុំនិយាយ ឬក៏លោក សៅ គឹមហុង និយាយ ខ្ញុំមិនច្បាស់ដែរ។ ព្រោះអត្ថបទអ៊ីចឹង ខ្ញុំជួបគ្នាអ៊ីចឹង ហើយគេអត់ដែលបានឱ្យខ្ញុំអានឡើងវិញ ហើយយកមកសួរខ្ញុំអ៊ីចឹង ខ្ញុំពិបាកអះអាងដែរ វាជិត៤០ឆ្នាំមកហើយ។

**ស៖** សូមអរគុណលោកសាក្សី។ នៅពេលដែលលោកធ្វើការនៅទួលស្លែងក្នុងឆ្នាំ៧៩ តើលោកស្គាល់ អ៊ឹង ប៊ិច ឬក៏ ម៉ៃ ឡាំ នោះទេ?

**ឆ៖** បាទ ខ្ញុំស្គាល់។

[១៣:៥៨:០៩]

**ស៖** តើលោកគិតថា ពួកគាត់ហ្នឹងជាមនុស្សគួរឱ្យទុកចិត្តដែរឬទេ?

**ឆ៖** អ្ហឺ! ខ្ញុំៗ មិនអាចអះអាង ខ្ញុំមិនថា ខ្ញុំទុកចិត្តគាត់១០០ភាគរយ បានទេបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសូមសួរលោកបន្តទៅសំណួរមួយទៀតទាក់ទងពេលវេលាលោកនៅទួលស្លែង តើលោកដឹងថាមានឯកសារណាមួយ ដែលគេយកចេញទៅ យកទៅក្រៅ ឬមួយក៏ត្រូវគេបំផ្លាញចោលដែរឬទេ? ថាតើអាចមានបែបនេះដែរឬទេ?

**ឆ៖** ពេលនោះ ខ្ញុំរកឯកសារមួយចំនួន វាអត់ឃើញ។ ឯកសារដូចខ្ញុំចង់ដឹងពីឯកសារ ដែលលោក នួន ឃឿន ឧទាហរណ៍ ដែលខ្ញុំដូចថា ធ្លាប់ស្គាល់ពីដើមមក ខ្ញុំរកឯកសារគាត់វាអត់ឃើញ។ ហើយឯកសារមនុស្សដែលខ្ញុំធ្លាប់ស្គាល់មួយចំនួនទៀត ហើយនិងដល់ខ្ញុំសួរ សួរ រកសួរទៅថាមាន

ឯកសារមួយចំនួនបាត់ ប៉ុន្តែខ្ញុំមិនអាចថាបាត់នោះដោយសារអ្វីទេ។ ប៉ុន្តែខ្ញុំអាចបញ្ជាក់បានថា នៅពេលនោះឯកសារមួយចំនួន ដូចជាខ្ញុំ ខ្ញុំមានឯកសារមិត្តភក្តិខ្ញុំម្នាក់ ខ្ញុំទិញចេកចៀន ខ្ញុំឃើញឯកសារហ្នឹងគេយកទៅ -- ខ្ញុំញ៉ាំចេក ខ្ញុំហូបចេកចៀនទៅ ខ្ញុំឃើញឯកសារហ្នឹងដែលយកទៅដើម្បីខ្ចប់ ចេកចៀន។ ហើយតាមខ្ញុំដឹងមក ដែលកូនស្រីលោក ភីង តុន ជាឧទាហរណ៍គាត់បានឃើញសម័យ ប្រហែលគ្នាហ្នឹងគាត់បានឃើញនៅផ្សារមួយខាងណាមួយទៀតនោះ គាត់បានឃើញរៀបគ្នានេះដែរ។ ដូច្នេះ អាហ្នឹងវាជាព្រឹត្តិការណ៍ដែលកន្លងមកបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ យើងមើលទៅទំព័រ១១ នៃភាសា -- ជាភាសាអង់គ្លេស ហើយខ្ញុំគិតថា ទំព័រ១៦ ភាសាខ្មែរ។ ឯកសារអង់គ្លេសគឺ 00170702, ខ្មែរ 00324687។ អានេះ គឺជាអ្វីដែលខាងព្រះរាជអាជ្ញាបានលើកឡើង គឺប្រហែលជានៅក្នុងកិច្ចសម្ភាសន៍ដែលហ្នឹងគឺនៅទំព័រកណ្តាល ដែលបាននិយាយថា ប្រភពគឺមកពី សៅ គឹមហុង ដូច្នេះខ្ញុំគិតថា យើងអាចសន្មតថាអ្វីៗដែលនិយាយបន្តហ្នឹងគឺជាចម្លើយរបស់ សៅ គឹមហុង ហើយចំណែកឯផ្នែកខាងមុខ គឺជាចម្លើយរបស់លោកសាក្សី។

[១៤:០១:២២]

ដូច្នេះ ខ្ញុំគ្រាន់តែរំឭកដើម្បីឱ្យលោកសាក្សីនឹកឃើញ ដូច្នេះលោកសាក្សីពិនិត្យមើលនៅក្នុងអេក្រង់ "វៀតណាមបានចូលមកទួលស្លែងមុនគេទាំងអស់ ហើយបានយកទៅជាមួយនូវឯកសារខ្លះជាពិសេសឯកសារមុនឆ្នាំ១៩៧៨ និង សូម្បីតែបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងឆ្នាំ១៩៧៨ ផងដែរ។ រូបថតដែលដាក់បង្ហាញនៅពេលបច្ចុប្បន្ននេះ ក្នុងគុកទួលស្លែងគឺជារូបថតដែលចេញពីហ្វីលដែលកងទ័ពវៀតណាមបានរកឃើញនៅក្នុងគុក ហើយបានយកទៅប្រទេសវៀតណាម ដើម្បីផ្តិតចេញជារូបថត។ ឯកសារស្តីពី ហ៊ូ នឹម, ហ៊ូ យន់ បានបាត់អស់។ តើលោកធ្លាប់ឃើញ ឬក៏ធ្លាប់ដឹងអំពីការសម្ភាសបែបនេះដែរឬទេលោកសាក្សី?

[១៤:០២:១១]

**ឆ៖** ខ្ញុំមិនធានាថា នេះជាសម្តីរបស់ខ្ញុំទេបាទ ហើយជាពិសេសខ្ញុំមាន -- ខ្ញុំអត់បានឃើញសារភាពរបស់លោក ហ៊ូ យន់ ពិតប្រាកដមែន ប៉ុន្តែសារភាពរបស់ ហ៊ូ នឹម ខ្ញុំឃើញ ហើយខ្ញុំនិយាយអ៊ីចឹងដូចជាផ្ទុយ ខ្ញុំមិន -- ផ្ទុយពីការជាក់ស្តែង ព្រោះខ្ញុំបានអានសារភាពរបស់លោក ហ៊ូ នឹម បាទ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់អ៊ីចេះ បញ្ជាក់ត្រង់កន្លែងថា ពីបញ្ហាហ្នឹងបើមិនដឹងទិសដៅចង់បានអី ប៉ុន្តែគ្រាន់ថា

នេះជាសេចក្តីសម្អាសដែលខ្ញុំអត់បានអានឡើងវិញទេ។ ខ្ញុំពេលនោះ ហើយជាការជាក់ស្តែងទៅពេលដែលខ្ញុំទៅឃើញថា វាបញ្ហាធំគឺឯកសារដែលនៅទួលស្លែងនោះរាយប៉ាយពេញហ្នឹង ហើយបងប្អូនយើងមួយចំនួនដែលកាលពេលនោះ គាត់ខ្វះក្រដាសប្រើ គាត់បានមកយកក្រដាសហ្នឹងទៅលក់ ឬក៏ធ្វើបិទខ្ចប់អីវ៉ាន់អីតាមផ្សារពាសពេញហ្នឹង។ អាហ្នឹងវាជាព្រឹត្តិការណ៍នៅពេលនោះបាទ។

[១៤:០៣:៣៩]

**ស៖** សូមអរគុណលោកសាក្សី។ បាទ យើងពិនិត្យលើឯកសារនេះ ក្នុងរយៈពេលបន្តិចទៀតនេះ។ យើងចូលទៅទំព័រ១៤ នៅក្នុងទំព័រអង់គ្លេស អត្ថបទខ្មែរគឺទំព័រ២០ ឬក៏២១ ខ្ញុំនឹងសួរសំណួរមួយពីបញ្ហានេះមុន។ តើលោកនៅចាំដែរឬទេ ឬលោកបានដឹងដែរឬទេ អំពីការជំនុំជម្រះដែលបានរៀបចំឡើងដោយវៀតណាមនៅឆ្នាំ១៩៧៩ នៅភ្នំពេញនោះ? គឺពេលដែលលោកធ្វើការនៅទួលស្លែង នៅពេលដែលលោកធ្វើការនៅទីនោះ តើលោកបានចូលរួមក្នុងការត្រៀមរៀបចំឯកសារសម្រាប់ការជំនុំជម្រះរឿងក្តី ប៉ុល ពត នោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានចូលជួយរៀបចំមែនបាទ។

**ស៖** ថាតើការជំនុំជម្រះរៀបចំឡើងនៅកន្លែងណាលោកសាក្សី?

**ឆ៖** ខ្ញុំអត់បានទៅជំនុំ -- ទៅចូលរួមទេ គ្រាន់ថាបានដោយភារកិច្ចនៅធ្វើជាអ្នក*អាកឈីវីស* អ្នករៀបចំនៅទួលស្លែងហ្នឹង ខ្ញុំបានជួយធ្វើអីចឹង ប៉ុន្តែពេលប្រជុំខ្ញុំអត់បានដឹងនៅកន្លែងណា មិនដឹងជានៅអតីតទូតចិន ឬក៏សាលចតុមុខ ខ្ញុំមិន -- ឥឡូវហ្នឹងខ្ញុំអត់ច្បាស់ទេបាទ។

[១៤:០៥:៥៤]

**ស៖** សូមអរគុណលោកសាក្សី។ សំណួរចុងក្រោយមួយទាក់ទងនឹងឯកសារនេះ ហើយខ្ញុំអាចត្រឡប់មកវិញនៅពេលក្រោយ។ ប៉ុន្តែសូមលោកមើលទំព័រដដែល ភាសាអង់គ្លេស 00170705, 00369 រហូតដល់ 93 ភាសាខ្មែរ ហើយភាសាបារាំង 00 --។

ឥឡូវនេះខ្ញុំសូមអនុញ្ញាតអានជូនលោក គឺថានៅខាងលើគឺជាបទសម្ភាសន៍ថ្ងៃទី ខែកុម្ភៈ ឆ្នាំ១៩៨០ ហើយលោកជាប្រភពនៅក្នុងឯកសារនេះ។ ខ្ញុំសូមអាននៅក្នុងផ្នែកមួយពាក់កណ្តាលទំព័រអង់គ្លេស៖ “ជាអ្នកចូលរួមនោះគឺថាគេបានដាក់បញ្ចូលក្នុងគណៈកម្មការមួយ គឺគណៈកម្មការសរសេររដ្ឋធម្មនុញ្ញគឺប្រវត្តិសាស្ត្រសម្រាប់កម្ពុជា វៀតណាមបានប្រើខ្ញុំឱ្យប្រើរដ្ឋធម្មនុញ្ញវៀតណាមជាគំរូរបស់រដ្ឋធម្មនុញ្ញខ្មែរ ហើយគឺមិនឱ្យប្រើគំរូរបស់បារាំងទេ។ ហើយលោកបានសរសេរគោលចំណុចសំខាន់ៗ គឺថាជា

សាមគ្គីភាពជាប្រវត្តិសាស្ត្ររវាងវៀតណាមនិងកម្ពុជាដើម្បីគណៈកម្មការហ្នឹងនៅជាមួយខ្ញុំហ្នឹង គឺថាត្រូវប្រើគំរូរដ្ឋធម្មនុញ្ញវៀតណាម គឺមិនប្រើប្រភពពីអាណានិគមបារាំងទេ ហើយការយោងទៅរកប្រវត្តិនេះនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលហៅថា វៀតណាម គឺថាមានភាពវៃឆ្លាតដើម្បីការប្រើគំរូនេះ ហើយគេនឹងយកបញ្ហានេះជាគំរូ"។ តើលោកចាំទេ តើគេបានប្រាប់លោកបែបនោះទេ នៅក្នុងពេលដែលលោកធ្វើការនៅទីនោះ កាលណោះនោះ?

[១៤:០៧:៥០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប ចាំស្តាប់សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា!

សូមអញ្ជើញ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរបែបនេះ ដោយសារមេធាវីបានយោងទៅរកចម្លើយមួយដែលបានធ្វើពីមុន។ ហើយសំណួរដែលពួកគាត់សួរខាងដើមនេះ ទាក់ទងទៅនឹងឯកសារនៅស-២១នោះ គឺសមស្របហើយ ដើម្បីឲ្យបំភ្លឺឲ្យច្បាស់នោះ។ ខ្ញុំសូមជម្រាបថា គឺមានបញ្ហាក្រោយពីឆ្នាំ១៩៧៩ ហ្នឹង គឺមិនទាក់ទង គឺចំពោះ E124/7.2 នោះ គឺថាអង្គជំនុំជម្រះបានដាក់កថាខណ្ឌនៃដីកាដំណោះស្រាយនៃផ្នែកសវនាការនេះ ដោយដាក់បញ្ចូលទៅនឹងកថាខណ្ឌមួយចំនួនទាក់ទងនឹងផ្នែកជាពិសេសកថាខណ្ឌ៥០ គឺថា១៥៨២ គឺ ១៥៨៦, ១៦០២, ១៦០៣ គឺទាក់ទងទៅនឹងការចោទប្រកាន់ដែលទាក់ទងទៅនឹងសកម្មភាពរបស់ នួន ជា, អៀង សារី ហើយនិង ខៀវ សំផន នៅក្នុងសម័យកាលក្រោយឆ្នាំ១៩៧៩។ សំណួរដែលទាក់ទងទៅបញ្ហានេះ គឺពាក់ព័ន្ធ ប៉ុន្តែមេធាវីបានសួរទាក់ទងទៅនឹងការរៀបចំសេចក្តីព្រាងរដ្ឋធម្មនុញ្ញ គឺក្រោយឆ្នាំ១៩៧៩ នេះគឺមិនទាក់ទងទៅនឹងវិសាលភាពនៃការសវនាការជំនុំជម្រះនេះទេ។

[១៤:០៩:៣០]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអនុញ្ញាតឆ្លើយតបដោយសង្ខេប។ ទស្សនៈ និងបរិបទដែលទាក់ទងពីមុន ហើយនិងក្រោយដីកាដំណោះស្រាយនោះ គឺមិនកម្រិតត្រឹមតែទ្រឹស្តីនៃការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទេ។ ប៉ុន្តែត្រូវតែចូល ដាក់បញ្ចូលនូវទ្រឹស្តីដោះបន្ទុករបស់មេធាវីការពារនោះផងដែរ។ ហើយយើងបានបញ្ជាក់ជា

ញឹកញាប់មកហើយ ថាអ្វីដែលកើតឡើងបន្ទាប់ពីឆ្នាំ១៩៧៩ ភ្លាមៗនោះ គឺកងទ័ពវៀតណាម ហើយនិងការប្រើប្រាស់ឯកសាររបស់វៀតណាម លើឯកសារការប្រមូលឯកសារ ការសរសេរប្រវត្តិសាស្ត្រឡើងវិញ គឺថាពាក់ព័ន្ធខ្លាំងណាស់ក្នុងរឿងក្តីនេះ។ ខ្ញុំមិនឃើញថាមានមូលហេតុអ្វីដែលលោក លីសាក់ លើកឡើងអំពីបរិបទ ដែលថា គប្បីតែកម្រិតទាក់ទងទៅនឹងបញ្ហាដែលទាក់ទងលោក នួន ជា ទេ។ ហើយខ្ញុំមិនគិតថា មិនយុត្តិធម៌ មិនសមស្រម ដែលឲ្យគាត់លើកបែបនេះទេ ហើយដែលថាចៅក្រមមិនអាចនឹងមានហេតុផលអ្វីយល់ស្របទៅនឹងការជំទាស់នោះទេ។ បរិបទនេះវាពាក់ព័ន្ធ គឺថាវាពាក់ព័ន្ធចំពោះមេធាវីការពារ ហើយនិងចំពោះសហព្រះរាជអាជ្ញាក៏ដូចគ្នាដែរ។

បាទ ដូច្នេះ ខ្ញុំរង់ចាំបាទ។

[១៤:១១:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១២:៤៥]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ត្រឹមត្រូវ។ សំណួរនេះ គឺក្រៅអង្គហេតុមិនពាក់ព័ន្ធទេ។ សេចក្តីជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ទេ។

**លោក អេនគ្រូ អ៊ីនូហ្សិ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជម្រាបជូនដល់អង្គជំនុំជម្រះទាំងមូលថា ខ្ញុំសុំការគាំទ្រទាក់ទងទៅនឹងសេចក្តីសម្រេចដែលលោកប្រធានទើបតែសម្រេចអំមិញនេះ។ គឺថាអ្វីដែលខ្ញុំលើកឡើងនេះគឺថាជា--

**ប្រធានអង្គជំនុំ៖**

ចប់ហើយ បន្តសំណួរទៀតប្រសិនបើមានសំណួរ។ យើងមិនអនុញ្ញាតឲ្យលោកធ្វើអត្ថាធិប្បាយពីលើសេចក្តីសម្រេចរបស់យើងទេ។ ផ្លូវដែលលោកដើរ គឺប្តឹងសាទុក្ខទៅតុលាការកំពូលនូវអ្វីដែលលោកមិនសុខចិត្ត ហើយអនុវត្តតាមវិធានផ្ទៃក្នុងដែលមានចែង។

**លោក អេនគ្រូ អ៊ីនូហ្សិ៍៖**

សូមអរគុណលោកប្រធាន។ គឺថាអាច ខ្ញុំអាចប្តឹងតាមតែចុងបញ្ចប់នៃសវនាការនេះ ប៉ុណ្ណោះ

តាមវិធានផ្ទៃក្នុង។ ដូច្នេះហើយ ខ្ញុំពិបាក។ ដូច្នេះ ខ្ញុំសូមបន្តសំណួរទៅមុខទៀតបាទ។

**ប្រធានអង្គជំនុំ៖**

បើលោកមានសំណួរតទៅមុខទៀត សូមអញ្ជើញ!

**សួរដោយលោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

**ស៖** សូមអរគុណជាថ្មីម្តងទៀត លោកសាក្សី ខ្ញុំមិនបញ្ជាក់ថាលោកចូលរួមក្នុងការសរសេរប្រវត្តិសាស្ត្រនោះទេ។ ប៉ុន្តែខ្ញុំចូលទៅដល់ចំណុចមួយដែលថា លោក លីសាក់ យល់ស្របជាមួយខ្ញុំ គឺថាពេលវេលាដែលលោកធ្វើការនៅទីនោះ។ តើត្រឹមត្រូវដែរឬទេ ដែលយើងថា នៅក្នុងពេលនេះដែលថាវៀតណាមគឺ ចាប់អារម្មណ៍ក្នុងការដាក់បញ្ចូលដែលគេចង់បាននូវខ្លឹមសារឲ្យក្លាយទៅជាប្រវត្តិសាស្ត្រកម្ពុជានៅពេលនោះ។ ថាតើការនិយាយបែបនេះសមស្របដែរឬទេ ផ្អែកទៅលើអ្វីជាបទពិសោធន៍លោកនៅទួលស្លែងកាលណោះនោះ?

[១៤:១៥:២៨]

**លោក អុង ថុងហឿង៖**

**ឆ៖** នៅពេលនោះជាការពិត វៀតណាមបានមក -- នៅទួលស្លែងគឺ ម៉ៃឡាំ ដែលជាជនជាតិវៀតណាមគាត់ដឹកនាំ គាត់ធ្វើជាប្រធានទួលស្លែងនៅពេលនោះ ហើយហ្នឹងជាការពិត។ ហើយជាការពិតដែរ មិនដឹងជាលោកមេធាវីចង់បានអីទេ ប៉ុន្តែថា ជាការពិតដែរ គឺដែលជនរងគ្រោះដែលបានស្លាប់ដែលមាននៅទួលស្លែងនោះគឺក៏ជាការពិតដែរ គឺអានោះគឺជាការពិត ដែលស្លាប់ដោយសាររបបខ្មែរក្រហម។ ហើយជាមួយគ្នាហ្នឹង ខ្ញុំក៏ឆ្លើយនឹងលោកគឺថា នៅពេលនោះប្រាកដមែនហើយ គឺថាវៀតណាមគាត់ចង់ឲ្យ យើងខ្ញុំមាន វ៉ាន់ឌី កាអុន, មាន សាំងកង់ សេណារ៉ាត ហើយនិងមិត្តភក្តិមួយចំនួនទៀត សរសេរសៀវភៅប្រវត្តិសាស្ត្រឡើងវិញ ដើម្បី -- ពីព្រោះពេលនោះអត់មានសៀវភៅប្រវត្តិសាស្ត្រសម្រាប់ការសិក្សារបស់យុវជនខ្មែរ ប៉ុន្តែដែលដោយមានការចុះសម្រុងគ្នា ខ្ញុំក៏បានរត់ចេញពីស្រុកខ្មែរបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ហើយនៅពេលដែល ក្រោយឆ្នាំ១៩៧៩ ខ្ញុំសូមឲ្យលោកបញ្ជាក់ពីម្សិលមិញនោះគឺថា មានការយល់ច្រឡំបន្តិចទាក់ទងទៅនឹងបញ្ហាការបកប្រែ ហើយក៏មានការច្រឡំអំពីក-១៥ ហើយនិង ក-៥។ បាទគឺ លោកសាក្សីតើលោកយល់អំពី ក-៥ តើការកែន ក-៥ ហ្នឹងជាអ្វីតើលោកធ្លាប់ឮពាក្យនេះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបទៅនឹងសំណួរនេះ!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៤:១៧:៤៤]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ខ្ញុំសូមបំភ្លឺនូវអ្វីដែលសហភាតាខ្ញុំបានលើកឡើង គឺថាយើងមានសំណួរទាក់ទងទៅនឹង ក-១៥ ទេ ដែលសាក្សីទៅកន្លែងនោះពីពោធិ៍ចិនតុង ហើយបើសិនជាពេលណាមួយនោះ បកប្រែទៅជា ក-៥ ដោយសារអ្នកបកប្រែនោះគាត់ភ័ន្តច្រឡំ នេះជា -- ក៏ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ប៉ុន្តែនៅពេលដែលយើងពិភាក្សាគ្នានោះ យើងនិយាយពីក-១៥ ទេ អ៊ីចឹងពុំមានទំនាក់ទំនងអីនឹង ក-៥ ទេ។ បាទ អ៊ីចឹងសូមអរគុណ។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអភ័យទោស ហើយខ្ញុំមិនមានន័យថា ចង់ជំទាស់ទៅនឹងសហព្រះរាជអាជ្ញាទេ។

**សួរដោយលោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

**ស៖** លោកសាក្សី ក៥ គឺទាក់ទងទៅនឹងទ្រឹស្តីការពាររបស់ខ្ញុំ ហើយខ្ញុំសួរលោក តើលោកដឹងអ្វីខ្លះអំពីក-៥ អំពីកំណែន ក៥ នេះ ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ! សំណួរនេះក្រៅអង្គហេតុ មិនពាក់ព័ន្ធទេ។

[១៤:១៩:០០]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងយល់ស្រប ប្រសិនបើសាក្សីមិនដឹង ប៉ុន្តែយើងបានជម្រាបហើយថា បញ្ហានេះទាក់ទងទៅនឹងចំនួនមនុស្សស្លាប់សរុប ហើយនិងទាក់ទងទៅនឹងការការពារក្តីរបស់ខ្ញុំថាតើ--

**ប្រធានអង្គជំនុំ៖**

យើងមិនបណ្តែតបណ្តោយឲ្យលោកធ្វើអត្ថាធិប្បាយទេ។ បញ្ហានេះ ដូចយើងបាននិយាយច្រើនលើកច្រើនសាហើយ យើងនឹងគ្រប់គ្រងបញ្ហានេះឲ្យខាងតែបាន។

**លោក អេនឌ្រូ អ៊ីនូហ្សឺ៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះ ខ្ញុំទៅខាងមុខទៀតទាក់ទងទៅនឹងផ្នែកដែលជាក់លាក់ ដែលនិយាយនៅក្នុងដីកាដំណោះស្រាយ ហើយនិងជាកម្មវត្ថុ ដែលត្រូវសួរដេញដោលសម្រាប់ពីរថ្ងៃចុងក្រោយនេះ។ ឥឡូវនេះ ខ្ញុំនិយាយអំពីបឹងត្របែក។

[១៤:១៩:៥៧]

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្សឺ៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរលោកត្រឡប់ទៅនឹងសក្ខីកម្មរបស់លោកពីម្សិល និងថ្ងៃនេះ។ ទាក់ទងទៅនឹងការស្នាក់ទី២ របស់លោកនៅបឹងត្របែក គឺថា១ពីរបីខែចុងក្រោយ នៃកម្ពុជាប្រជាធិបតេយ្យ តើអ៊ីចឹងមែនទេ?

**លោក អុង ថុងហឿង៖**

**ឆ៖** បាទ អ៊ីចឹងមែនហើយ។

**ស៖** សូមអរគុណលោកសាក្សី ឥឡូវនេះក្នុងទាក់ទងទៅនឹងសំណួរមួយចំនួនរបស់ខ្ញុំ បន្ទាប់ទៅនេះ ហើយខ្ញុំ -- ចំណុចទី២ ដែលលោកបាននិយាយរួចហើយ សូមបញ្ជាក់ដែលថាលោកជម្រាបទៅអ្នកស៊ើបអង្កេតនៅឆ្នាំ១៩៨០។ មុនសម្រាកនេះគឺថា មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីពិភាក្សាជាមួយលោក ហើយលោកបានប្រាប់គាត់ថា ហោ ណាំហុង គឺជាអ្នកគ្រប់គ្រងក្រុមមួយនៅក្នុងប-៣២ តើអ៊ីចឹងទេ?

[១៤:២១:០៣]

**ឆ៖** បាទ គឺគាត់ជា -- ខ្ញុំបញ្ជាក់ផងដែរ គាត់ជាខ្មែរមកពីបរទេសដូចយើងខ្ញុំ ហើយគេចាត់តាំងគាត់ជាប្រធានប-៣២ ពេលខ្ញុំមកពីដីក្រហមវិញ។

**ស៖** សូមអរគុណលោកសាក្សី។ សូមលោកបំភ្លឺ តើត្រូវដែរឬទេថាគាត់បានទទួលតំណែងបន្ទាប់ពី សាវ៉ន បានបាត់ បន្ទាប់ពី វ៉ាន់ ពីនី បានបាត់ខ្លួន តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ប្រាកដហើយ។

**ស៖** សូមអរគុណលោកសាក្សី។ ដើម្បីឲ្យច្បាស់គឺថាទី១ គឺជាអនុប្រធាន ហើយក្រោយមកគាត់បានក្លាយជាប្រធាន តើការទទួលខុសត្រូវរបស់គាត់ហ្នឹងក្នុងឋានៈជាប្រធាន គាត់ធ្វើអ្វីខ្លះ?

**ឆ៖** ខ្ញុំ -- ពេលខ្ញុំមកដល់ពីដីក្រហមវិញ វាសភាពការណ៍ធូរស្រាល ខ្ញុំមិនបានដឹងថាពីមុនវាយ៉ាងម៉េចខ្លះទេ។ កាលពីមុនមានការបាត់ខ្លួនមែន ប៉ុន្តែពេលខ្ញុំមកដល់លែងមានការបាត់ខ្លួនហើយ។

ប៉ុន្តែដើម្បីឲ្យច្បាស់កន្លែងហ្នឹង ខ្ញុំនិយាយឲ្យ -- ដើម្បីកុំឲ្យមានការសង្ស័យ។ ខ្ញុំ -- ហើយខ្ញុំមិនមែន -- និយាយនេះគឺថាជាៗការដែលខ្ញុំយល់។ ខ្ញុំមិនយល់ថាលោក ហោ ណាំហុង ជាកម្មាភិបាលរបស់ ខ្មែរក្រហមទេ។ ខ្ញុំមិនយល់ថា -- ខ្ញុំមិនៗ -- គ្មានឯកសារថាលោក ហោ ណាំហុង នេះជាបក្ខជនរបស់បក្សកុម្មុយនីស្តកម្ពុជាទេ។ ខ្ញុំមិនជឿថាលោក ហោ ណាំហុង នេះគាត់ដឹងថាសម័យនោះ គាត់ដឹងថាមានអេស-វ៉ាំងតេអង់ ទេ។ អាហ្នឹងជាការជំនឿរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំមិនដឹងថាលោកមេធាវីចង់ឆ្លើយ -- ចង់សួរខ្ញុំពីរឿងអី ប៉ុន្តែខ្ញុំជា នេះខ្ញុំច្បាស់ក្នុងចិត្តខ្ញុំ ហើយខ្ញុំអត់និយាយការពារគាត់ទេ ខ្ញុំការពារយុត្តិធម៌បាទ។

[១៤:២៣:៣៤]

**ស៖** សូមអរគុណលោកណាស់ លោកសាក្សី ដែលខ្ញុំចង់បានព័ត៌មានគឺប៉ុណ្ណឹង។ ខ្ញុំសូមសរសើរ។ នៅពេលនោះថា តើឈ្មោះបដិវត្តន៍របស់គាត់ឈ្មោះ យ៉ែម ឬ យឹម អ៊ីចឹងមែនឬទេ? តើខ្ញុំអានឈ្មោះហ្នឹងត្រូវទេ?

**ឆ៖** គាត់ឈ្មោះ យ៉ែម បាទ យ៉ែម។

**ស៖** សូមអរគុណលោកសាក្សី។ ហើយដើម្បីឲ្យច្បាស់នៅក្នុងកំណត់តុលាការ គាត់និយាយ -- លោក ហោ ណាំហុង គាត់ជារដ្ឋមន្ត្រីក្រសួងការបរទេសបច្ចុប្បន្ន នៃព្រះរាជណាចក្រកម្ពុជា។

**ឆ៖** សូម -- ខ្ញុំអត់យល់បាទ សូមសួរសំណួរឡើងវិញ។

**ស៖** បាទ លោកៗបាននិយាយពីលោក ហោ ណាំហុង ឥឡូវនេះបច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងការបរទេសនៃកម្ពុជា តើមែនឬទេ?

**ឆ៖** បាទ មែនហើយ។

[១៤:២៤:៥១]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវណោះ សូមលោកទៅឯកសារមួយទៀត នេះជាសៀវភៅរបស់លោក ជាសៀវភៅដែលយើងបានពិភាក្សារួចហើយព្រឹកមិញនេះ ក្នុង -- ខ្ញុំយល់ថាខ្ញុំមិនចាំបាច់អាន ERN នោះឡើងវិញទេ ខ្ញុំយល់ថាភាគីបានជ្រាបហើយ តើលោកសាក្សី លោកសាក្សីលោកមានសៀវភៅចំពោះមុខលោកទេ?

**ឆ៖** បាទ ខ្ញុំយកមក២-៣ថ្ងៃហើយ ប៉ុន្តែអត់ -- ពីមុនអត់ឲ្យខ្ញុំបើក ខ្ញុំអត់បានយកមកទៀតទេបាទ។

**ស៖** ខ្ញុំគិតថាលោកមាន -- យើងមានឯកសារមួយចំនួននៅតុលាការនេះ ខ្ញុំសូមនិយាយអំពីឯកសារ D141/1.2 ជាអត្ថបទភាសាខ្មែរ និងបារាំងទាំងស្រុងនៅក្នុងសំណុំរឿង គឺថាមានសេចក្ដីដកស្រង់ជាភាសាអង់គ្លេសតិចទេ ប៉ុន្តែគឺមិនទាក់ទងទៅនឹងផ្នែកមួយដែលនិយាយ ដែលខ្ញុំចង់សួរលោកនៅថ្ងៃនេះ ខ្ញុំនឹងផ្ដោតតែចំណុចនោះតែប៉ុណ្ណោះ។

[១៤:២៦:០៦]

ខ្ញុំសូមអនុញ្ញាតដើម្បីបង្ហាញលើអេក្រង់ ដើម្បីឲ្យតុលាការងាយស្រួល។ ខ្ញុំមានសំណួរប្រាំដែលខ្ញុំចង់សួរលោកអំពីសៀវភៅរបស់លោក ហើយសុំឲ្យលោកបញ្ជាក់ ដោយសារលោកជាអ្នកនិពន្ធ។ ទី១ នៅទំព័រ២០៧ នៅក្នុងភាសាបារាំងនៃសៀវភៅរបស់លោក។ បារាំង ERN 00288086, ខ្មែរ ERN 0083121 -- អ៎! 41។ ខ្ញុំមើលផ្នែកមួយដែលថាដែលលោកបានឃើញហើយ និយាយថា "ជីវិតនៅបឹងត្របែក គឺដូចជានៅឋាននរក ក្រោមពីការដឹកនាំរបស់ សារ៉ន, ភាគ, ហួត, ហើយនិង ឯក។ តើលោកនៅប្រកាន់ខ្លឹមសារនៅក្នុងសៀវភៅរបស់លោកដដែលនេះឬទេ លោកសាក្សី?

**ឆ៖** បាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងត្រឡប់ទៅទំព័រ២២១ អត្ថបទភាសាបារាំង 00288100, ខ្មែរ 00831253 រហូតទៅដល់ 254។ ហើយមាននៅក្នុងនេះ គឺនិយាយថា ដែលសុន្ទនាជាមួយខ្ញុំបានបញ្ជាក់ថា ហោ ណាំហុង និង វ៉ាន់ ពីនី ជាឧបករណ៍យ៉ាងស្លូតរបស់ សារ៉ន -- យ៉ាងស្លូតរបស់ សារ៉ន -- ហើយធ្វើតឹងរ៉ឹងអ្នកដែលនៅក្រោមការគ្រប់គ្រងរបស់គាត់។ តើលោកប្រកាន់នូវខ្លឹមសារផ្នែកនេះនៃសៀវភៅរបស់លោកថា ត្រឹមត្រូវដដែលទេ?

[១៤:២៨:៣១]

**ឆ៖** នេះដែលខ្ញុំបានឮ ខ្ញុំបានឮមែនបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ហើយយើងនៅលើទំព័រដដែលនេះ នៅចុងឆ្នាំ -- អ៎!នៅចុងខែតុលា ឆ្នាំ១៩៧៨ មានការប្រជុំមួយ ហោ ណាំហុង នៅរក្សាតួនាទីជាប្រធាន ហើយនៅក្នុងគណៈកម្មាធិការមួយ ដែលមានសមាជិកប្រាំនាក់។ តើខ្លឹមសារហ្នឹងត្រឹមត្រូវអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** សូមអរគុណ។ ឥឡូវនេះយើងទៅមើលទំព័រ២២២ បារាំង ERN 00288101, ខ្មែរ 00831254។ នៅទីនេះ គឺថាគឺសមាជិកភាគច្រើនទាំងអស់បានបាត់ មានតែ ចាន់ យូរ៉ាន់ និង ហោ

ណាំហុង ទេ ដែលនៅទីនោះបាទ។ ដែលទៅជាអ្នកបម្រើរបស់អង្គការ ឃ្លាចុងក្រោយនោះ ដោយស្មោះត្រង់។

**ឆ៖** បាទ ខ្ញុំទទួលស្គាល់ថា ខ្ញុំបានសរសេរ។

**ស៖** សូមអរគុណលោកសាក្សី។ ចំណុចមួយទៀត នៅក្នុងសៀវភៅរបស់លោក ឥឡូវនេះ ទំព័រ ២២៣ បារាំង ERN 00288102, ខ្មែរ ERN 00831255។ នៅទីនេះ គេសរសេរថា គេនិយាយថា ហើយលោកយោងទៅសៀវភៅខ្មៅ ដែលយើងបានប្រើថា ហោ ណាំហុង និង ពេជ ប៊ុនតុង បានបកប្រែសៀវភៅនេះ អស់ជិតមួយថ្ងៃបាទ។ តើលោកប្រកាន់ថា ខ្លឹមសារនៅត្រឹមត្រូវដដែលឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ តាមដែលខ្ញុំបានឃើញនេះ។

[១៤:៣១:១០]

**ស៖** ផ្អែកតាមបទពិសោធន៍របស់លោក នៅបឹងត្របែក អ្វីដែលលោកបានសរសេរអំពីលោក ហោ ណាំហុង នោះ តើលោកអាចនិយាយបានទេ ថាគាត់មានព័ត៌មានអ្វីដែលឲ្យអង្គជំនុំជម្រះបានយល់បានអំពីរចនាសម្ព័ន្ធនៃបឹងត្របែក លោកអាចជម្រាបបានឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

បាទ លោកប្រធាន ខាងការពារក្ដីនោះ ចង់ឲ្យសាក្សីនេះ ឆ្លើយព្រាវៗហើយ ដោយសួរថា តើ ហោ ណាំហុង ហ្នឹង អាចមកពិពណ៌នារចនាសម្ព័ន្ធបឹងត្របែកនេះ ឬអត់ ថាជាការសុំឲ្យគាត់ឆ្លើយព្រាវៗ។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំមិនបានស្នើសុំសាក្សីស្មាននោះទេ គ្រាន់ឲ្យនិយាយអំពីបទពិសោធន៍ដែលគាត់បានឆ្លងកាត់នៅទីនោះ។ នេះ គឺមានការពាក់ព័ន្ធយ៉ាងច្បាស់ ទៅនឹងផ្នែកមួយនៃដីកាដំណោះស្រាយអំពីរចនាសម្ព័ន្ធ និងមុខងាររបស់ស្ថាប័នកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំគិតថា សាក្សីរូបនេះ គឺថាលោកអាចប្រាប់អង្គជំនុំជម្រះបាន ថាតើលោក ហោ ណាំហុង អាចមកបំភ្លឺបានអំពីរចនាសម្ព័ន្ធនៅទីនោះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងនៃសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ត្រឹមត្រូវ។ សេចក្ដី

ជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរបែបបនេះទេ។

[១៤:៣៣:០០]

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតបន្តទៅទៀត។

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

**ស៖** លោកសាក្សី ដោយសារលោកជាបញ្ញវន្ត ហើយលោកអ្នកមានចំណេះដឹងខ្ពស់ ហើយគឺថាលោកដែលមានសិទ្ធិនិយាយជាទូទៅ ទាក់ទងទៅនឹងប្រវត្តិសាស្ត្រកម្ពុជាផងដែរ។ តើលោកអាចប្រាប់អង្គជំនុំជម្រះបានទេ ដែលថាមានបែងចែករវាងបទឧក្រិដ្ឋ ដែលលោកលើកឡើងម្សិលមិញ រវាងមេដឹកនាំកម្ពុជានៅពេលសព្វថ្ងៃនេះ តើវាខុសគ្នាដូចម្តេច?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលអាន់ឆ្លើយ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ខាងការពារក្តីនេះ គឺថានិយាយឲ្យប្រាស់ចាកពីដីកាដំណោះស្រាយហើយ។ អ៊ីចឹងហើយ បានយើងទីនេះ ពិភាក្សាគ្នាក្នុងសវនាការនេះ គាត់និយាយហួសវិសាលភាពហើយ។

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

ជំហររបស់យើង គឺយើងយល់ថា យើងត្រូវ -- តើកូនក្តីរបស់យើងអាចនឹងបានការជំនុំជម្រះដោយយុត្តិធម៌ដែរ ឬក៏អត់? ហើយបញ្ហានោះ ដែលយើងបានបញ្ជាក់ពីកាលខាងដើម គឺវាមានចំណុចពាក់ព័ន្ធ។ ដូច្នេះ ហើយយើងមានមូលដ្ឋានដើម្បីសួរសាក្សី ដែលសហព្រះរាជអាជ្ញាលើកអ៊ីចឹង គឺថាមិនសមស្របទេ គឺកំណត់ត្រាបានកត់ហើយ គឺនេះវាពាក់ព័ន្ធទៅនឹងអង្គហេតុ និងប្រធានបទ ដែលយើងត្រូវចោទសួរនេះឯង។

[១៤:៣៤:២៩]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងសំអាងនៃសេចក្តីជំទាស់ ត្រឹមត្រូវ។ សេចក្តីជំទាស់មានប្រសិទ្ធភាព សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរប្រភេទនេះទេ។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

**ស៖** លោកសាក្សី តើអ្នកណាដែលលោកបានរៀបរាប់ក្នុងពាក្យរបស់លោកថា ជាបុរសខ្លាំងនៅកម្ពុជា ថាតើជាមនុស្សដែល ថាជាមនុស្សកំពូលដែលថាមនុស្សគ្មានក្ដីមេត្តា។ តើអ៊ីចឹងដែរឬទេដែលលោកនិយាយនោះ?

[១៤:៣៥:១០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

បើកក្បាលមីក្រូ!

**លោក ច័ន្ទ តារាស្មី៖**

ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ការលើកឡើងរបស់លោកមេធាវីការពារក្ដីលោក នួន ជា នេះគឺមិនត្រឹមត្រូវទេ មិនពាក់ព័ន្ធទៅនឹងអង្គហេតុ និងការដែលយើងត្រូវការនៅពេលនេះទេ។ អ៊ីចឹងសូមជំទាស់សំណួរនេះបាទ លោកប្រធាន។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

ជាថ្មីម្ដងទៀត លោកប្រធាន នេះគឺទាក់ទងបញ្ហាផ្ទាល់ទៅនឹងអនិទណ្ឌភាព ហើយនិងនិយាយអំពីអំពើលាក់ពុតនៅក្នុងកិច្ចនយោបាយ ដែលថាយើងអាចនឹងគេចោទប្រកាន់អំពីករណីនៅតុលាការនេះ។

[១៤:៣៥:៥៤]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងមូលហេតុ សំអាងហេតុនៃសេចក្ដីជំទាស់ត្រឹមត្រូវ។ សេចក្ដីជំទាស់មានប្រសិទ្ធភាព សាក្សីមិនចាំបាច់ឆ្លើយតបនឹងសំណួរប្រភេទនេះទេ។

ទំនងជាអត់មានសំណួរអីទៀតទេមើល៍ទៅ មិនចេះសួរឲ្យបានសួរទេ គួរតែសួរដើម្បីឲ្យមានការពាក់ព័ន្ធផ្ទាល់ទៅនឹងអង្គហេតុដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

ខ្ញុំមានសំណួរមួយចំនួនសម្រាប់ជូនសាក្សី។ បើសិនជាខ្ញុំមិនអាចសួរនោះទេ បើខ្ញុំមិនអាច

សួរបាន ខ្ញុំសូមបញ្ចប់ត្រឹមនេះ ហើយសូមអរគុណលោកសាក្សីដែលបានប្រឹងប្រែងពេលនេះ ហើយនិងប្រគល់វេទិកាទៅដល់សហសេវិករបស់ខ្ញុំដើម្បីសួរបន្ត។ បាទ សូមអរគុណ។

[១៤:៣៦:៥៧]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ សូមជម្រាបសួរលោក អ៊ុង ថុងហឿង ជាសាក្សី។ ខ្ញុំឈ្មោះ សុន អរុណ ជាមេធាវីជាតិការពារលោក នួន ជា។

**សួរដោយលោក សុន អរុណ៖**

**ស៖** បន្ទាប់ពីសហសេវិកខ្ញុំបានសួរសំណួរច្រើនខ្លះមកដែរហើយ ខ្ញុំមានតែសំណួរបីបួនប្រាំទេ ដើម្បីសួរលោកនៅពេលនេះ។ លោកសាក្សី តាមខ្ញុំស្តាប់ការឆ្លើយតបរបស់លោកទៅនឹងសហព្រះរាជអាជ្ញាកាលពីថ្ងៃទី០៧ ខែ៨ ពីរឿងរណសិរ្សរួបរួមជាតិកម្ពុជា និងបក្សកុម្មុយនីស្តកម្ពុជា គេហៅថា ហ្នុង និង ភី.ស៊ី.ខេ បក្សកុម្មុយនីស្តកម្ពុជា មុនឆ្នាំ១៩៧៥។ សូមលោកបំភ្លឺបញ្ជាក់ក្រុមទាំងពីរនេះ តើធ្វើការជាមួយគ្នាយ៉ាងរៀបណា? លុះដល់ក្រោយឆ្នាំ១៩៧០ មានន័យថា ក្រោយពី លន់ នល់ ទម្លាក់សម្តេច នរោត្តម សីហនុ តើក្រុមទាំងពីរខាងលើធ្វើការជាមួយគ្នាពីពេលណាមក? ហើយសហការរបៀបណាដែរ?

[១៤:៣៨:៤០]

**លោក អ៊ុង ថុងហឿង៖**

**ឆ៖** ជាប្រវត្តិសាស្ត្រ ខ្ញុំមិនបាច់និយាយឡើងវិញ ជាប្រវត្តិសាស្ត្រគណបក្សកុម្មុយនីស្តកម្ពុជា គឺអ្នកផ្សេងទៀតបាននិយាយជាមុនខ្ញុំច្រើនណាស់។ ខ្ញុំមិនបាច់លើកនិយាយឡើងវិញទេ។ គ្រាន់តែសំណួររបស់លោក ខ្ញុំគ្រាន់ចង់ឆ្លើយអ៊ីចេះ ចង់ឆ្លើយថា គណបក្សកុម្មុយនីស្តកម្ពុជាដែលមាន សាឡុត ស ឬក៏ជាលេខាហ្នឹងគឺជាអង្គការមួយសម្ងាត់ ហើយជាទូទៅក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ បងប្អូនយើងទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេសអត់ដឹងថាលោក ខៀវ សំផន ក្តី, លោក ហ៊ូ នឹម ក្តី, លោក ហ៊ូ យន់ ក្តីជាកុម្មុយនីស្ត ជានៅ -- ដែលជាអ្នកធ្វើជាសមាជិកបក្សកុម្មុយនីស្ត ហើយគេទាំងអស់គ្នាគេអត់ដែលស្គាល់ សាឡុត ស ឬក៏ ប៉ុល ពត ហ្នឹងថាយ៉ាងម៉េចទេបាទ។ គេអត់ដែលឮសូរឈ្មោះភាគច្រើន ខ្ញុំនិយាយអ្នកគឺថាអាហ្នឹងគេអត់ដែលដឹងទេ។

ដូច្នេះ ខ្ញុំនិយាយថា គឺដូច្នេះគឺយើងមិនអាចនិយាយថា រណសិរ្សរួបរួមជាតិកម្ពុជាហ្នឹងសហការ

ជាមួយគណបក្សកុម្មុយនីស្តកម្ពុជាទេ គឺថារណសិរ្សរួបរួមជាតិកម្ពុជាកើតឡើងគឺថា រួបរួមជាមួយឥស្សរជនដែលប្រជារាស្ត្រពីដើមមកធ្លាប់ទទួលស្គាល់ថា មាន -- ជាអ្នកស្អាតស្អំដូចជាលោក ហ៊ូ យន់, លោក ហ៊ូ នឹម, លោក ខៀវ សំផន ហើយនិងបញ្ញវន្តមួយចំនួនទៀត។ ដូច្នេះខ្ញុំៗឆ្លើយចំពោះលោកតែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ពេលក្រុមទាំងពីរខាងលើដែលខ្ញុំបានសួរលោករួចមកហើយនោះ បានចូលធ្វើសហការគ្នាក្រោមការដឹកនាំរបស់សម្តេច នរោត្តម សីហនុ តើពេលនោះក្រុមខ្មែរក្រហម គឺបក្សកុម្មុយនីស្តកម្ពុជាមានឈ្មោះអ្វី? មានដាក់ឈ្មោះអីផ្សេងទេ គឺក៏នៅបក្សកុម្មុយនីស្តកម្ពុជាអ៊ីចឹងដដែល? អាហ្នឹងមួយ។ រឿងពីរ ឬប្រើពាក្យ ហ្វ៊ុង នេះជាមួយគ្នាដើម្បីសហការប្រយុទ្ធជាមួយគ្នា? អាហ្នឹងជាសំណួរទី២។

[១៤:៤១:៣៨]

**ឆ៖** សូមឆ្លើយ។ លោកមេធាវីជាទីគោរព ខ្ញុំមិនដែលមានឃើញការចុះហត្ថលេខាកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងគណបក្សកុម្មុយនីស្តកម្ពុជា ជាមួយរណសិរ្សរួបរួមជាតិកម្ពុជាទេ។ ព្រោះខ្ញុំគ្រាន់តែឃើញរណសិរ្សរួបរួមជាតិកម្ពុជា បង្កើតឡើងដោយសម្តេច សីហនុ ហើយមានលោកអ្នកដឹកនាំផ្សេងៗគាត់ចូលរួម ប៉ុន្តែខ្ញុំមិនដែលឃើញមានថា លោក ប៉ុល ពត បានទៅជួបជាមួយសម្តេចសីហនុបានជជែកពិភាក្សាគ្នា ទៅចុះហត្ថលេខារួម មានកម្មវិធីរួម ខ្ញុំ -- ប្រហែលជាលោកបាន ធ្លាប់បានឃើញ ប៉ុន្តែខ្ញុំបាទអត់ដែលបានឃើញទេបាទ។

**ស៖** ខ្ញុំរលងបន្តិច ខ្ញុំភ្លេចសួរថា លោកចូលគណបក្ស -- ចូលរណសិរ្សរំដោះជាតិកម្ពុជាហ្នឹងគឺហ្វ៊ុង ហ្នឹងអង្កាល់ពីពេលវេលាណាដែរ?

**ឆ៖** ក្រោយ ខ្ញុំបានរណសិរ្សក្រោយការ ក្រោយសេចក្តីថ្លែងការណ៍របស់សម្តេច សីហនុ សេចក្តីថ្លែងការណ៍៥ចំណុចរបស់សម្តេច សីហនុ ខែ៣ ឆ្នាំ១៩៧០។

**ស៖** មានន័យថា ក្រោយពេលដែល លន់ នល់ បានទម្លាក់សម្តេចរួចហើយអ៊ីចឹងមែនទេ?

**ឆ៖** បាទ មែនហើយ។

**ស៖** លោកជាសមាជិករបស់ ហ្វ៊ុង តាំងពីខែ៣ ១៩៧០ លោកដឹងថា ហ្វ៊ុង ហ្នឹងធ្វើការតស៊ូមានសម្ភារៈ និងអាវុធបានមកពីណាទេ?

[១៤:៤៣:៥៤]

**ផ៖** ខ្ញុំដឹងថា ភាគច្រើនបានមកពីប្រទេសចិនប្រជាមានិត។

**ស៖** អរគុណណាស់។ ពីអំមិញហ្នឹងលោកបានឆ្លើយមកសហសេវិករបស់ខ្ញុំ ថាលោកបានធ្វើការនៅ ស-២១ លោកអាចបញ្ជាក់ម្តងទៀតបានទេ ថាធ្វើការចាប់ពីពេលណាដល់ពេលណា?

**ផ៖** ខ្ញុំអាច -- អត់អាចបញ្ជាក់បាន គ្រាន់តែថាខ្ញុំធ្វើពីខ្ញុំធ្វើរហូតដល់ខែ១១ ឆ្នាំ១៩៧៩ ខ្ញុំ-- ដូច្នេះខ្ញុំធ្វើបីខែ ប្រហែលជាខែ១០, ១១, ១២ ប្រហែលប៉ុណ្ណឹង ៧៩បាទ។ សូមទោស ខ្ញុំចាស់ហើយខ្ញុំមិនថ្ងៃខែខ្ញុំវាមិនចាំភ្លាមៗអ៊ីចឹងបានទេ ខ្ញុំអត់មានកំណត់នៅនឹងមុខខ្ញុំ។

**ប្រធានអង្គជំនុំ៖**

អរគុណណាស់លោកមេធាវី ពេលវេលាសមល្មមសម្រាកដែរហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងប្រគល់វេទិកាជូនទៅមេធាវីជាតិការពារក្តីលោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរប្រហែលជាពីរ ឬបីទៀត អស់ហើយ។

**សួរដោយលោក សុន អរុណ៖**

**ស៖** អំមិញខ្ញុំសួរដល់ត្រង់ចំណុចថា លោកបានចូលធ្វើការនៅ ពីដើមគេហៅថា ស-២១ ប៉ុន្តែក្រោយវៀតណាមវ៉ៃខ្មែរក្រហមចេញទៅគេហៅថា សាលាទួលស្លែង។ អ៊ីចឹងពិតអ៊ីចឹងទេ ដែលពេលលោកចូលទៅធ្វើការនុ៎ង? គេហៅ សាលាទួលស្លែងអ៊ីចឹង?

**លោក អុង ហុងហៀង៖**

**ឆ៖** បាទ ខ្ញុំឮសួរគេហៅ ទួលស្លែងៗបាទ។ អ៊ីចឹងមែន។

[១៥:០៤:៤៥]

**ស៖** ពេលនុ៎ងអ្នកណាកាន់កាប់ ធ្វើជាប្រធាននៅសាលាទួលស្លែងហ្នឹង នៅពេលលោកចូលទៅធ្វើការនៅទីនោះ?

**ឆ៖** ចាងហ្វាង -- មានដាក់ផ្លាកនៅខាងក្រៅ ដាក់"មន្ទីរប្រល័យពូជសាសន៍"។ ខ្ញុំមិនច្បាស់ទេ ប៉ុន្តែថា ហើយដែល -- ខ្ញុំមិនច្បាស់ ប៉ុន្តែថា ដែលលោក ម៉ៃឡាំ គាត់ធ្វើជាចាងហ្វាងទទួលខុសត្រូវនៅទួលស្លែងហ្នឹង។ គាត់ជាជនជាតិវៀតណាម គាត់ចេះនិយាយបារាំង។

**ស៖** អរគុណណាស់។ លោកឆ្ងល់ទេ ថាហេតុអីបានជាជនជាតិវៀតណាមទៅធ្វើប្រធាននៅកន្លែងមន្ទីរប្រល័យពូជសាសន៍អ៊ីចឹង? ព្រោះអីជនជាតិវៀតណាមជាជាតិមួយផ្សេងពីជនជាតិខ្មែរយើង។

**ឆ៖** អង្កាល់នោះទ័ពវៀតណាមនៅពាសពេញប្រទេសកម្ពុជា នៅកន្លែងណាក៏មានវៀតណាមដែរលោក។

**ស៖** អរគុណ។ ពេលដែលលោកទៅធ្វើការហ្នឹង លោកបានជម្រាបចម្លើយមុនៗមកថា លោកគេឱ្យលោករៀបចំឯកសារ ដែលរប៉ាត់រប៉ាយ ឬក៏ចោល ឬក៏ថា នេះដើម្បីៗនឹងរៀបចំធ្វើជាឯកសារផ្សេងៗសម្រាប់រដ្ឋ --អំ! សម្រាប់អ្នកកាន់អំណាចថ្មី។ ពេលនោះ ពេលដែលលោកធ្វើការមើលឃើញឯកសារច្រើនហើយនុ៎ង តើលោកមានបានឃើញរចនាសម្ព័ន្ធរបស់ទួលស្លែងនេះ ពីដើមគេហៅថា ស-២១ នេះ រចនាសម្ព័ន្ធដែលធម្មតា កាលណាគេធ្វើការ គេមានធ្វើជារចនាសម្ព័ន្ធបិទនឹងជញ្ជាំង ឬក៏មានជាឯកសារសៀវភៅ ឬអី មានដែលប្រទះរចនាសម្ព័ន្ធហ្នឹងទេ?

[១៥:០៧:៣៨]

**ឆ៖** ខ្ញុំដែលចាប់អារម្មណ៍ជាងគេ ទៅដល់មានមិត្តខ្ញុំម្នាក់ដែលមកពីស្រុកបារាំងដែរ គាត់ធ្វើជា *ប្រូហ្វេស័រ ហ្វីឡូ* គាត់ធ្វើជាសាស្ត្រាចារ្យទស្សនវិជ្ជា គាត់បានចូលមុនខ្ញុំ ដល់ឃើញ គាត់ឃើញខ្ញុំទៅ

ខ្ញុំដើរទៅ គាត់ឲ្យមក គាត់ក៏ថា បើខ្លួនចង់មើលឯកសារ មកធ្វើការជាមួយគ្នាមក។ ហើយខ្ញុំជាទិសដៅធំខ្ញុំចង់មើល -- ព្រោះទិសដៅធំពេលនោះគឺថា ខ្ញុំចង់មើលសារភាពមិត្តភក្តិ ដែលចេញមកបរទេស ព្រោះខ្ញុំអង្គាល់ហ្នឹង ជាជាក់ស្ដែងទៅ ខ្ញុំមិនដឹងមិត្តភក្តិដែលបាត់នៅបាត់ទៅណា អត់ទាន់ដឹងថា គេយកទៅសម្លាប់ស្លាប់ឬអី គ្រាន់ថា បាត់ៗទៅ ស្រាប់តែទួលស្លែងហ្នឹង គឺថាខ្ញុំឃើញ ឈ្មោះ សាន់វ៉ា គាត់ថា មានមិត្តភក្តិយើងនៅស្លាប់នៅទួលស្លែង។ ខ្ញុំថា បើអ៊ីចឹង ខ្ញុំចង់មើលឯកសារ នៅទួលស្លែងហ្នឹង ហើយដូច្នេះបានខ្ញុំក៏មកធ្វើការនៅទួលស្លែងហ្នឹង ដោយមានការបានពិភាក្សាជាមួយ ម៉ៃឡាំ ហើយគាត់ថា ឲ្យមកជួយធ្វើការទួលស្លែងទៅ។ ហើយឲ្យខ្ញុំក៏បានធ្វើការទៅ ហើយខ្ញុំជាពិសេស ខ្ញុំមើលឯកសារមិត្តភក្តិខ្ញុំជាពិសេសមិត្តដែលខ្ញុំធ្លាប់ស្គាល់មកពីបរទេស ធ្វើៗ ដែលបានធ្វើសារភាពនៅទួលស្លែងហ្នឹង។ ខ្ញុំហើយខ្ញុំក៏ដឹងពេលនោះ និយាយពីរចនាសម្ព័ន្ធ គាត់ -- ខ្ញុំដឹងថា ឌុច ធ្វើជាប្រធានហ្នឹង ហើយ -- ប៉ុន្តែខ្ញុំមិនបានរកវែងឆ្ងាយទេ ព្រោះរយៈពេលខ្លី ហើយខ្ញុំគ្រាន់ថា ពេលនេះពេលវាខ្លោចផ្សា គ្រាន់តែដឹងថា មិត្តភក្តិរបស់ខ្លួនស្លាប់នៅអ៊ីចឹង ដែលអាហ្នឹងវាៗ ខ្ញុំអត់បានគិតអីច្រើនទេ គិតតែធ្វើម៉េច ខំមើលឯកសារហ្នឹងឲ្យបានច្រើនបំផុត។

[១៥:០៩:៣៤]

**ស៖** បំណងរបស់ខ្ញុំសួរទៅលោកសាក្សី គឺគ្រាន់ចង់ដឹងថា លោកបានប្រទះឃើញនៅលើឯកសារណាមួយដែលមាននិយាយពីរឿងរចនាសម្ព័ន្ធ របស់មន្ទីរស-២១ កាលពីសម័យខ្មែរក្រហមទេ?

**ឆ៖** ខ្ញុំអត់បានគិតគូរដល់ហ្នឹងទេ ខ្ញុំគ្រាន់ដឹងថា ឌុច គាត់ធ្វើជាប្រធានបាទ។

**ស៖** អរគុណណាស់។ ខ្ញុំសូមដូរសំណួរទៅសំណួរមួយផ្សេងទៀត ស្ដីអំពី ពេលដែលលោកចូលជាសមាជិកហ្វុង ឬហ្រ្គុង ហើយហ្វុង និងហ្រ្គុងបានរួមគ្នាតស៊ូជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាដើម្បីវាយអាមេរិកាំងនោះ តើលោកដែលឮឈ្មោះ នួន ជា ទេ តាំងពីលោកចូលហ្វុង ឬហ្រ្គុងហ្នឹងមករហូតដល់ឆ្នាំ៧៩?

**ឆ៖** ខ្ញុំឮឈ្មោះ នួន ជា ដែលច្បាស់ជាងគេ ពេលដែលខ្ញុំឃើញគាត់ចុះហត្ថលេខាលើឯកសារជនសារភាពនៅទួលស្លែង ហើយពេលនោះបានខ្ញុំថាគាត់មានតួនាទីសំខាន់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ពីមុនមកខ្ញុំអត់ដែលបានដឹងទេបាទ។

[១៥:១១:១៧]

**ស៖** ខ្ញុំសូមបញ្ជាក់គ្រង់ថាលោកឃើញហត្ថលេខារបស់ជនសារភាពនៅទួលស្លែងហ្នឹង ជនណា?

ឈ្មោះអី?

**ឆ៖** ខ្ញុំបានឃើញជាពិសេសខ្មែរដែលចូលមកពីបរទេសដូចខ្ញុំ ខ្ញុំមិនអាចរាប់ឈ្មោះជូនលោកមេធាវីបានទេ ព្រោះថាវារាប់រយនាក់បាទ។

**ស៖** លោកអាចចាំបានម្នាក់ ឬពីរនាក់ ដែលមិត្តភក្តិណាជិតដិត ហើយមានចុះហត្ថលេខាដោយលោក នួន ជា អាចជម្រាបតុលាការបានម្នាក់ ឬពីរនាក់ទេដែលជិតដិត លោកនឹកឃើញ?

**ឆ៖** ខ្ញុំមិនអាចនឹកឃើញពេលហ្នឹងបានទេ ប៉ុន្តែខ្ញុំច្បាស់ពេលនុ៎ងខ្ញុំបានឃើញបាទ។

**ស៖** លោកមានដឹងថានៅក្នុងរយៈឆ្នាំ៧០ ដល់៧៩ មានដឹងថា នួន ជា ហ្នឹងគាត់ធ្វើអ្វីនៅក្នុងរដ្ឋាភិបាល ឬក្តី នៅក្នុងបក្សក្តី ស្អីក្តី លោកដឹងថាលោក ដែលឮហើយលោកបានស្គាល់ ឬក៏ដែលឮថាលោក នួន ជា ហ្នឹងធ្វើអ្វីទេ?

**ឆ៖** ខ្ញុំសូមគោរពលោកមេធាវី ជាទីគោរពម្តងទៀតគឺថា ខ្ញុំអត់ដែលបានស្គាល់លោក នួន ជា ឈ្មោះលោក នួន ជា មុនពេលខ្ញុំចូលធ្វើការនៅទួលស្លែងទេ។

[១៥:១៤:២០]

**ស៖** បើដូច្នេះលោកបានឃើញហត្ថលេខារបស់ នួន ជា ក្រោយពេលដែលលោកបានចូលធ្វើការនៅក្នុងសាលា --អំមិញសាលាៗអី ភ្លេចហើយ។ មន្ទីរស-២១ ថាអ៊ីចុះ។ នៅមន្ទីរស-២១ ពេលដែលលោកធ្វើការក្នុងខែ៧ ដល់ខែ១១ នុ៎ង -- ខែ៨ ឬ ខែ១១ ហ្នឹង ក្នុងឆ្នាំ១៩៧៥ហ្នឹងទេ អ៊ីចឹងទេ? នេះខ្ញុំចង់សួរបញ្ជាក់ទេ។

**ឆ៖** បាទ។

**ស៖** ពេលដែលលោកឃើញហត្ថលេខារបស់ នួន ជា ហ្នឹង បើលោកចាំថាហត្ថលេខាហ្នឹងនិយាយអំពីអី? ក្រដាសដែលលោកឃើញហត្ថលេខាហ្នឹង លោកបានអានទេ តើគេនិយាយអំពីអី?

**ឆ៖** ខ្ញុំគ្រាន់តែដឹងថា មានហត្ថលេខា គេប្រាប់ខ្ញុំអ៊ីចឹង ហើយគេថាហ្នឹង ហត្ថលេខារបស់ នួន ជា។ នួន ជា ហ្នឹង មេធំផ្ទាល់របស់ ឌុច។ ខ្ញុំគ្រាន់តែប៉ុណ្ណឹង។ ហើយខ្ញុំមិនដឹងថា នួន ជា ជាស្អីហើយគាត់អី ខ្ញុំអត់បានចាំទេបាទ។ ប៉ុន្តែខ្ញុំគ្រាន់តែបញ្ជាក់ម្តងទៀត បញ្ជាក់ហើយបញ្ជាក់ទៀត ថាខ្ញុំបានឃើញនឹងភ្នែកខ្ញុំពិតប្រាកដមែន ហើយខ្ញុំជឿជាក់ថា នៅមានឯកសារហ្នឹង នៅ អេស-ភ្នំងតែអង ឬនៅៗមជ្ឈមណ្ឌលកម្ពុជា។

[១៥:១៦:០៥]

**សៈ** បើសិនជាលោកបានឃើញហត្ថលេខាលោក នួន ជា ពេលនុំង លោកនៅចាំបានថា បើសិនខ្ញុំជូនលោកពេលឥឡូវឲ្យមើលហត្ថលេខា នួន ជា មួយទៀត តើលោកអាចនៅចាំបានថា -- លោកស្គាល់ទេ?

**ផៈ** ខ្ញុំមិនអាចស្គាល់ទេ ព្រោះខ្ញុំអត់ដែលស្គាល់ នួន ជា ពេលនោះ ហើយគេប្រាប់ថា គេ -- កង ស៊ិនរ៉ាត ហើយនិង អ៊ឹង ប៊ិច គាត់ប្រាប់ថា ហ្នឹងហត្ថលេខា នួន ជា។ ខ្ញុំក៏ថា នួន ជា អីចឹង ខ្ញុំក៏វាអត់មានបានចាំ ចំណាំថាហត្ថលេខាគាត់យ៉ាងម៉េច អីយ៉ាងម៉េច។ ខ្ញុំអត់ៗចាំទេ ខ្ញុំមិនអាចមានលទ្ធភាពធ្វើ ខ្ញុំអត់ -- មិនមែនជាអ្នកជំនាញការខាងហ្នឹងទេ លោក។ សូមអធ្យាស្រ័យ។

**សៈ** សូមអរគុណ។ ក្រោយពេលដែលលោកសាក្សីមកដល់ប្រទេសកម្ពុជា ឮថា ឬក៏បានឃើញឯកសារស្តីអំពីសម្តេច នរោត្តម សីហនុ ធ្វើលិខិតស្តីអំពីការលាឈប់ពីការដឹកនាំតស៊ូ ឬកម្ពុជាប្រជាធិបតេយ្យឬទេ? សូមៗទោស ខ្ញុំសូមសម្រួលសំណួររបស់ខ្ញុំឲ្យស្តាប់បាន។ ពេលដែលលោកចូលមកប្រទេសខ្មែរ លោកដែលបានឃើញឯកសារមួយនិយាយអំពីសម្តេច នរោត្តម សីហនុ សុំលាលែងចេញពីការដឹកនាំ មិនដឹងពេលហ្នឹង -- មានន័យថា នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ ហ្នឹង ប្រទេសកម្ពុជាយើងហៅថា ឈ្មោះអី? ខ្ញុំមិនច្បាស់ដែរ មិនដឹងជាហ្វ៊ុង មិនដឹង ហ្គ្រុង មិនដឹង ព្រោះគ្មានឯកសារអីបញ្ជាក់សោះ ឬកម្ពុជាប្រជាធិបតេយ្យ។ ប្រហែលជាកម្ពុជាប្រជាធិបតេយ្យ តើលោកដែលបានឃើញក្រដាសហ្នឹងទេ? ដែលឃើញក្រដាសដែលសម្តេច នរោត្តម សីហនុ សុំលាលែងឈប់ពីតំណែង?

[១៥:១៨:២៥]

**ផៈ** ខ្ញុំអត់ចាំច្បាស់រយៈពេលណាទេ។ ប៉ុន្តែខ្ញុំអត់បានអាន ព្រោះនៅជំនាន់ហ្នឹង អត់មានកាសែតមើលទេ ប៉ុន្តែខ្ញុំបានស្តាប់ ឮសូរស្តាប់វ៉ាដ្យូ ឃើញបាន -- ស្តាប់វិទ្យុ មាននិយាយពីរឿងហ្នឹង។ ប៉ុន្តែខ្ញុំមិនច្បាស់ថា ថ្ងៃណាទេបាទ។

**សៈ** អំមិញលោកបានបញ្ជាក់ថា លោកបានឮ បានវិទ្យុនិយាយអំពីព្រះអង្គលាលែងពីតំណែង។ លោកមានឆ្លល់ថា ព្រោះអីពេលនុំង សម្តេចនរោត្តម សីហនុ ជាប្រធានហ្វ៊ុង និងប្រធានហ្គ្រុង ហើយជាថ្នាក់ដឹកនាំកំពូលរបស់ប្រទេសកម្ពុជា ដែលវ៉ៃឈ្មោះ លន់ នល់ ហើយ ។គាត់ជាប្រមុខរដ្ឋ។ ហើយលោក -- គាត់ជាមេរបស់លោក លោកអត់មានឆ្ងល់ថា ហេតុអីបានជាមេរបស់យើង សមាជិកហ្វ៊ុងទាំងអស់ ឬហ្គ្រុងទាំងអស់ ឬកម្ពុជាប្រជាធិបតេយ្យទាំងអស់ហ្នឹង ឆ្ងល់ទេ? គឺជាពិសេសខ្លួនលោកផ្ទាល់នេះ ព្រោះអីឥឡូវលោកជាសាក្សី។ លោកអត់ឆ្ងល់ថា ហេតុអីបានជាសម្តេចន រោត្តម សីហនុ លោក

លាលែងទេ?

[១៥:១៩:៥៣]

**ឆ៖** ខ្ញុំបាទ សភាពការណ៍ពេលនោះ ខ្ញុំអត់ចោទបញ្ហាហ្នឹង ព្រោះខ្ញុំយល់ថា ខ្ញុំជាប់ក្នុង នៅក្នុងជំរំហើយ ព្រះករុណាលោកលាលែងជារឿងមួយ ប៉ុន្តែរឿងធំ ចំពោះពេលហ្នឹង គឺជារឿងខ្ញុំដែលខ្ញុំជាប់គុកហ្នឹង ជាប់កន្លែងហ្នឹង ហើយខ្ញុំគ្រាន់តែមានសំណួរអ៊ីចឹង។ ប៉ុន្តែសំណួររបស់ខ្ញុំអត់មាន គ្រាន់តែមានសំណួរអ៊ីចឹង ខ្ញុំឆ្ងល់ដែរ ប៉ុន្តែគ្រាន់តែខ្ញុំមិនដឹងទៅធ្វើម៉េច។ ខ្ញុំនៅជាប់គុកហ្នឹងដែរ។

**ស៖** ពេលនុ៎ង លោក -- នៅខែមីនា ពាក់កណ្តាលខែមីនា ឆ្នាំ១៩៧៦ បើតាមលោកបានប្រាប់មកអង្គសវនាការថា លោកបានចូលមកស្រុកខ្មែរ នៅខ្មែរនៅថ្ងៃទី -- ខែ១២ ឆ្នាំ១៩៧៦។ មានន័យថាចូលមកក្រោយពេលដែលលោកបានប្រកាសសុំលាលែងហើយ។ បើអ៊ីចឹងមានន័យថា លោកនៅក្រៅនៅឡើយទេនៅប្រទេសបារាំង ឬនៅណានៅឡើយទេ? ពេលហ្នឹងលោកដឹងដែរមិនអ៊ីចឹង? លោកអំមិញលោកឆ្លើយថា លោកដឹងតាមកាសែត តាមវ៉ាដ្យូ តាមអ៊ីចឹង។ ហើយអានេះ ខ្ញុំគ្រាន់តែចង់សួរថាតើលោកបានពិចារណាថា ហេតុអីបានជាលោកលាលែង? ហើយសមាជិកទាំងអស់ដែលដង្ហែរតាមព្រះអង្គទាំងពីណាមក មានឆ្ងល់ទេ? មានដែលឮនិយាយជុំគ្នាថា ឆ្ងល់យ៉ាងម៉េច? ហើយមានការព្រួយបារម្ភយ៉ាងម៉េច អីយ៉ាងម៉េចទេ?

[១៥:២១:២៩]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណ។ មិនមែនជាការជំទាស់នោះទេ ក៏ប៉ុន្តែមេធាវីបាននិយាយថា សាក្សីនេះមកប្រទេសកម្ពុជានៅខែធ្នូ ឆ្នាំ១៩៧៦ ក៏ប៉ុន្តែតាមពិតទៅ គាត់ថាគាត់មកទីនេះនៅខែកក្កដា នៅឆ្នាំ១៩៧៦ទេ។ នេះគ្រាន់តែជាការបំភ្លឺប៉ុណ្ណោះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ នៅចំពោះយើងនេះ គឺជាសាក្សីដែលត្រូវនិយាយអំពីអ្វីដែល

គាត់បានជួបប្រទះផ្ទាល់តែម្តង បានឃើញផ្ទាល់នៅក្នុងសម័យដែលពាក់ព័ន្ធនុ៎ង។ សំណួរដែលសួរដោយលោកមេធាវី សុន អរុណ គឺចង់ឱ្យសាក្សីនេះនិយាយអំពីគំនិតយោបល់ផ្ទាល់ខ្លួន ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ដែលគាត់មិនមានការពាក់ព័ន្ធផ្ទាល់ ឃើញផ្ទាល់ដោយផ្ទាល់ខ្លួន។ ដូច្នេះ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ។ សូមអរគុណ។

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយទៅព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ អ្ហឺ! លោកសាក្សីគាត់បានចូលជាសមាជិកអ្នកតស៊ូតាំងពីដើមឆ្នាំ១៩៧០ អ៊ីចឹងមានន័យថា បានធ្វើសកម្មភាពរួចទៅហើយ ហើយលោកដឹង ជាពិសេសសាក្សីហ្នឹងដឹងរឿងច្រើនណាស់ពីរឿងការតស៊ូយ៉ាងម៉េចៗហ្នឹង។ បើកាលណាថាទេ លោកអត់ដឹងទេ លោកអ្ហឺ! ឬសម្តេច នរោត្តម សីហនុ គាត់ -- លោកលាលែងនៅខែ៣-៧៦។ អាហ្នឹងមានន័យថា លោកបានចូលរួចទៅហើយ។ មានន័យថាលោកដឹង។ ត្រង់ហ្នឹងខ្ញុំចាប់ចំណុច ខ្ញុំចង់សួរថាលោកមានបានគិតទេ បើមេធំរបស់យើងហ្នឹងលោកលាលែង។

សំណួររបស់ខ្ញុំ អត់តែប៉ុណ្ណឹង។ សូមអរគុណលោកប្រធាន។

[១៥:២៣:៤០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីទាំងអស់ ហើយសូមជម្រាបដល់អស់លោក លោកស្រីទាំងនៅក្នុង និងនៅខាងក្រៅសាលសវនាការ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តាងនាមឱ្យលោក អាង ឧត្តម និងខ្លួនខ្ញុំផ្ទាល់ជាមេធាវីការពារក្តីលោក អៀង សារី ខ្ញុំសូមសួរទៅលោកសាក្សីអំពីប្រវត្តិរបស់លោកមួយចំនួន តើលោកអាចជម្រាបបានដែរឬទេ ថាតើលោកទទួលបានសញ្ញាប័ត្រអ្វីពីមហាវិទ្យាល័យ?

**លោក អុង ថុងហឿង៖**

**ឆ៖** ខ្ញុំរៀនរៀបចំដល់ ម៉េទ្រីស ប៉ុន្តែខ្ញុំអត់បានប្រលងទេ ដោយខ្ញុំឈឺបាទ។

**ស៖** យោងតាមប្រភពនានាបាននិយាយថា លោកបានបោះបង់ចោលសញ្ញាបត្របណ្ឌិត -- ការសិក្សាបណ្ឌិតរបស់ ដើម្បីត្រឡប់មកប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៦។ ដូច្នេះខ្ញុំសូមនិយាយត្រឡប់ទៅវិញ ថាតើលោកចូលកម្មវិធីសិក្សាបណ្ឌិត ឬក៏កម្មវិធីសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ ព្រោះថានៅពេលដែលលោកនៅប្រទេសបារាំង គឺឆ្នាំ៧៥ ដល់ -- អ៎! ឆ្នាំ១៩៦៥ ដល់ ៧៦ ក្នុងនាមជានិស្សិត?

**ឆ៖** បាទ ខ្ញុំបានរៀននយោបាយសេដ្ឋកិច្ច ហើយខ្ញុំអត់បានប្រលងចប់ទេ។

**ស៖** សូមអរគុណ។ ដូច្នេះ តាមចម្លើយរបស់លោក លោកមិនមានសញ្ញាបត្រខាងបរិញ្ញាបត្រខាងសេដ្ឋកិច្ចនយោបាយ ឬក៏សេដ្ឋកិច្ចសង្គម តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទត្រឹមត្រូវ។

[១៥:២៦:៤៨]

**ស៖** នៅពេលដែលលោកធ្វើ -- បានសរសេរថា លោកបានបោះបង់ចោលកម្មវិធីសិក្សាបណ្ឌិតថា តើវាជាការនិយាយត្រឹមត្រូវ -- ថាតើវាជាការពិតដែរទេដែលលោកនិយាយថា លោកបានបោះបង់ចោលការសិក្សាថ្នាក់បណ្ឌិតនោះ?

**ឆ៖** នៅកម្មវិធីសិក្សានៅប្រទេសបារាំង គេអាចមានលទ្ធភាពធ្វើដូច្នេះបានបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅចំណុចមួយទៀត លោកបានបង្ហាញនៅក្នុងចម្លើយរបស់លោកថា បន្ទាប់ពីរដ្ឋប្រហារ លោកបានក្លាយជាសមាជិកសហព័ន្ធនិស្សិត ប្រហែលជានៅក្នុងឆ្នាំ១៩៧០ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ? គឺលោកជាសមាជិកនៃសហភាពនិស្សិតខ្មែរ? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ។

**ស៖** ហើយលោកបាននៅក្នុងប្រទេសបារាំងតាំងពីឆ្នាំ៦៥។ ខ្ញុំចង់សួរលោកថា ចន្លោះ៦៥ ដល់ ៧០ តើលោកមានចូលរួមសកម្មនយោបាយនៅទីណា ឬក៏នៅកន្លែងណាអីដែរឬទេ?

**ឆ៖** ខ្ញុំបានចូលរួមដូចជានិស្សិតផ្សេងទៀត បានចូលរួមធ្វើនយោបាយជាមួយនិស្សិតបារាំងបាទ។

**ស៖** អ៊ីចឹងបានន័យថា លោកគ្រាន់តែនិយាយ ឬក៏ពិភាក្សាអំពីនយោបាយជាមួយនិស្សិតផ្សេងៗ ឬមួយក៏លោកចូលរួមក្នុងក្លឹបនយោបាយ ឬក៏ស្ថាប័ន ឬក៏អង្គភាពនយោបាយណាមួយដែលទាក់ទងទៅនឹងសកម្មភាពនយោបាយអីដែរឬទេ?

**ឆ៖** ខ្ញុំគ្រាន់មានសមានចិត្តជាមួយចលនាឆ្វេងនៅប្រទេសបារាំង ហើយខ្ញុំបាន -- អង្គាល់ព្រឹត្តិ

ការណ៍ខែ៣ ឆ្នាំមួយពាន់-- នៅប្រទេសបារាំងខ្ញុំ គឺខ្ញុំកាន់និស្សិតមានចលនា គឺខ្ញុំបានចូលរួមជាមួយគេជាមួយឯងជាមិត្តភក្តិផ្សេងទៀតបាទ។

[១៥:២៩:៣១]

**ស៖** អរគុណ។ លោកបានបង្ហាញថា លោកស្គាល់ ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់។ តើលោកដឹងអំពីការសិក្សារបស់ពួកគាត់ដែរឬទេ គឺការសិក្សារបស់ពួកគាត់នៅមហាវិទ្យាល័យនោះ?

**ឆ៖** ខ្ញុំបានមើលនិក្ខេបបទរបស់ ខៀវ សំផន ខ្ញុំបានមើលនិក្ខេបបទរបស់ ហ៊ូ នឹម ខ្ញុំបានមើលនិក្ខេបបទរបស់លោក ហ៊ូ យន់។

**ស៖** អរគុណលោកបានឆ្លើយនូវសំណួរបន្ទាប់របស់ខ្ញុំរួចទៅហើយ ដូច្នេះសូមអរគុណលោក។ ថាតើលោកក្នុងនាមជាសមាជិកសហភាពនិស្សិត ថាតើលោកចូលរួមយ៉ាងសកម្ម ថាតើភាពសកម្មហ្នឹងសកម្មដល់កម្រិតណាដែរ?

**ឆ៖** សកម្មក្នុងន័យថា ខ្ញុំបាននៅបុរីអន្តរជាតិ ខ្ញុំបានធ្វើៗមីទ្ទិងជាមួយនិស្សិតបរទេស ដើម្បីនិយាយពីកម្ពុជា ឬក៏បានទៅទាក់ទងនិស្សិត ចលនានិស្សិតផ្សេងៗ និស្សិតបរទេសបាទ។

[១៥:៣០:៥២]

**ស៖** ខ្ញុំសូមសួរថា តើមាននិស្សិតកម្ពុជាប្រហែលប៉ុន្មានរូប ដែលជាសមាជិកនៃសហភាពនិស្សិតខ្មែរក្នុងពេលដែលលោកជាសមាជិកដែរនោះ តើមាននិស្សិតខ្មែរប្រហែលប៉ុន្មានរូបដែរ?

**ឆ៖** ខ្ញុំចាំច្បាស់ទេ ប្រហែលជាយ៉ាងតិច៥០។

**ស៖** សូមលោកជម្រាបប្រាប់យើងបានដែរឬទេ ថាតើសហភាពនិស្សិតខ្មែរនោះ មានប្រធាន ឬក៏អនុប្រធាន ឬក៏ហិរញ្ញិក ឬក៏អគ្គលេខាធិការអ្វីដែរឬទេ? ថាតើសហភាពនោះមានគណៈកម្មការបែបនេះដែរឬទេ?

**ឆ៖** បាទ មាន។

**ស៖** ថាតើមានធម្មនុញ្ញ ឬក៏មានបទបញ្ជា ឬក៏មានអ្វីមួយរបស់សហភាពនិស្សិតនោះដែរឬទេ?

**ឆ៖** បាទ មានធម្មនុញ្ញផ្ទៃក្នុង មានធម្មនុញ្ញជាសមាគមបាទ។ ជាសមាគមសហភាពនិស្សិតខ្មែរ មានធម្មនុញ្ញ មានគេហៅ *ស្តាទុយ អាំងទែរីយ័រ* មានធម្មនុញ្ញផ្ទៃក្នុង និងផ្ទៃក្រៅ។

**ស៖** តើប្រធានសហភាពនៅពេលដែលលោក ក្នុងនាមជាសមាជិកដែរនុ៎ង គឺជា -- ថាតើមានប្រធានលើប្រធាន នៃសហភាពនិស្សិតខ្មែរនុ៎ងដែរឬទេ? ថាតើមានប្រធានច្រើនរូបដែរឬទេ?

[១៥:៣៣:១៥]

**ឆ៖** ពេលខ្ញុំចូលនោះ គឺប្រធានមានលោក សួង ស៊ីគឿន ជាប្រធានបាទ។

**ស៖** សូមអរគុណ។ តើ -- ថាតើមានប្រតិបត្តិការ ឬក៏មានការដឹកនាំពីឆ្វេងទៅស្តាំ ឬក៏នៅកណ្តាលយ៉ាងម៉េចដែរចលនានោះ?

**ឆ៖** ចលនានោះវាមានពីរបាទ។ ចលនាធំ គឺចលនាពួកចាស់ៗ ច្រើនមាននិន្នាការជាប់ទាក់ទងនៅជាមួយនៅបរទេស -- ទាក់ទងជាមួយគណបក្សកុម្មុយនីស្តបារាំង ហើយដែលបន្ទាប់មកទៀតបន្ទាប់ពីរដ្ឋប្រហារ មានពួកក្មេងៗទៅចំនួនទៀត ទៅពីប្រទេសកម្ពុជា ពួកហ្នឹងមាននិន្នាការខាងប្រទេសចិន។

**ស៖** តើលោករស់នៅកន្លែងណា នៅក្នុងភាគីក្រុមហ្នឹងដែលលោកធ្វើការ ឬក៏ដែលលោកមាននិន្នាការទៅរកហ្នឹង គឺផ្នែកណាមួយ? ក្រុមណាមួយ? ក្នុងទាំងពីរហ្នឹង។

**ឆ៖** ខ្ញុំនៅកណ្តាលបាទ។

[១៥:៣៤:៥៦]

**ស៖** បាទ ឥឡូវនេះនៅក្នុងចម្លើយរបស់លោក ខ្ញុំយោងទៅរក E3/97។ នៅក្នុងចម្លើយរបស់លោកនោះនៅក្នុងអត្ថបទខ្មែរ ERN 00270684 រហូតដល់ 86, បារាំង ERN 00241883 រហូតដល់ 84, អង់គ្លេស 00287100។ គេបានសួរលោកនូវសំណួរមួយ៖ "ហេតុអ្វីបានសហភាពនិស្សិតខ្មែរ បានរំលាយនៅឆ្នាំ១៩៧១?" ហើយនៅកន្លែងនេះ លោកបាននិយាយថា៖ "អៀង សារី បានសម្រេចដើម្បីរំលាយចលនានេះចោល"។ ឥឡូវនេះ ខ្ញុំនឹងផ្តោតទៅលើចំណុចនេះបន្តិច ហើយបន្ទាប់ទៀត ខ្ញុំនឹងពិនិត្យមើលចម្លើយរបស់លោកខាងដើម។ តាមលក្ខន្តិកៈ របស់សហភាពនិស្សិតនោះ តើលោកអាចនិយាយបានទេ ម្នាក់ បុគ្គលម្នាក់ ដែលមិនមែនជាសមាជិកហ្នឹងអាចៗប្រកាសរំលាយសហភាពហ្នឹង បានដូចម្តេចកើតនៅក្នុងពេលដែលលោកជាសមាជិកនៅពេលនោះ។ តើលោកអាចជម្រាបបានទេ?

[១៥:៣៦:៣៤]

**ឆ៖** នៅពេលនោះមានចលនា នៅស្រុកបារាំងមាននិស្សិត មានសមាគមផ្សេងៗ ដែលគាំទ្រសេចក្តីថ្លែងការណ៍ ៥ខ របស់សម្តេច សីហនុ ហើយមាននិស្សិតខ្លះ គាំទ្រលោក ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម គឺនិស្សិត សមាគមឈ្មោះនិស្សិតផ្សេងៗគ្នា។ ហើយនិស្សិតទាំងអស់នោះ គាំទ្ររណសិរ្សរួបរួមជាតិកម្ពុជា ហើយលោក អៀង សារី គាត់បានណែនាំឲ្យគណបក្សទាំងអស់នោះរំលាយខ្លួនចូល

រណសិរ្សតែមួយ ហើយទាំងអស់គ្នាបានសុខចិត្តបាទ។

**ស៖** បាទ តាមអ្វីដែលខ្ញុំយល់ចម្លើយរបស់លោកនោះ គាត់មិនបានរំលាយសហភាពនិស្សិតនេះទេ ប៉ុន្តែគាត់បានឲ្យយោបល់ ថាតើនិស្សិតគួរដឹកនាំសហភាពហ្នឹង ដែលថាមានភាគីផ្សេងៗគប្បីតែធ្វើឬដូចម្ដេច? តើនេះជាការយល់ត្រឹមត្រូវទៅនឹងចម្លើយរបស់លោកដែរឬទេ?

**ឆ៖** គេធ្វើការណែនាំ ដើម្បី -- លោក អៀង សារី គាត់ធ្វើការណែនាំប្រធានសមាគមនីមួយៗ ហើយប្រធានសមាគមនោះក៏រាយការណ៍ ហើយទាំងអស់គ្នាក៏បានសុខចិត្តអ៊ីចឹង អាហ្នឹងការដាក់ស្ដែងវាអ៊ីចឹងបាទ។

**ស៖** ម៉្យាងទៀត គាត់បាន -- មិនបានធ្វើសេចក្ដីសម្រេចអ្វីទេ គាត់គ្រាន់តែឲ្យយោបល់ ហើយដែលយោបល់នោះគេទទួលយក។ តើអ៊ីចឹងឬទេ?

[១៥:៣៨:២៥]

**ឆ៖** អានេះមិនមែនជាយោបល់ទេ គឺថាជាតាមខ្ញុំថា ជាការបញ្ជា ព្រោះម្នាក់ៗត្រូវតែអនុវត្តតាមមាគ៌ារបស់លោក អៀង សារី។

**ស៖** បាទ ខ្ញុំចង់យល់ឲ្យច្បាស់ អំពីសក្ខីកម្មរបស់លោក។ នៅកន្លែងនេះ គាត់ -- លោកនិយាយថា គាត់ធ្វើសេចក្ដីសម្រេច ក្រោយមកលោកនិយាយថា គាត់ឲ្យយោបល់ ពីព្រោះថា មានក្រុមផ្សេងៗគ្នា ប៉ុន្តែឥឡូវនេះ យើងប្ដូររឿងរ៉ាវរបស់លោក គឺថា លោកនិយាយថា គាត់ឲ្យបញ្ជាវិញ។ តើលោកឃើញភាពខុសគ្នាបីទេ ទាក់ទងទៅនឹងសំណួរដែលគេសួរលោកនោះ? តើឃើញទេថាលោកបានឆ្លើយចម្លើយបីខុសគ្នាដែរ ឬទេលោកសាក្សី?

**ឆ៖** ខ្ញុំឆ្លើយសំណួរនេះ គឺក្នុងក្របខ័ណ្ឌថា ទាំងអស់គ្នាទុកសម្ដីរបស់លោក អៀង សារី ជាសម្ដីទិព្វ។ ដូច្នេះជាពាក្យថា "ស្នើ" ពាក្យថា យ៉ាងម៉េច គឺវាមានន័យថា តែគាត់ហាមាត់ថាម៉េចទាំងអស់គ្នាសុខចិត្តធ្វើតាមគាត់ហើយបាទ។

[១៥:៣៩:៤៩]

**ស៖** បាទ អ៊ីចឹងអនុញ្ញាតទៅខាងមុខបន្តិច។ លោកបានចង្អុលបង្ហាញថា នៅពេលមួយនោះលោកទទួលបានព័ត៌មានមកពីរណសិរ្សរួបរួមកម្ពុជា ដែលនៅកាលនោះ គឺព័ត៌មានហ្នឹងគឺបែបហ្នឹង តើអ៊ីចឹងដែរឬទេ?

**ឆ៖** ព័ត៌មានបែបម៉េច ខ្ញុំអត់យល់។

**ស៖** សូមអរគុណ ដែលលោកបានបញ្ជាក់ ដែលថាសំណួរខ្ញុំមិនពេញ។ ទាក់ទងនឹងអ្វីដែលកើតឡើងនៅកម្ពុជា តាមអ្វីដែលខ្ញុំយល់សក្ខីកម្មរបស់លោកកាលពីម្សិលមិញនោះ ព្រឹត្តិបត្រនោះ ត្រូវបានចែកដោយហ្មុង។ ខ្ញុំយល់ថាលោកបានថា គេមានបោះពុម្ពផ្សាយអត្ថបទអ្វីមួយនៅក្នុងប្រទេសបារាំង?

**ផ៖** គេហៅថាៗ ព្រឹត្តិបត្ររណសិរ្សរួបរួមជាតិកម្ពុជាបាទ។

[១៥:៤១:០៦]

**ស៖** អ្នកណាជាអ្នកចែកផ្សាយនូវព្រឹត្តិបត្រនេះ តើមានចំណងជើងដូចម្ដេច? ពីព្រោះថាលោកនិយាយថានៅប្រទេសបារាំងគេបានបោះពុម្ពផ្សាយអត្ថបទមួយ ហើយបានបែងចែក។ អ្នកណាជាអ្នកបោះពុម្ព? តើមានចំណងជើងអ្វី? តើអ្នកណាជាអ្នកសរសេរខ្លឹមសារនៅក្នុងនោះបាទ?

**ផ៖** ខ្លឹមសារជាទូទៅគឺយកមកពីវិទ្យុបាទ។ វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា ហើយអ្នកផ្សាយគឺជានិស្សិត ឬក៏ផ្ញើតាមប៉ុស្តិ៍ ផ្ញើតាម -- ។

**ស៖** បាទ តាមអ្វីដែលខ្ញុំយល់គឺថាមានអ្នកស្ដាប់វិទ្យុ ហើយធ្វើប្រតិចារឹកតាមអ្វីដែលគេបានឮ ហើយបានចែកទៅឲ្យអ្នកដែលមិនបានស្ដាប់វិទ្យុ ដែលអ្នកទាំងអស់ -- ដែលថាព័ត៌មានហ្នឹងចេញមកពីរណសិរ្សរួបរួមជាតិកម្ពុជា តើអ៊ីចឹងដែរឬទេនៅប៉ារីសនោះ?

**ផ៖** បាទ ពីព្រោះថានៅប៉ារីសស្ដាប់វិទ្យុរណសិរ្សហ្នឹងអត់បានទេ ទាល់ផ្ញើអត្ថបទហ្នឹងពីៗហាណូយ ឬពីណាទៅ ហើយនៅប៉ារីសទទួល ហើយចម្លងតាមហ្នឹង។ ជារួម បាទ។

**ស៖** នេះជា-- ខ្ញុំនឹងសួរបន្ទាប់។ តើលោកដឹងច្បាស់ថាប្រភពជាក់លាក់មកពីណា? តើអ្នកណាជាអ្នកសរសេរខ្លឹមសារដែលត្រូវយកទៅចែកផ្សាយនោះ លោកបានបញ្ជាក់ហើយថានៅពេលមួយនេះលោកមានៗ គឺអតីតប្រមុខរដ្ឋជាព្រះមហាក្សត្រ គឺសម្ដេច នរោត្តម សីហនុ ដែលជាប្រធាននៃរណសិរ្សរួបរួមជាតិបាទ។ តើត្រឹមត្រូវអ៊ីចឹងដែរឬទេដែលលោកនិយាយនោះ?

[១៥:៤៣:១៦]

**ផ៖** ខ្ញុំអត់យល់សំណួរ។

**ស៖** តើការផ្សាយៗចេញពីណា? តើអ្នកណាជាអ្នករៀបចំនូវខ្លឹមសារការផ្សាយនោះ? ពីព្រោះលោកនិយាយថាសម្ដេចនរោត្តម សីហនុ ជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា តើអ៊ីចឹងត្រូវឬខុសបាទ?

**ផ៖** បាទ និយាយឲ្យចំសម្ដេច នរោត្តម សីហនុ ជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ហើយសម្ដេច សីហនុ តាមធម្មតាគាត់មាន*មូលតាំង*របស់គាត់មួយ។ អាហ្នឹងសម្ដេច សីហនុ គាត់ចូលចិត្ត

មាន*មូលតាំង*របស់គាត់មួយ មានព្រឹត្តិបត្ររបស់គាត់មួយ។ ហើយព្រឹត្តិបត្រមួយទៀតចេញមកពីការិយាល័យរណសិរ្សរួបរួមជាតិកម្ពុជា ដែលចេញផ្សាយតាមវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា។

[១៥:៤៤:៣២]

**ស៖** ព័ត៌មានដែលលោកទទួលបានមកពីសម្តេច សីហនុ នោះ ចេញមកពីព្រឹត្តិបត្ររបស់ព្រះអង្គនោះ តើដូចគ្នា ឬក៏ជាមូលដ្ឋានដូចគ្នា ជាព័ត៌មានដូចគ្នានៅក្នុងព្រឹត្តបត្រមួយផ្សេងទៀត ឬមួយក៏វាខុសគ្នាដាច់ស្រឡះទេ?

**ឆ៖** ជារួមព្រឹត្តិបត្រដែលចេញមកពីសម្តេច នរោត្តម សីហនុ គឺនិយាយពីសកម្មភាពរបស់ទ្រង់សកម្មភាពផ្ទាល់របស់ព្រះអង្គ។

**ស៖** បាទ ដូច្នេះតាមអ្វីដែលខ្ញុំយល់ សក្ខីកម្មថ្ងៃនេះ ហើយនិងមើលសៀវភៅរបស់លោកផងដែរ លោកបានផ្តល់តម្លៃទៅដល់លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ ដើម្បីលើកចិត្តរបស់ -- ឲ្យលោកសរសេរសៀវភៅរបស់លោក។ តើត្រូវអ៊ីចឹងឬទេ? តើខ្ញុំយល់អ៊ីចឹងត្រូវទេ?

**ឆ៖** អត់ត្រូវទេបាទ។ ពីព្រោះខ្ញុំសរសេរចប់ បានខ្ញុំៗ ដែលខ្ញុំឲ្យ -- ខ្ញុំស្គាល់ ឆេនដ៍ល័រ ហើយខ្ញុំឲ្យគាត់មើល។ ខ្ញុំសរសេរចប់ បានឲ្យ -- ខ្ញុំឲ្យអ្នកដទៃមើល។

**ស៖** បាទ ខ្ញុំមាន នៅទំព័រ១៥ នៃសៀវភៅរបស់លោកដែលនិយាយចំណុចនេះ "គឺសៀវភៅនេះមិនអាចមានទេ បើសិនជា ហាង់រី ឡូកា មិនបានរកឃើញនូវកន្លែងរបស់ ស្ទីវ ហេដឌ័រ ហើយ ហេដឌ័រ និង ដេវីដ ឆេនដ៍ល័រ បានណែនាំខ្ញុំឲ្យបោះពុម្ពផ្សាយសៀវភៅនេះ" ដែលនៅទំព័រ១៥ ដែលបកប្រែទៅជាអង់គ្លេស ខ្ញុំឃើញ។ តើអ៊ីចឹងត្រូវឬទេ ខ្លឹមសារនេះ?

[១៥:៤៦:៤៣]

**ឆ៖** បាទ ត្រូវ។ ប៉ុន្តែខ្ញុំមិនមែន ឆេនដ៍ល័រ ឬក៏ ស្ទីវ ហេដឌ័រ ឲ្យខ្ញុំសរសេរទេ។ ខ្ញុំសរសេរចប់ហើយ បានពួកនោះ យកទៅមើល ហើយគេប្រាប់ខ្ញុំថា គួរតែបោះ។

**ស៖** បាទ គឺថា -- បាទ គឺត្រូវហើយ ដែលថានិយាយថា គាត់ណែនាំឲ្យបោះពុម្ពផ្សាយមិនមែនឲ្យសរសេរទេ។ អ៊ីចឹង យើងអាចទាញយកសេចក្តីសន្និដ្ឋាន ថាលោកអាចមានការពាក់ព័ន្ធជាមួយ ដេវីដ ឆេនដ៍ល័រ លោកអាចនិយាយជាមួយគាត់ មុនពេលដែលគាត់ប្រទះឃើញសេចក្តីព្រាងនៃៗសៀវភៅរបស់លោកដែលសរសេរដំបូងនោះ។ តើលោកបានជួបពួកគាត់ ជួប ដេវីដ ឆេនដ៍ល័រ មុនទេ? លោកបាននិយាយនៅពេលណាទេ ជួបគាត់មុនពេលហ្នឹងទេបាទ?

**ឆ៖** ជាទូទៅ អ្នកនិពន្ធ បើយើងសរសេរអីហើយ យើងចែកគ្នាមើល។ គាត់ ជួនកាល គាត់សរសេរអី គាត់ផ្ញើឲ្យខ្ញុំមើល។ ខ្ញុំ អ្នកផ្សេងទៀត ក៏ដូចគ្នា។ អាហ្នឹង គឺចែកគ្នាមើលទៅវិញទៅមក ហើយបើគេថា គួរផ្សាយ ក៏ផ្សាយទៅបាទ អាហ្នឹង វាក្នុងន័យអ៊ីចឹងទេបាទ។

[១៥:៤៨:១៣]

**ស៖** តើលោកដឹងដែរឬទេ លោកបានដាក់បញ្ចូល -- លោកបានមើលខ្លឹមសារសៀវភៅរបស់ ដេវីដ ឆេនដ័ល័រ និយាយអំពីសោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជា ដែលមានរក្សាសិទ្ធិនៅឆ្នាំ១៩៩១ ជាមួយការបោះពុម្ពផ្សាយឆ្នាំ១៩៩៣ របស់ សៅអ៊ីស្ត-អេហ្សា។ តើលោកដឹងពីអ្វីដែលបញ្ជាក់នៅក្នុងសៀវភៅរបស់គាត់ទេ? សៀវភៅដែលខ្ញុំបានលើកឈ្មោះខាងដើមអំមិញនេះ?

**ឆ៖** ខ្ញុំមិនចាំទេ បាទ។

**ស៖** តើគាត់ -- តើលោកបានអានសៀវភៅណាមួយរបស់គាត់ទេ នៅពេលដែលលោកនៅពេលនោះ? ខ្ញុំយល់ថា នៅពេលដែលសរសេរសៀវភៅរបស់លោក លោកបានធ្វើការសិក្សាស្រាវជ្រាវមួយចំនួន។ តើអ៊ីចឹងដែរឬទេ?

[១៥:៤៩:១៤]

**ឆ៖** ខ្ញុំបានធ្វើការស្រាវជ្រាវមួយចំនួន ប៉ុន្តែមុននឹងខ្ញុំអត់បានមើល។ ពេលមើលសៀវភៅ ឆេនដ័ល័រ ទៅ ខ្ញុំអត់បានស្គាល់គាត់ ហើយដោយសារខ្ញុំមិនជាអ្នកមើល។ ដូច្នេះខ្ញុំមិន -- សៀវភៅដែលខ្ញុំសរសេរ អត់មានឈរលើឯកសាររបស់គាត់ទេបាទ។

**ស៖** បាទ ឥឡូវនេះ យើងមើលទៅឯកសារ D108/50/1.75។ ខ្ញុំដឹងថាមិនបានបកប្រែទៅជាភាសាបារាំង ឬខ្មែរទេ មាន ERN 00193374។ នៅកន្លែងនេះគាត់បាននិយាយថា "គឺថាហ្វ្រុង គឺថាមានការពាក់ព័ន្ធ -- ហឿង មានការពាក់ព័ន្ធទៅ យូ.អ៊ី.ខេ នៅក្នុងសហភាពជាតិនិស្សិតខ្មែរ យូ.អិន.អ៊ី.ខេ ជាអង្គការម៉ៅ ដែលទាក់ទងទៅនឹង កុល ទូច កូនប្រុសរបស់ កុល ទូច ស្ថិតនៅក្នុងនោះដែរ"។ តើនេះជាសេចក្តីសន្និដ្ឋានត្រឹមត្រូវរបស់លោក ឆេនដ័ល័រ ដែលនិយាយពីលោកដែរឬទេ?

**ឆ៖** បាទ នេះជាការត្រឹមត្រូវ។ ខ្ញុំតែងតែមានឲ្យនិស្សិតខ្មែរ និន្នាការនយោបាយណាក៏ដោយរួបរួមគ្នា។ ដូច្នេះ ខ្ញុំជាមួយលោក កុល ទូច កូនលោក កុល ដូរាធី ជាមិត្តរបស់ខ្ញុំ។ ដូច្នេះ គឺគាត់មាននិន្នាការខាងចិន គឺខ្ញុំមានកង មានមិត្តភក្តិ មិត្តភាពជាមួយគាត់ ក៏ដូចអ្នកដទៃទៀតដែរបាទ។ នេះមិនមែនបានន័យថា ខ្ញុំនិន្នាការចិន ឬក៏និន្នាការសូវៀត ឬនិន្នាការណាមួយទេបាទ។

[១៥:៥១:២៥]

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់តើអ្វីដែលគាត់និយាយនោះ ត្រឹមត្រូវដែរឬទេ? គាត់និយាយបន្តទៀត "គឺថាសមាជិក៣០នាក់នៃសហភាពនិស្សិតខ្មែររាប់បញ្ចូលទាំងកូនប្រុសរបស់ ទូច នោះគឺបានអនុញ្ញាតឲ្យចូលមកកម្ពុជាឆ្នាំ១៩៧៣ បន្ទាប់ពីមានការពិនិត្យនៅប៉េកាំងរួចហើយ គឺថា និស្សិតដូចជាលោក ហឿង ដែលមានការពាក់ព័ន្ធទៅនឹងសហភាពសូវៀត ត្រូវបានគេប្រាប់ឲ្យរង់ចាំ ហើយមិនឲ្យត្រឡប់មកប្រទេសទេ រហូតទាល់តែខែមេសា ឆ្នាំ១៩៧៥"។ ឥឡូវនេះ តើសេចក្តីថ្លែងករណ៍នេះត្រឹមត្រូវដែរឬទេ តាមអ្វីដែលលោកយល់នោះ?

**ឆ៖** ខ្ញុំមិនអាច ខ្ញុំមិនថា នេះជាការ ជាយោបល់របស់អ្នកនិពន្ធ។ ខ្ញុំមិនមែន ខ្ញុំសរសេរទេ បាទ ព្រោះខ្ញុំ ខ្លួនខ្ញុំផ្ទាល់ ខ្ញុំអត់មានដាក់ពាក្យសុំចូលមកក្នុងស្រុក។ ដូច្នេះបញ្ហាហ្នឹង វាអត់មានចោទទេ។

**ស៖** បាទ ដើម្បីឲ្យប្រាកដ លោកមិនបានស្នើ -- គេមិនបានស្នើសុំឲ្យលោកមកកម្ពុជាទេនៅឆ្នាំ១៩៧៣ ឬ៧៤ ដែលលោកត្រូវទៅប៉េកាំង ដើម្បីឲ្យគេពិនិត្យសិន គឺថាគេ លោកមិនបានស្នើសុំថាមកទេ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំៗមិនដែលដាក់ពាក្យសុំចូលក្នុងឆ្នាំ៧៣ ឬ៧៤ ទេបាទ។

**ស៖** បាទ សូមអរគុណ។ គាត់និយាយបន្តទៅទៀតថា "នៅឆ្នាំ១៩៧៤ ហឿង ហើយនិងអ្នកផ្សេងទៀតនៅក្នុងចលនាបានទៅប៉ុយការ៉េស ដើម្បីទៅជួប អៀង សារី ដែលបានធ្វើដំណើរជាមួយសម្តេច សីហនុ"។ ឥឡូវនេះ ខ្ញុំបានស្តាប់សក្ខីកម្មរបស់លោកពីម្សិលមិញ ហើយនិងថ្ងៃម្សិលមិញ។ លោកបាន -- លោកមិនដែលបាននិយាយថាទៅប៉ុយការ៉េស នៅឆ្នាំ១៩៧៤។ តើលោកអាចប្រាប់តុលាការបានទេ ថាតើលោក ឆេនដ៍ល័រ កត់ត្រាហ្នឹងត្រឹមត្រូវដែរឬទេ? សំណួរគឺថា តើលោកពិតជាបានទៅ ប៉ុយការ៉េស នៅឆ្នាំ១៩៧៤ដែរឬទេ?

[១៥:៥៤:០៧]

**ឆ៖** បាទ ខ្ញុំបានទៅ ប៉ុយការ៉េស ក្នុងឆ្នាំ១៩៧៤មែន។

**ស៖** ឥឡូវនេះលោកបានប្រាប់ថា សហភាពនិស្សិតខ្មែរហ្នឹងត្រូវបានរំលាយ។ តើលោកយល់ដូចម្តេចចំពោះលោកបានទៅ ជាផ្នែកនៃក្រុម ឬជាផ្នែកនៃសមាគមអ្វីមួយ? ប្រសិនបើដូច្នេះមែន ថាតើក្រុមណា ឬក៏សមាគមណា?

**ឆ៖** ខ្ញុំទៅក្នុងឋានៈខ្ញុំ ក៏ដូចអ្នកផ្សេងទៀតដែរក្នុងឋានៈខ្ញុំជាសមាជិក -- ជានិស្សិតសមាជិក

រណសិរ្សរួបរួមជាតិកម្ពុជា។ ហើយពេលឆ្នាំ៧៤ហ្នឹង គឺថាលោក អៀង សារី បានធ្វើដំណើរទស្សនកិច្ចជាមួយសម្តេច សីហនុ នៅប្រទេសរ៉ូម៉ានី និងប្រទេសអាល់បានី ហើយនិងប្រទេសយូហ្គោស្លាវី។

**ស៖** ថាតើគោលបំណងដែលលោកធ្វើដំណើរពីប៉ារីស ឬក៏ពីកន្លែងណាមួយនៅបារាំងទៅប៉ុយការ៉េសហ្នឹង នៅក្នុងឆ្នាំ១៩៧៤ ហេតុអ្វីក៏លោកបានទៅទីនោះ?

**ឆ៖** ជាផ្លូវការ យើងរណសិរ្ស និស្សិតរណសិរ្សរួបរួមជាតិកម្ពុជាបានចាត់តាំងនិស្សិតមួយចំនួនឲ្យទៅជួបធ្វើ -- ជួបសម្តេច នរោត្តម សីហនុ ជាប្រធានរណសិរ្ស ហើយដល់ទៅជួបសម្តេច សីហនុ ហើយក៏ក្រោយមកបានជួបលោក អៀង សារី ទៀត។

[១៥:៥៦:១៥៤]

**ស៖** បាទ នៅពេលដែលលោកបានជួបសម្តេច សីហនុ ហើយនិង អៀង សារី តើលោកបានសួរសំណួរអ្វីខ្លះទេ ឬក៏គ្រាន់តែពិធីជួបជុំជាធម្មតា?

**ឆ៖** ខ្ញុំអត់ចាំថា ខ្ញុំបានសួរសំណួរអីទេបាទ។

**ស៖** បាទ ខ្ញុំមិនគប្បីនិយាយថា លោកទេ បើសិនជាក្រុមទាំងមូលទៅ ប្រហែលថាទទួលបាននូវព័ត៌មានមួយចំនួនអំពីសម្តេច សីហនុ ឬលោក អៀង សារី ហើយប្រហែលថា អាចនឹងសួរសំណួរហើយមានចម្លើយរវាងបុគ្គលនៅក្នុងក្រុមដែលតំណាងឲ្យរណសិរ្សរួបរួមជាតិកម្ពុជានោះ?

**ឆ៖** ខ្ញុំមិនចាំថា មាននិស្សិតណាសួរព្រះករុណា ឬសួរលោក អៀង សារី ទេ ព្រោះយើងជានិស្សិត ទម្លាប់ខ្មែរ គឺយើងទៅដល់ស្តាប់ព្រះករុណាលោកសំណេះសំណាលទៅ ហើយយើងសើចជាមួយគាត់ទៅ អាហ្នឹងវាច្រើនតែអ៊ីចឹង។ អាហ្នឹងជាទំនៀមទម្លាប់ខ្មែរ អត់មានដេញដោលគាត់ ដូចលោកកំពុងដេញដោលខ្ញុំអ៊ីចឹងទេបាទ។

**ស៖** អ៊ីចឹង តើលោកអាចប្រាប់តុលាការបានទេ ថាតើជាហេតុការណ៍ដែលអាចចងចាំបានទេ នៅពេលដែលលោកជួបសម្តេចនៅប៉ុយការ៉េស ថាតើខ្លឹមសារសំខាន់ដែលលោកបានឮពីព្រះអង្គទាក់ទងទៅនឹងខ្លឹមសារសំខាន់ដែលថា ព្រះអង្គត្រូវតែប្រាប់ទៅតំណាងសហភាពនិស្សិត ដែលមកពីរណសិរ្សរួបរួមជាតិហ្នឹងមកជួបព្រះអង្គ តើអ្វីដែលលោកបានឮនោះកាលនោះ?

**ឆ៖** ខ្ញុំអត់បានចាំថា លោកនិយាយថាម៉េច គ្រាន់បានសំណេះសំណាលគ្នាជាមួយលោកអ៊ីចឹងទៅអត់ៗ លោកបានរាយការណ៍ពីលោកបានជួប ចាឆេស្កូ លោកបានជួបអ្នកនេះ អ្នកនោះអ៊ីចឹងទៅ ហើយចប់ទៅ។ ខ្ញុំអត់បានចាប់អារម្មណ៍ថា មានអីទៀតទេបាទ។

[១៥:៥៨:៥១]

**ស៖** ខ្ញុំចង់និយាយឲ្យច្បាស់ ព្រះអង្គនៅទីនោះក្នុងនាមរណសិរ្សរួបរួមជាតិកម្ពុជា ដើម្បីផ្តល់ព័ត៌មាន។ ឥឡូវលោកប្រាប់ខ្ញុំថា អំពីការប្រជុំនោះដែលលោកបានជួបនោះ លោកមិនចាំថាព្រះអង្គបានមានព្រះឱង្ការអ្វី? អ្វីកើតមានឡើងនៅកម្ពុជា តើការតស៊ូហ្នឹងប្រឆាំងអ្នកណា? តើប្រឆាំង លន់ នល់ នុំងយ៉ាងម៉េចហើយ ផែនការអនាគតនោះយ៉ាងម៉េច? ហើយលោកស្តាប់ឮថាមិនមានការនិយាយអ្វីទាំងអស់ បានសន្និដ្ឋានថាមិនឮអ្វីទាំងអស់។ តើអ្នកនេះសក្ខីកម្មរបស់លោកថ្ងៃនេះឬ?

**ឆ៖** ខ្ញុំមិនមែនថាៗ ព្រះករុណាអត់បាននិយាយ មានបន្ទូលអីក្នុងហ្នឹង ប៉ុន្តែខ្ញុំមិនបានចាប់អារម្មណ៍អ្វីក្រៅពីព្រះអង្គនិយាយ -- អំ! មានបន្ទូលថា ព្រះអង្គបានជួបប្រធានាធិបតីនេះ ធិបតីនោះហើយ អានេះគឺក្នុងការសភាពការណ៍ក្នុងប្រទេសរឿងអី ខ្ញុំមិនមែនបានន័យថា ព្រះអង្គមិនមានបន្ទូលទេ ប៉ុន្តែ ខ្ញុំបាទអត់ចាំបាទ។

**ស៖** ខ្ញុំមានសំណួរចុងបញ្ចប់មួយ នៅពេលដែលយើងចប់ពេលថ្ងៃនេះ។ នេះចេញអំពីទំព័រដដែលនៃសៀវភៅ ឆេនដ៍ល័រ គាត់បន្តនិយាយថា៖ "នៅចុងឆ្នាំ១៩៧៥ ប្រហែលមានខ្មែរនៅបរទេស ៣០ ដែលបានគេនាំមកពីអឺរ៉ុបមកកម្ពុជា ជាពិសេសមកពីប្លុកសូវៀត ហើយតាមរយៈទីក្រុងប៉េកាំង។ ប៉ុន្តែមិនរហូតដល់ខែមេសា ឆ្នាំ១៩៧៦ ដែល ហៀង ហើយនិងប្រពន្ធរបស់គាត់បានទទួលការអនុញ្ញាតឲ្យធ្វើដំណើរនៅក្នុងក្រុមទី៤ នៃអ្នកត្រឡប់មកវិញ ដែលម្នាក់ៗមានចំនួនប្រហែលជា៤០នាក់ ទាំងបុរស ទាំងស្ត្រី"។

ឥឡូវនេះលោកបានប្រាប់ខ្ញុំថា នៅពេលដែលលោកត្រឡប់មកវិញ ប៉ុន្តែសំណួររបស់ខ្ញុំ ថាតើលោករង់ចាំឲ្យមានការអនុញ្ញាតដើម្បីចូលមកដែរឬទេ? មកពី បាទ និយាយថា ចាប់ពីពេលដែលភ្នំពេញបានដួលរលំនៅឆ្នាំ១៩៧៥ តើលោកបានដាក់សំណើដើម្បីសុំមកប្រទេសកម្ពុជា ហើយលោកត្រូវរង់ចាំរហូតទាល់១ឆ្នាំក្រោយមក ដែលបានៗការអនុញ្ញាតដើម្បីឲ្យត្រឡប់មកកម្ពុជាវិញ តាមរយៈក្រុងប៉េកាំងនោះ?

[១៦:០១:៣០]

**ឆ៖** បាទ អង្កាល់នោះគឺស្រេចតែអង្គការហៅមក ហៅមកពេលណាមកពេលហ្នឹងមកបាទ។

**ស៖** បាទ ប្រហែលជាបាត់ព័ត៌មានខ្លះក្នុងបកប្រែ។ ខ្ញុំមិនសួរថា គេហៅទេ ខ្ញុំសួរលោកបែបនេះ តើលោកបានស្នើសុំការអនុញ្ញាត ឬលោកស្ម័គ្រចិត្តដើម្បីត្រឡប់មកវិញ ដើមឆ្នាំ១៩៧៥ ហើយ

លោកត្រូវរង់ចាំការរង់ចាំដើម្បីឲ្យអនុញ្ញាតឲ្យបានចូលមក។ គឺមានអត្ថន័យបង្កប់នៅទីនោះ គឺមានន័យថាលោកបានស្នើសុំ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ទាំងអស់គ្នាបានស្នើសុំចូលស្រុក។ ខ្ញុំបានស្នើសុំ បើលោកចង់ដឹង ខ្ញុំបានស្នើសុំចូលស្រុក ហើយពេលដែលគេអនុញ្ញាតឲ្យខ្ញុំមក ខ្ញុំមក។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ឥឡូវនេះខ្ញុំនឹងចូលទៅដល់ប្រធានបទថ្មី ប៉ុន្តែមានពេលតែ២-៣នាទី បាទ ហើយខ្ញុំប្រហែលជាប្រើពេលតែបន្តិច បន្ទាប់ពីម៉ោងបួន។ ដូច្នេះ សូមតុលាការសម្រេចបាទ។

[១៦:០២:៥០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្តបាទ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណ។ ខ្ញុំនឹងត្រូវការប្រហែលជា១ម៉ោង សម្រាប់សួរលោកសាក្សី ហើយខ្ញុំមិនអាចបញ្ចប់ថ្ងៃនេះទេ ដោយសារក្រុមមេធាវីលោក ខៀវ សំផន គាត់នឹងសួរដែរបាទ។ ខ្ញុំមិនចង់ប្រើសិទ្ធិប្រឆាំងនឹងម៉ោងនាឡិកានេះទេបាទ។

**ប្រធានអង្គជំនុំ៖**

អាចច្រឡំគ្នា ពីព្រោះអង្គជំនុំជម្រះស្តាប់ថាលោកហ្នឹង មានត្រូវការពេលវេលាបន្តិចបន្តួចក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ ទំនងជា១០ ឬក៏១៥មីនុត ប៉ុណ្ណោះ។ នេះជាការបកប្រែជាភាសាខ្មែរ។ បើដឹងថាលោកនៅពេលវែងដដែល យើងមិនបាច់សួរដេញដោលរបស់លោក -- ជាមួយលោកស្អីទៀត ព្រោះពេលវេលាត្រូវពេលសម្រាកហើយ។

[១៦:០៣:៥៥]

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១៣ ខែសីហា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃចន្ទ សប្តាហ៍ក្រោយនេះនឹងបន្តស្តាប់សក្ខីកម្មសាក្សី សួង ស៊ីគឿន ដែលនឹងសួរដេញដោលក្រុមមេធាវីការពារក្តី និងជាយថាហេតុអង្គជំនុំជម្រះអាចបន្តស្តាប់សក្ខីកម្មសាក្សី អ៊ុង ចុងហឿង ដោយក្រុមមេធាវីការពារក្តី អាស្រ័យលើបញ្ហា

សុខភាពរបស់ សួង ស៊ីគឿន។ សូមភាគី និងសាធារណជនជ្រាប។

លោក អ៊ុង ផុងហឿង ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ។ សវនាការត្រូវបន្តធ្វើនៅថ្ងៃចន្ទ ទី១៣ ខែសីហា ឆ្នាំ២០១២ គឺដើមសប្តាហ៍ក្រោយនេះ។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្ម នៅថ្ងៃចន្ទ សប្តាហ៍ក្រោយនេះទៀត។

[១៦:០៥:៥៤]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់បរិវេណ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅព្រឹកថ្ងៃចន្ទ ដើម្បីជាការបម្រុងទុកក្នុងការផ្តល់សក្ខីកម្ម ក្នុងករណីយថាហេតុនៃលោក សួង ស៊ីគឿន គាត់មិនមានសុខភាពល្អ មិនអាចផ្តល់សក្ខីកម្មបាន។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីឃុំឃាង នាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនពួកគាត់ទាំងបីរូប ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃចន្ទសប្តាហ៍ក្រោយ ឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៦ នាទី)*